សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស

លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS




# សិទ្ធិនៅលើការទិញដូរ៖ ជីវិត នៅក្នុងពន្ធនាគារ កម្ពុជា

របាយការណ៍ចេញ
ខែមករា ឆ្នាំ២០១៥

# សិទ្ធិនៅលើការទិញដូរ៖ ជីវិត

## នៅក្នុងពន្ធនាគារ កម្ពុជា

របាយការណ៍ចេញខែមករា ឆ្នាំ២០១៥

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅ តាមសាខាទូទាំង ១៣ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តិ ដោយបុគ្គលអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:**
បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ច:**
ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារ:**
អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:**
ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានា:**
ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:**
អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍:**
ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

**សម្រាប់ពត៌មានបន្ថែម សូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារ: (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែល: contact@licadho-cambodia.org
គេហទំព័រ: www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្ដីផ្ដើម ទំព័រ១

សារតារ ទំព័រ២

ការរឹតត្បិតចំពោះការចូលពន្ធនាគារ ទំព័រ៣

សិទ្ធិសម្រាប់លក់ ទំព័រ៥

ការប្រាស្រ័យទាក់ទងជាមួយពិភពខាងក្រៅ ទំព័រ៦

ទឹកជំនន់លិចពន្ធនាគារនាំឲ្យមានការជម្លៀសជនជាប់ឃុំក្នុងទ្រង់ទ្រាយធំ ទំព័រ៩

ពលកម្មក្នុងពន្ធនាគារ ទំព័រ១០

កុមារក្នុងពន្ធនាគារ-គ្រោះថ្នាក់នៃការរំលោភបំពាន និងការកេងប្រវ័ញ្ច ទំព័រ១២

កុមារីក្នុងពន្ធនាគារ-ក្រុមដែលមិនត្រូវបានគេយកចិត្តទុកដាក់ ទំព័រ១៤

ជនជាប់ឃុំជានារី ទំព័រ១៥

កុមារក្នុងពន្ធនាគារ-លូតលាស់ក្នុងពន្ធនាគារកម្ពុជា ទំព័រ១៨

អំពើទារុណកម្ម និងការធ្វើបាប ទំព័រ២២

ស្ថានភាពមិនល្អនៃសម្ភារៈបរិក្ខារពេទ្យក្នុងពន្ធនាគារ ទំព័រ២៤

បញ្ហាសុខភាពផ្លូវចិត្ត ដែលមិនបានយកចិត្តទុកដាក់ ទំព័រ២៦

លើសពីសមត្ថភាព ទំព័រ២៧

ឆ្ពោះទៅបញ្ចប់ការចង្អៀតណែនក្នុងពន្ធនាគារ ទំព័រ២៧

ការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ គួរតែជាការលើកលែង មិនមែនជាវិធានការណ៍នោះទេ ទំព័រ២៩

ទម្រង់ថ្មីរបស់តុលាការ-ជំហានមួយទៀតឆ្ពោះទៅកំណែទម្រង់ ទំព័រ៣០

បន្ទុកមួយសម្រាប់រាជរដ្ឋាភិបាល និងសង្គម ទំព័រ៣១

ការឃុំខ្លួនខុសច្បាប់ ទំព័រ៣៣

ការរង់ចាំសវនាការសាលាឧទ្ធរណ៍ដ៏យូរ ទំព័រ៣៤

ឧបសគ្គក្នុងការទទួលបានយុត្តិធម៌ ទំព័រ៣៥

សេចក្ដីបញ្ចប់ ទំព័រ៣៩

អនុសាសន៍ ទំព័រ៣៩




បន្ទប់ឃុំឃាំង នៅពន្ធនាគារខេត្តកំពង់ឆ្នាំង ឆ្នាំ២០១១




ប្រកចូលទៅកាន់មណ្ឌលអប់រំកែប្រែទី៣ ឆ្នាំ២០១៤

# សេចក្តីផ្តើម

តួនាទីរបស់អគ្គនាយកដ្ឋានពន្ធនាគារ គឺដើម្បីឃុំឃាំងជនជាប់ឃុំ[១] ក្នុងកន្លែងមួយ ដែលប្រកបដោយសុវត្ថិភាព សន្តិសុខ អនាម័យ និងមនុស្សធម៌ ដែលអនុញ្ញាតឲ្យពួកគាត់មានលទ្ធភាព ស្តានីតិសម្បទា ដើម្បីពួកគាត់អាចវិលត្រលប់មករស់នៅក្នុងសង្គមប្រកបដោយអត្ថន័យឡើងវិញ។[២] ទោះបីជាគោលគោលការណ៍ទាំងនេះគួរឲ្យកើតសរសើរយ៉ាងណាក៏ដោយ ក៏វាមិនបានឆ្លុះបញ្ចាំងពីស្ថានភាពជីវិតពិតរបស់ជនជាប់ឃុំជាច្រើននាក់នៅក្នុងពន្ធនាគារកម្ពុជានោះឡើយ។

ជនជាប់ឃុំជាច្រើនមិនមែនគ្រាន់តែត្រូវបានដកហូតសេរីភាពប៉ុណ្ណោះទេ ប៉ុន្តែអ្នកទាំងនោះ ថែមទាំងត្រូវបានដកហូតនូវសិទ្ធិមនុស្សជាមូលដ្ឋានផ្សេងទៀត ដូចជា សិទ្ធិទទួលបានការថែទាំសុខភាព និងសេចក្តីថ្លៃថ្នូរជាមនុស្ស សិទ្ធិរួចផុតពីអំពើទារុណកម្ម និងសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ទៀតផង។ ពួកគាត់ជាច្រើនដែលជាប់ឃុំឃាំង មិនទាន់ត្រូវបានកាត់ឲ្យជាប់ទោសពីបទល្មើស ណាមួយទោះទេ ប៉ុន្តែអ្នកទាំងនោះត្រូវបានគេប្រព្រឹត្តមកលើ ដូចជាទណ្ឌិត ឬធ្ងន់ធ្ងរជាងទណ្ឌិតទៀតផង។ ក្នុងពន្ធនាគារអំពើពុករលួយបានកើតមានជាញឹកញាប់ ខណៈដែលប្រព័ន្ធ និងរចនាសម្ព័ន្ធដឹកនាំមិនផ្លូវការក្នុងបន្ទប់ឃុំឃាំង ជារឿងៗ ត្រូវបានប្រើប្រាស់ជំនួសឲ្យវិធាន និងនីតិវិធីផ្លូវការ ដែលកត្តានេះធ្វើឲ្យយន្តការក្នុងប្តឹងផ្លូវការ មិនត្រូវបានអនុវត្ត ឬ អនុវត្តមិនមានប្រសិទ្ធិភាព។

អង្គការលីកាដូបានកត់ឃើញថា ប៉ុន្មានឆ្នាំចុងក្រោយនេះ វិធានការនៅមានកម្រិត នៅឡើយ ចំពោះការលើកស្ទួយការស្តានីតិសម្បទាក្នុងពេលជាប់ឃុំឃាំង ហើយជម្រើសផ្សេងទៀត ក្រៅពីការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ និងការដាក់ទោសមិនជាប់ពន្ធនាគារ ក៏នៅមានកម្រិតផងដែរ។ ការអនុវត្តកែទម្រង់មានភាពយឺតយ៉ាវ ហើយដូចដែលអគ្គនាយកដ្ឋានពន្ធនាគារទទួលស្គាល់ អញ្ចឹង បញ្ហាប្រឈមជាច្រើននៅតែបន្តកើតមាន ដូចជា ភាពចង្អៀតណែន ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ បញ្ហាខ្វះមធ្យោបាយដឹកជញ្ជូនទៅមកសាលាឧទ្ធរណ៍ ការអនុវត្តន៍ច្បាប់នៅទន់ខ្សោយ និងបញ្ហាកង្វះចំណេះដឹងរបស់មន្ត្រីពន្ធនាគារ។[៣]

របាយការណ៍នេះផ្តល់ការវិភាគលម្អិត ស្តីអំពីស្ថានភាពបច្ចុប្បន្នរបស់ពន្ធនាគារកម្ពុជា ហើយផលប៉ះពាល់ដែលមានទៅលើសិទ្ធិរបស់ជនជាប់ឃុំ។ របាយការណ៍នេះ យោងទៅ លើការស្រាវជ្រាវរបស់អង្គការលីកាដូ នៅក្នុងពន្ធនាគារចំនួន១៨ កន្លែង[៤] ដែលត្រូវបានឃ្លាំមើលជាទៀងទាត់ ដោយរួមទាំងការសម្ភាសន៍ជាមួយជនជាប់ឃុំ អតីតជនជាប់ឃុំ គ្រួសារសាច់ញាតិរបស់ជនជាប់ឃុំ ការជួបប្រជុំជាមួយប្រធានពន្ធនាគារ និងមន្ត្រីពន្ធនាគារផ្សេងទៀត។ របាយការណ៍នេះក៏បាន ប្រើប្រាស់ព័ត៌មាន ដែលទទួលបានពីការចុះទៅទស្សនកិច្ចក្នុងពន្ធនាគារ

[១] នៅក្នុងរបាយការណ៍ ពាក្យថា "prisoner" និង "inmate" ត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក ដោយសំដៅដល់ជនដែលជាប់ក្នុងពន្ធនាគារទាំងអស់។ ពាក្យថា "pre-trial detainee" ត្រូវបានប្រើ នៅពេលសំដៅទៅលើស្ថានភាពជាក់សម្រាប់អ្នកជាប់ឃុំខ្លួនបណ្តោះអាសន្ន ដោយរួមទាំង (ពេលមានព័ត៌មាន) អ្នករង់ចាំបណ្តឹងឧទ្ធរណ៍ និងសាលក្រមស្ថាពរ។

[២] ក្រមខណ្ឌគោលនយោបាយ សម្រាប់កំណែទម្រង់ពន្ធនាគារ ខែមករា ឆ្នាំ២០០៨។

[៣] អគ្គនាយកដ្ឋានពន្ធនាគារ - ផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨ ចំណុច ២.២ បញ្ហាប្រឈម។

[៤] ពន្ធនាគារ PJ មណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី២ មណ្ឌលអប់រំកែប្រែទី៣ មណ្ឌលអប់រំកែប្រែទី៤ ពន្ធនាគារតាខ្មៅ ពន្ធនាគារយោធាទួលស្លែង ពន្ធនាគារខេត្តព្រះសីហនុ ពន្ធនាគារខេត្តកំពង់ស្ពឺ ពន្ធនាគារខេត្តកំពត ពន្ធនាគារខេត្តកំពង់ឆ្នាំង ពន្ធនាគារខេត្តកំពង់ចាម ពន្ធនាគារខេត្តធំ ពន្ធនាគារខេត្តពោធិ៍សាត់ ពន្ធនាគារខេត្តបាត់ដំបង ពន្ធនាគារខេត្តបន្ទាយមានជ័យ ពន្ធនាគារខេត្តសៀមរាប ពន្ធនាគារខេត្តស្វាយរៀង ពន្ធនាគារខេត្តកោះកុង។ អង្គការលីកាដូ មិនធ្វើការឃ្លាំមើលជាប្រចាំនៅកន្លែងផ្សេងទៀត ដែលមនុស្សត្រូវបានដកហូតសេរីភាពផងដែរ ដូចជា ប៉ុស្តិ៍នគរបាល កន្លែងឃុំឃាំងអន្តោប្រវេសន៍ មណ្ឌលស្តានីតិសម្បទាសង្គមកិច្ច និងថ្នាំញៀន។

ដែលប្រព្រឹត្តទៅក្នុងរយៈពេលពីរឆ្នាំ[៥]កន្លងមក និងព័ត៌មានទទួលបានពីក្រុមគ្រូពេទ្យរបស់អង្គការលីកាដូ ដែលបានចុះទៅផ្តល់ការពិនិត្យព្យាបាលជាទៀងទាត់ ដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ នៅតាមពន្ធនាគារចំនួន ១៤ កន្លែង។[៦]

អង្គការលីកាដូទទួលស្គាល់ថា បញ្ហាប្រឈម ទាក់ទងនឹងការគ្រប់គ្រងពន្ធនាគារមាននៅគ្រប់ប្រទេសទាំងអស់ ហើយក៏ទទួលស្គាល់ចំពោះកិច្ចខិតខំប្រឹងប្រែង និងការកែលម្អ ដែលបានធ្វើឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីឈានទៅទទួលបានប្រព័ន្ធពន្ធនាគារដែលប្រសើរជាងមុននៅកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ អង្គការលីកាដូ នៅតែមានការព្រួយបារម្ភជាខ្លាំង ចំពោះស្ថានភាពនៅក្នុងពន្ធនាគារជាច្រើន និង បញ្ហាបន្ត ដែលមានដូចជា ការរំលោភបំពាន ការរើសអើង ការកេងប្រវ័ញ្ច និងអំពើពុករលួយក្នុងប្រព័ន្ធពន្ធនាគារ។ របាយការណ៍នេះ បញ្ជប់ទៅរួមជាមួយអនុសាសន៍មួយចំនួន ជូនចំពោះអាជ្ញាធរកម្ពុជា ទាក់ទងនឹងរបៀបកែលម្អឲ្យប្រសើរឡើងនូវគោលនយោបាយ និងការអនុវត្តន៍ ដើម្បីលើកកម្ពស់ និងការពារឲ្យបានពេញលេញនូវសិទ្ធិរបស់ជនជាប់ឃុំ។



ជនជាប់ឃុំឃាំងជាបុរស នៅក្នុងមណ្ឌលអប់រំកែប្រែទី៣ ឆ្នាំ២០១៣

# សាវតារ

នាពេលបច្ចុប្បន្ន ប្រទេសកម្ពុជាមានមណ្ឌលអប់រំកែប្រែចំនួន ៤ ពន្ធនាគារខេត្ត-ក្រុង ចំនួន ២៣ និងពន្ធនាគារយោធាចំនួន ១។[៧] ពន្ធនាគារស៊ីវិលទាំងអស់ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ។

ពន្ធនាគារនៅកម្ពុជា មានលក្ខណៈខុសប្លែកគ្នាជាច្រើន។ មណ្ឌលអប់រំកែប្រែទី១ ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ មានជនជាប់ឃុំចំនួនរហូតដល់ទៅជាង ៣,០០០ នាក់ ខណៈដែល ពន្ធនាគារខេត្តមណ្ឌលគីរីមានជនជាប់ឃុំតិចជាង ១០០ នាក់ ប៉ុណ្ណោះ នាពេលបច្ចុប្បន្ន។ ពន្ធនាគារខេត្តកំពង់ធំ ដែលមានលក្ខណៈទំនើបជាងបើប្រៀបធៀបជាមួយពន្ធនាគារដ៏ទៃទៀត ត្រូវបានសាងសង់នៅឆ្នាំ ២០១០ ខណៈដែលអគារជាច្រើននៃពន្ធនាគារខេត្តតាកែវ ត្រូវបានសាងសង់ឡើង តាំងពីឆ្នាំ១៩១៤ មកម្ល៉េះ។ ស្ថានភាពទីតាំងភូមិសាស្ត្រ ក៏មានលក្ខណៈខុសគ្នាផងដែរ។ ខណៈដែលពន្ធនាគារខេត្តកណ្តាល ស្ថិតនៅកណ្តាលក្រុងតាខ្មៅ រីឯមណ្ឌលអប់រំកែប្រែទី៤ វិញ ស្ថិតនៅលើដីស្រែរាប់រយសិបហិកតា នៅតំបន់ដាច់ស្រយាល ដែលត្រូវចំណាយពេលធ្វើដំណើរ រហូតដល់ទៅ ១ ម៉ោង និង ៣០ នាទី ពីទីរួមខេត្តពោធិ៍សាត់។

ការមានធនធាន និងសកម្មភាពផ្សេងៗ ក៏អាចអាស្រ័យទៅលើរចនាសម្ព័ន្ធ ទីតាំង និងទំហំរបស់ពន្ធនាគារផងដែរ។ ពន្ធនាគារខ្លះ ដូចជាមណ្ឌលអប់រំកែប្រែទី៤(ម៤)ជាដើមមានកម្មវិធីបណ្តុះបណ្តាលការងារយ៉ាងសម្បូរបែប រីឯពន្ធនាគារដ៏ទៃទៀត ដូចជា ពន្ធនាគារខេត្តសៀមរាប គឺអាស្រ័យទៅលើអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការ

[៥] បន្ថែមទៅលើពន្ធនាគារដែលអង្គការឃ្លាំមើលជាទៀងទាត់ អង្គការលីកាដូ ក៏បានធ្វើ ទស្សនកិច្ចទៅកាន់ពន្ធនាគារខេត្តព្រះវិហារ ពន្ធនាគារខេត្តព្រៃវែង និងកន្លែងឃុំឃាំងបណ្តោះអាសន្ន នៅខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យ។

[៦] ពន្ធនាគារខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង មណ្ឌលអប់រំកែប្រែទី៤ ខេត្តព្រៃវែង ខេត្តស្វាយរៀង តាខ្មៅ PJ និងពន្ធនាគារយោធា ក្នុងរាជធានីភ្នំពេញ។

[៧] លើសពីនេះទៅទៀត មានកន្លែងឃុំឃាំងបណ្តោះអាសន្ន សម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា (ECCC)។

បណ្តុះបណ្តាល សកម្មភាពកំសាន្តផ្សេងៗ និងឱកាសការងារ។ ផ្ទុយទៅវិញ ពន្ធនាគារបណ្តោះអាសន្នរបស់ខេត្តឧត្តរមានជ័យវិញ មិនមាននោះទេ នូវសកម្មភាពទាំងនេះ ហើយជនជាប់ឃុំភាគច្រើន ថែមទាំងមិនត្រូវបានអនុញ្ញាតឲ្យចេញពីបន្ទប់ឃុំឃាំង ដើម្បីធ្វើលំហាត់ប្រាណថែមទៀតផង។[៨]

បើទោះជាមានលក្ខណៈខុសប្លែកគ្នាបែបនេះក៏ដោយ ក៏នៅមានកត្តាមួយចំនួន ដែលបង្ហាញនូវលក្ខណៈទូទៅរបស់ប្រព័ន្ធពន្ធនាគារទាំងមូលផងដែរ។ ភាពចង្អៀតណែន និងភាពខ្វះអនាម័យជាបញ្ហាទូទៅរបស់ពន្ធនាគារ ហើយអំពើពុករលួយក៏នៅតែមានផងដែរ។ សម្រាប់ជនជាប់ឃុំភាគច្រើន លុយជាកត្តាដែលកំណត់នូវស្ថានភាពនៃការឃុំឃាំង ការប្រព្រឹត្តមកលើជនជាប់ឃុំ ការមកសួរសុខទុក្ខរបស់គ្រួសារ[៩] និងការទទួលបាននូវសេចក្តីត្រូវការចាំបាច់មួយចំនួន ដូចជា អាហារ ទឹក ពន្លឺថ្ងៃ និងខ្យល់ធម្មជាតិជាដើម។

អ្នកដែលមិនមានថវិកា រស់នៅក្នុងស្ថានភាពលំបាកយ៉ាងខ្លាំង ដោយពួកគាត់ជានិច្ចជាកាល គេងនៅលើកម្រាលអិដ្ឋផ្ទាល់ ត្រូវគេបង្ខំឲ្យធ្វើការងារមិនសមរម្យ និងក្នុងករណីខ្លះ មិនត្រូវបានគេអនុញ្ញាត ឲ្យចេញក្រៅបន្ទប់ឃុំឃាំងថែមទៀតផង។ ខណៈដែលពន្ធនាគារខ្លះ អួតអាងអំពីសកម្មភាពកំសាន្ត និងឱកាសទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្សេងៗ ក្នុងពន្ធនាគារ ជាញឹកញាប់សកម្មភាព និងឱកាសបែបនេះ មានសម្រាប់ជនជាប់ឃុំមួយចំនួនតូចប៉ុណ្ណោះដែលទទួលបានសិទ្ធិពិសេសនេះ ហើយពេលខ្លះ ទទួលបានដោយសារតែការចំណាយលុយ។ ជាញឹកញាប់ ជនជាប់ឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការ រស់នៅក្នុងស្ថានភាពមិនល្អ ជាងជនដែលត្រូវបានកាត់ទោសរួច ហើយជារឿងកម្រដែលជនជាប់ឃុំត្រូវបានដាក់ឲ្យដាច់ដោយឡែកពីគ្នា ឲ្យបានត្រឹមត្រូវ ទៅតាមកម្រិតសន្តិសុខ ដោយជនជាប់ឃុំបទល្មើសតូចតាច រឿយៗ ត្រូវបានគេដាក់ក្នុងបន្ទប់ឃុំឃាំង ជាមួយជនជាប់ឃុំដែលប្រព្រឹត្តអំពើមនុស្សឃាត និង ជនជាប់ឃុំប្រព្រឹត្តអំពើរំលោភសេពសន្ថវៈជាដើម។

ពន្ធនាគារនៅកម្ពុជានៅតែមានភាពចង្អៀតណែនយ៉ាងខ្លាំងដដែល ជាមួយនឹងចំនួន ជនជាប់ឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការដ៏ច្រើន ករណីឃុំឃាំងខុសច្បាប់ជាច្រើនដែល ត្រូវបានកត់ត្រាកន្លងមក និងការរង់ចាំសវនាការសាលាឧទ្ធរណ៍យ៉ាងយូរ។ ស្ថានភាពជនជាប់ឃុំដែលមានបញ្ហាផ្លូវចិត្ត អនីតិជន នារីមានផ្ទៃពោះ និងកុមាររស់នៅក្នុងពន្ធនាគារជាមួយម្តាយ ក៏ជាក្តីកង្វល់មួយយ៉ាងខ្លាំងផងដែរ ពិសេសដោយសារតែស្ថានភាពមិនល្អយ៉ាងខ្លាំង នៃសម្ភារៈបរិក្ខារពេទ្យរបស់ពន្ធនាគារ និងករណីរំលោភបំពានដែលបន្តកើតមាន។

# ការរឹតត្បិតចំពោះការចូលពន្ធនាគារ

បើទោះជាការរកឃើញរបស់អង្គការលីកាដូ យោងទៅលើការស្រាវជ្រាវពេញលេញក៏ដោយ ប៉ុន្តែគួរតែកត់សម្គាល់ផងដែលថា បញ្ហាប្រឈមជាក់លាក់មួយចំនួន ក៏បានរារាំងអង្គការលីកាដូ ក្នុងការទទួលដឹងពីស្ថានភាពជីវិតនៅក្នុងពន្ធនាគារកម្ពុជា ឲ្យកាន់តែពេញលេញថែមទៀត។ បើតាមលក្ខណៈនៃបញ្ហាប្រឈមដូចមានរៀបរាប់ខាងក្រោម វាទំនងថា អំពើរំលោភបំពានពិតប្រាកដ និងអំពើរំលោភសិទ្ធិមនុស្សផ្សេងទៀត មិនត្រូវបានរាយការណ៍ឲ្យបានទូលំទូលាយនោះទេ។

ក្នុងរយៈពេលបីបួនឆ្នាំកន្លងមក ការចូលធ្វើការរបស់អង្គការលីកាដូ នៅក្នុងពន្ធនាគារ កាន់តែមានការលំបាកខ្លាំងឡើងៗ។ អង្គការលីកាដូ មិនអាចចុះទៅកន្លែងឃុំឃាំង ដោយមិនមានការជម្រាបជូនដំណឹងជាមុនឡើយ ហើយកាន់តែពិបាកជាងមុនថែមទៀតនោះ អ្នកស្រាវជ្រាវពន្ធនាគាររបស់អង្គការលីកាដូ មិនអាចធ្វើការសម្ភាសន៍ក្នុងពន្ធនាគារ ប្រកបដោយភាពសម្ងាត់ពេញលេញបានឡើយ។

អតីតជនជាប់ឃុំបានប្រាប់អង្គការលីកាដូថា មានការរៀបចំយ៉ាងម៉ត់ចត់ជាមុន ដោយអាជ្ញាធរពន្ធនាគារ មុនពេលទស្សនកិច្ចរបស់អ្នកមកពីខាងក្រៅ ដើម្បីធានាថា អគារ សម្ភារៈបរិក្ខារ មើលទៅស្អាត និងមានការរៀបចំបានត្រឹមត្រូវ។ អ្នកខ្លះបានរាយការណ៍ថា ជនជាប់ឃុំត្រូវបានចាក់សោទុក ក្នុងបន្ទប់ឃុំឃាំង នាអំឡុងពេលទស្សនកិច្ច ដើម្បីកុំឲ្យពួកគាត់ទំនាក់ទំនងជាមួយអ្នកធ្វើទស្សនកិច្ចនោះ។ អ្នកផ្សេងទៀតបានប្រាប់ថា ជនជាប់ឃុំទាំងអស់ ត្រូវបានអនុញ្ញាតឲ្យចេញពីបន្ទប់ឃុំឃាំង ក្នុងអំឡុងទស្សនកិច្ច ហើយចាក់សោក្នុងបន្ទប់ឃុំឃាំងវិញភ្លាម បន្ទាប់ពីការទស្សនកិច្ចចប់។ អតីតជនជាប់ឃុំម្នាក់បានប្រាប់ការសម្ងាត់មកអង្គការលីកាដូ ថា គាត់ត្រូវបានអនុញ្ញាតឲ្យចេញក្រៅបន្ទប់ឃុំឃាំង រយៈពេលជាង ១០ នាទី គឺក្នុងអំឡុងពេលទស្សនកិច្ចពន្ធនាគាររបស់អ្នកមកពីខាងក្រៅ ដែលមានការរៀបចំជាមុន។

"ពេលខ្លះ ពេលដែលតំណាងរបស់អង្គការមកធ្វើទស្សនកិច្ចក្នុងពន្ធនាគារ គេអនុញ្ញាតឲ្យពួកយើងបើកកង្ហារ ដើម្បីបង្ហាញថា សិទ្ធិរបស់ជនជាប់ឃុំត្រូវបានគោរព ហើយពួកយើងត្រូវរក្សាភាពស្ងប់ស្ងៀម នៅក្នុងអគារពន្ធនាគារ ក្នុងអំឡុងពេលទស្សនកិច្ចនោះ ប៉ុន្តែតាមការពិតយើងពិតជាមានកំហឹងជាខ្លាំង"

[៨] ក្នុងពេលសរសេររបាយការណ៍នេះ កន្លែងឃុំឃាំងថ្មីនៅខេត្តឧត្តរមានជ័យ ត្រូវបានរាយការណ៍ថា ជិតសាងសង់រួចរាល់ហើយ។
[៩] បើទោះជារបាយការណ៍នេះសំដៅលើការមកសួរសុខទុក្ខរបស់គ្រួសារជាសំខាន់ អង្គការលីកាដូ ដឹងថា ជនជាប់ឃុំខ្លះមិនមានគ្រួសារ មិនមានការប្រាស្រ័យទាក់ទងជាមួយអ្នកខាងក្រៅ ឬ មិនចង់មានការប្រាស្រ័យទាក់ទងជាមួយគ្រួសាររបស់ខ្លួន។ អង្គការលីកាដូ កត់សម្គាល់ថា វាមានភាពសំខាន់ដូចគ្នា ដែលជនជាប់ឃុំទាំងនេះ មានសិទ្ធិប្រាស្រ័យទាក់ទងជាមួយអ្នកដ៏ទៃទៀត ដូចជា មិត្តភក្តិ និងសហសេវិក។

អតីតជនជាប់ឃុំមួយចំនួន ក៏បានរាយការណ៍អំពីការទទួលរងការគំរាមកំហែង មុនពេលការចុះមកដល់ពន្ធនាគាររបស់បុគ្គលិកអង្គការលីកាដូ និងអង្គការដទៃទៀត។ ពួកគាត់ត្រូវបានគេប្រាប់មិនឲ្យនិយាយអ្វី អំពីបទពិសោធន៍ដែលពួកគាត់ជួបប្រទះក្នុងពន្ធនាគារនោះទេ ហើយត្រូវគេគំរាមកំហែង ដាក់ទណ្ឌកម្ម រួមទាំងកាត់បន្ថយរបបអាហារ ប្រសិនបើពួកគាត់មិនធ្វើតាម។ អ្នកខ្លះបានរាយការណ៍ថា បន្ទាប់ពីទស្សនកិច្ច ពួកគាត់ត្រូវបានមន្ត្រីពន្ធនាគារ ឬ មេបន្ទប់សួរអំពីព័ត៌មានលំអិតនៃការសន្ទនា ជាមួយអ្នកដែលមកទស្សនកិច្ចនោះ។

ក្នុងស្ថានភាពបែបនេះ អង្គការលីកាដូ មិនសួរសំណួរអ្វីដែលអាចបង្កគ្រោះថ្នាក់ដល់ជនជាប់ឃុំ ឬ ធ្វើឲ្យប៉ះពាល់ដល់ស្ថានភាពនៃការឃុំឃាំងអ្នកទាំងនោះឡើយ។ លុះត្រាតែ ភាពសម្ងាត់ត្រូវបានធានា អង្គការលីកាដូ ទុកសំណួរណាដែលមានលក្ខណៈរសើប និងសំនួរលំអិតទុកសួរ បន្ទាប់ពីជនជាប់ឃុំត្រូវបានដោះលែង។ បុគ្គលិកអង្គការលីកាដូ ក៏ចុះទៅជួបជនជាប់ឃុំ ជាបន្តបន្ទាប់ ដើម្បីការពារពួកគាត់ពីការសងសឹកណាមួយ។

ការគំរាមកំហែងមកលើជនជាប់ឃុំ មិនបញ្ចប់នៅនឹងខ្លោងទ្វារពន្ធនាគារនោះទេ។ ជនជាប់ឃុំ ដែលធ្លាប់ត្រូវបានគេបំភិតបំភ័យ ឬ ធ្វើបាប ប្រហែលជាស្ទាក់ស្ទើរក្នុងការនិយាយប្រាប់ពី បទពិសោធន៍របស់ខ្លួន បន្ទាប់ពួកគាត់ត្រូវបាន ដោះលែង ដោយសារខ្លាចការដាក់ទណ្ឌកម្ម ឬ ការចាប់ខ្លួនម្តងទៀត។ ក្នុងបរិយាកាសបែបនេះ មិនមែនត្រឹមតែជនជាប់ឃុំប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងគ្រួសាររបស់ពួកគេ និងសូម្បីតែ មន្ត្រីពន្ធនាគារថែមទៀត ពេលខ្លះ មិនចង់លាតត្រដាង អំពីក្តីកង្វល់របស់ខ្លួន ជាមួយអ្នកឃ្លាំមើលពីខាងក្រៅនោះឡើយ។

អង្គការលីកាដូ ក៏បានទទួលនូវការរាយការណ៍ផងដែរថា ជនជាប់ឃុំត្រូវបានគេផ្តល់ថវិកា ដើម្បីឲ្យបិទមាត់។ អតីតជនជាប់ឃុំម្នាក់បានប្រាប់ថា ពេលដោះលែង គាត់ត្រូវបានគេឲ្យថវិកា ចំនួន ២.៥ ដុល្លារអាមេរិក[១០] ជាថ្នូរនឹងការមិនប្រាប់អង្គការមិនមែនរដ្ឋាភិបាលអំពីស្ថានភាពជីវិតនៅក្នុងពន្ធនាគារ។

ជាមួយនឹងការសម្ភាសន៍ជនជាប់ឃុំក្នុងពន្ធនាគារ បុគ្គលិកអង្គការលីកាដូ បានប្រើប្រាស់វិធីសាស្ត្រយ៉ាងប្រយ័ត្នប្រយែង ដើម្បីធានាថាមានសុវត្ថិភាពក្រោយការដោះលែង និងសុវត្ថិភាព របស់សមាជិកគ្រួសារដែលបានផ្តល់ការសម្ភាសន៍។ ការសម្ភាសន៍ទាំងនេះធ្វើឡើងដោយការស្ម័គ្រចិត្ត និងប្រព្រឹត្តទៅនៅកន្លែង ដែលមានសុវត្ថិភាព។ ភាពសម្ងាត់ ត្រូវបានគោរពយ៉ាងពេញលេញ ហើយឈ្មោះមិនដែលត្រូវបានបញ្ចេញនោះទេ ហើយសកម្មភាពតាមដានបន្ត មិនដែលត្រូវបានធ្វើឡើងដោយមិនមានការឯកភាពនោះឡើយ។ ចំពោះអ្នកដោះលែងដែលអាចប្រឈមនឹងហានិភ័យផ្សេងៗ បុគ្គលិកអង្គការលីកាដូ នឹងរក្សាទំនាក់ទំនង បន្ទាប់ពីការសម្ភាសន៍រួច ហើយខ្លាចមានករណីសងសឹកចំពោះពួកគាត់។

ជាអកុសល យើងមិនអាចដឹងអំពីកម្រិតនៃការគំរាមកំហែង ការបំភិតបំភ័យ និង ការសូកប៉ាន់ ដែលត្រូវបានធ្វើឡើង ក្នុងការរារាំងការទទួលព័ត៌មានរបស់អង្គការមិនមែនរដ្ឋាភិបាល ទាក់ទងនឹងស្ថានភាពនៅក្នុងពន្ធនាគារនោះទេ។ ប៉ុន្តែទោះជាយ៉ាងណា យោងតាមចម្លើយ ដែលទទួលបានកន្លងមក អង្គការលីកាដូ ព្រួយបារម្ភថា ការអនុវត្តន៍បែបនេះមានភាពរីកដុះដាល។


ប៉ម ពន្ធនាគារកម្ពុជា ឆ្នាំ២០០៩

[១០] ដើម្បីឲ្យមានភាពស៊ីចង្វាក់គ្នានៅក្នុងរបាយការណ៍ ចំនួននៃទឹកប្រាក់ទាំងអស់ត្រូវគិតជា ដុល្លារសហរដ្ឋអាមេរិក។ នៅកម្ពុជា សាច់ប្រាក់ជាដុល្លារសហរដ្ឋអាមេរិក និងរៀល របស់កម្ពុជា ត្រូវបានប្រើប្រាស់ជាទូទៅ។ ១ ដុល្លារសហរដ្ឋអាមេរិក មានតម្លៃប្រហែល ៤,០០០ រៀល។

# សិទ្ធិសម្រាប់លក់

ជាទូទៅ ស្ថានភាពពន្ធនាគារនៅកម្ពុជា មានលក្ខណៈចង្អៀតណែន ហើយការបំពេញសេចក្តីត្រូវការជាមូលដ្ឋាន ដូចជា អាហារ ទឹក ខ្យល់ចេញចូលធម្មជាតិ និងពន្លឺព្រះអាទិត្យ នៅមានកម្រិត។ ផ្ទុយទៅវិញ ស្ថានភាពរបស់ជនជាប់ឃុំម្នាក់ៗ អាចមានលក្ខណៈខុសប្លែកគ្នាយ៉ាងខ្លាំងជាទូទៅ អាស្រ័យទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ជនជាប់ឃុំម្នាក់ៗ។

ភាគច្រើននៃជនជាប់ឃុំ ដែលត្រូវបានសម្ភាសន៍ដោយអង្គការលីកាដូ បន្ទាប់ពីត្រូវបានដោះលែង បានប្រាប់ថា របស់របរចាំបាច់ និងសិទ្ធិរបស់ជនជាប់ឃុំម្នាក់ៗ បានមកដោយសារការទិញដូរ។ មិនមានអ្វីគួរឲ្យឆ្ងល់នោះទេ ក្រៅពីករណីលើកលែងមួយចំនួនតូច ដែលថា ស្ថានភាពហិរញ្ញវត្ថុរបស់ជនជាប់ឃុំម្នាក់ៗ និងតួនាទីរបស់គាត់នៅក្នុងឋានានុក្រមនៃពន្ធនាគារ ជាកត្តាសំខាន់ ដែលកំណត់ពីស្ថានភាពជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។

ជនជាប់ឃុំដែលក្រីក្របំផុត និងអ្នកដែលមិនមានគ្រួសារមកសួរសុខទុក្ខ ឬ ជនជាប់ឃុំដែលគ្រួសារ និងមិត្តភក្តិមិនអាចចូលសួរសុខទុក្ខបាន ជាធម្មតា ស្ថិតនៅក្រោមគេបំផុតនៃឋានានុក្រមនៅក្នុងពន្ធនាគារ។ អ្នកទាំងនោះទទួលទានដំណេកនៅលើកម្រាលឥដ្ឋផ្ទាល់ ហើយជាញឹកញាប់ គេងជិតបង្គន់ និងរស់នៅ ដោយអាស្រ័យទៅលើម្ហូប និងទឹកដែលពន្ធនាគារផ្តល់ឲ្យតែប៉ុណ្ណោះ។[11] ពួកគាត់មួយចំនួន ស្ថិតនៅក្នុងបន្ទប់ឃុំឃាំងដែលក្តៅងងឹត ហើយមិនមានខ្យល់ចេញចូលគ្រប់គ្រាន់ ស្ទើរតែពេញមួយថ្ងៃ។

*វង្ឃា[12] បានជាប់ក្នុងពន្ធនាគាររយៈពេល ១៩ ខែ។ ក្នុងរយៈពេល ១០ ថ្ងៃ ដំបូង គាត់មិនត្រូវបាន គេអនុញ្ញាតឲ្យចេញពីបន្ទប់ឃុំឃាំងសោះឡើយ។ គាត់ត្រូវបានគេអនុញ្ញាតឲ្យចេញ បន្ទាប់ពីគាត់បង់ប្រាក់ចំនួន ៥០ ដុល្លារអាមេរិក ទៅឲ្យមន្ត្រីពន្ធនាគារ។ ពេលដែរគ្រួសាររបស់គាត់មកសួរសុខទុក្ខគាត់លើកដំបូង គ្រួសារគាត់ត្រូវបង់ប្រាក់ចំនួន ២០ ដុល្លារអាមេរិក ហើយលើកក្រោយៗមកទៀត ពួកគាត់បង់ប្រាក់ចន្លោះពី ២.៥ ដុល្លារអាមេរិក ទៅ ៥ ដុល្លារអាមេរិក សម្រាប់ការជួបសួរសុខទុក្ខម្តងៗ។ វង្ឃាក៏ត្រូវបង់ប្រាក់ចំនួន ០.៥ ដុល្លារអាមេរិក ផងដែរ ទៅឲ្យមន្ត្រីពន្ធនាគារ ដើម្បីទទួលបាននូវម្ហូបអាហារ ដែលគ្រួសារគាត់ផ្ញើរមកឲ្យគាត់។*

ចំពោះអ្នកដែលមានប្រាក់ ឬ មានគ្រួសារ ឬ មិត្តភក្តិមកជួបសួរសុខទុក្ខ ស្ថានភាពរបស់ពួកគាត់មិនអាក្រក់ពេកទេ។ ប្រហែលជា ពួកគាត់អាចទិញអាហារបន្ថែម ទិញកន្លែងគេងបន្ថែម និងទិញពេលវេលាចេញក្រៅបន្ទប់ឃុំឃាំង ហើយអ្នកមកសួរសុខទុក្ខប្រហែលជាយកអាហារ និងរបស់របរផ្សេងទៀតមកឲ្យបន្ថែមខ្លះដែរ។ ពន្ធនាគារខ្លះ វាត្រូវបានគេរាយការណ៍ថា មានបន្ទប់ពិសេស 'VIP' សម្រាប់ជនជាប់ឃុំដែលមានឥទ្ធិពល/អំណាច ឬ ជនជាប់ឃុំដែលមានលទ្ធភាពបង់ប្រាក់ដើម្បីស្នាក់នៅក្នុងបន្ទប់ឃុំឃាំងតែម្នាក់ឯង។ ក្នុងពន្ធនាគារខ្លះទៀត ថ្នាំញៀន ស្រា និងអ្នករកស៊ីផ្លូវភេទ មានរួចជាស្រេចសម្រាប់អ្នកដែល មានប្រាក់ ហើយអង្គការលីកាដូ ទទួលបាននូវសេចក្តីរាយការណ៍អំពីជនជាប់ឃុំខ្លះបានបង់ប្រាក់ រហូតដល់ ២,០០០ ដុល្លារ ដើម្បីបានប្តូរទៅកាន់បន្ទប់ពន្ធនាគារមួយផ្សេងទៀត។

ក្នុងពន្ធនាគារជាច្រើន ជនជាប់ឃុំបានប្រាប់ថា ពួកគាត់ត្រូវបង់ថ្លៃអគ្គិសនី ហើយជនជាប់ឃុំ នៅក្នុងបន្ទប់ឃុំឃាំងនីមួយៗ នៃមណ្ឌលអប់រំកែប្រែទី១ បានប្រាប់ថា ពួកគាត់ត្រូវបង់រហូតដល់ទៅ ២០០ ដុល្លារ ក្នុងមួយខែ ទៅឲ្យមន្ត្រីពន្ធនាគារ សម្រាប់ថ្លៃភ្លើង និងកង្ហារ។ តម្លៃនេះ ត្រូវបានគេរាយការណ៍ថា មានការកើនឡើងពី ១៥០ ដុល្លារ បន្ទាប់ពីការបំពាក់កង្ហារជាប់ពិតានធំជាងមុន។

## ទឹកជាទំនិញ

ការបែកបំពង់ផ្គត់ផ្គង់ទឹក ដែលតភ្ជាប់មណ្ឌលអប់រំកែប្រែទី១ និងមណ្ឌលអប់រំកែប្រែទី២ ទៅនឹងបំពង់មេផ្គត់ផ្គង់ទឹកក្នុងរាជធានីភ្នំពេញ នាពេលថ្មីៗនេះ បានធ្វើឲ្យតម្លៃទឹកនៅក្នុងពន្ធនាគារទាំងពីរ មានការកើនឡើងយ៉ាងខ្លាំង ហើយការបង្កើតឲ្យមានការផ្គត់ផ្គង់ទឹក ដើម្បីរកប្រាក់ចំណេញដែលជាការផ្តល់ប្រយោជន៍ដល់មន្ត្រីពន្ធនាគារ និងជនជាប់ឃុំដែលមានឥទ្ធិពល។ ខណៈដែលជនជាប់ឃុំ ត្រូវចំណាយលុយទិញទឹក សម្រាប់ហូប និងឲ្យគ្រប់គ្រាន់ តម្លៃទឹកត្រូវបានគេបំប៉ោងតម្លៃថែមទៀត បន្ទាប់ពីមានការផ្គត់ផ្គង់ទឹកតាមឡាន។ ជនជាប់ឃុំ ខ្លះបានរាយការណ៍ថា ពួកគាត់មិនមាន លទ្ធភាពទិញទឹកឲ្យបានគ្រប់គ្រាន់ឡើយ ខណៈដែលអ្នកខ្លះទៀត ត្រូវធ្វើការឲ្យជនជាប់ឃុំដែលមានប្រាក់ ដើម្បីបានប្រាក់កាសទិញទឹក។[13]

[11] អនុក្រឹត ឆ្នាំ២០០៩ ស្តីពីរបបអាហារ និងសម្ភារៈបរិក្ខារ គ្រប់គ្រងទៅលើថវិកា សម្រាប់ជនជាប់ឃុំម្នាក់ៗ ដែលពន្ធនាគារត្រូវទទួល។ ថវិកាប្រចាំថ្ងៃសម្រាប់ជនជាប់ឃុំម្នាក់ៗ មានចំនួន ០.៧០ ដុល្លារ។ ជាញឹកញាប់ ពន្ធនាគារមិនទទួលបានថវិកានេះចំនួនពេញលេញក្រោមអនុក្រឹតនេះទេ ឬ ទទួលបានថវិកានេះយឺតយ៉ាវ។ នៅពេល ដែលពួកគេទទួលបានថវិកានេះ វាមិនធានាថា ថវិកាទាំងអស់នឹងត្រូវចំណាយសម្រាប់អ្នកទោសនោះទេ។

[12] លើកលែងតែឈ្មោះពេញលេញរបស់អ្នកផ្តល់ការសម្ភាសន៍ត្រូវបានផ្តល់ជូន ឈ្មោះរបស់អ្នកផ្តល់ការសម្ភាសន៍ផ្សេងទៀត ត្រូវបានផ្លាស់ប្តូរ ដើម្បីការពារអត្តសញ្ញាណ។

[13] ក្នុងពេលសរសេររបាយការណ៍នេះ មណ្ឌលអប់រំកែប្រែទី១ និងមណ្ឌលអប់រំកែប្រែទី២ មិនទាន់បានតភ្ជាប់ទៅប្រព័ន្ធទឹកមេនៅឡើយទេ។

អតីតជនជាប់ឃុំក៏បានប្រាប់ អង្គការលីកាដូ ថា ក្នុងពន្ធនាគារខ្លះ ការទិញដូរមិនមែនត្រឹមតែចំពោះសេចក្តីត្រូវការជាចាំបាច់សម្រាប់ការរស់នៅប៉ុណ្ណោះទេ សូម្បីតែឱកាស ក្នុងការស្តារនីតិសម្បទា ដូចជា ការងារ និងឱកាសទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ឬ ការប្រើប្រាស់បណ្ណាល័យក្នុងពន្ធនាគារ ពេលខ្លះទាល់តែមាន ប្រាក់ ទើបទទួលបានឱកាសទាំងអស់នេះ។

គួរឲ្យបារម្ភទៀតនោះ អង្គការលីកាដូ ទទួលបានសេចក្តីរាយការណ៍ថា ជនជាប់ឃុំខ្លះ ត្រូវបង់ប្រាក់ សម្រាប់សេវាសុខភាព និងថ្នាំពេទ្យក្នុងពន្ធនាគារ។ ជាឧទាហរណ៍ អតីតជនជាប់ឃុំម្នាក់បានរាយការណ៍ថា គាត់ត្រូវបង់ប្រាក់ចំនួន ២២.៥០ ដុល្លារ ទៅឲ្យមន្ត្រីពន្ធនាគារ ដើម្បីបានការស្នាក់នៅក្នុងប៉ុស្តិ៍សុខភាពរបស់ពន្ធនាគារ នៅពេលដែលគាត់ឈឺ។ អតីតជនជាប់ឃុំម្នាក់ទៀត បានប្រាប់ថា បន្ថែមទៅលើការបង់ប្រាក់ថ្លៃសេវាពេទ្យ គាត់ត្រូវឲ្យប្រាក់ចំនួន ១០ ដុល្លារ ទៀត ទៅឲ្យមន្ត្រីពន្ធនាគារ ដើម្បីឲ្យគេអនុញ្ញាតឲ្យគាត់ទៅជួបពេទ្យឯកទេសនៅខាងក្រៅពន្ធនាគារ។

# ការប្រាស្រ័យទាក់ទងជាមួយពិភពខាងក្រៅ

ជនជាប់ឃុំទាំងអស់ មានសិទ្ធិធ្វើការប្រាស្រ័យទាក់ទងជាទៀងទាត់ ជាមួយគ្រួសារ និង មិត្តភក្តិ រួមទាំងការមកសួរសុខទុក្ខផ្ទាល់ផងដែរ។ ការទំនាក់ទំនងនេះមានសារៈសំខាន់សម្រាប់ សុខភាពផ្លូវចិត្តរបស់ជនជាប់ឃុំ ហើយដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើសមាហរណកម្មជាមួយគ្រួសារ និងសហគមន៍នាពេលក្រោយ។ នៅកម្ពុជា អ្នកមកសួរសុខទុក្ខជនជាប់ឃុំ ពិតជាសំខាន់ផងដែរ ហើយជាញឹកញាប់ ជាប្រភពតែមួយគត់ សម្រាប់អាហារមានជីវជាតិ ថ្នាំ និងថវិកា។

ប៉ុន្តែ នៅកម្ពុជា សិទ្ធិនេះមានតែចំពោះអ្នកដែលមានគ្រួសារ ឬ មិត្តភក្តិដែលមានលទ្ធភាព មកសួរសុខទុក្ខប៉ុណ្ណោះ។ បន្ថែមទៅលើថ្លៃធ្វើដំណើរ ពេលវេលាឈប់សម្រាកពីការងារ និងការចាត់ចែងចំពោះការថែទាំកូន អ្នកមកសួរសុខទុក្ខ តម្រូវឲ្យបង់ប្រាក់ឲ្យពន្ធនាគាររាល់ពេលនៃការមកសួរសុខទុក្ខ។ ចំនួនដែលត្រូវបង់ អាស្រ័យទៅតាមរយៈពេលនៃការជួបសួរសុខទុក្ខ ទីកន្លែងនៃការជួបសួរសុខទុក្ខ ថ្ងៃមកសួរសុខទុក្ខ និងលទ្ធភាពមានប្រាក់របស់អ្នកមកសួរសុខទុក្ខ។

ចំនួនជាទូទៅដែលលើកឡើងដោយជនជាប់ឃុំ និងគ្រួសារ គឺចន្លោះ ២.៥ ដុល្លារ ទៅ ៥ ដុល្លារ សម្រាប់ការជួបតាមនាំងដែក សម្រាប់រយៈពេល ១៥ នាទី ហើយឡើងដល់ ១០ ដុល្លារ សម្រាប់ការជួបក្នុងបរិវេណពន្ធនាគារ និង ១៥ ដុល្លារ ឬ លើសពីនេះ សម្រាប់ការជួបជាលក្ខណៈឯកជន។ ប្រសិនបើអ្នកមកសួរសុខទុក្ខនាំមកជាមួយនូវអាហារ ឬ របស់របរផ្សេងទៀត ពួកគាត់ជាញឹកញាប់ត្រូវតម្រូវឲ្យបង់ប្រាក់បន្ថែម ឬ ក៏ទុកចំណែកខ្លះនៃអាហារ ឬ របស់របរនោះ ទៅឲ្យមន្ត្រីពន្ធនាគារ។ ជនជាប់ឃុំដែលបានដោះលែងម្នាក់ បានប្រាប់អង្គការលីកាដូ ថា គ្រួសាររបស់គាត់ ត្រូវបង់ប្រាក់បន្ថែមចំនួន ២.៥ ដុល្លារ ពេលដែរកូនរបស់គាត់មកសួរសុខទុក្ខគាត់។

*ពេលដែល ផល្លី ត្រូវការថ្នាំ ដែលមិនមាននៅប៉ុស្តិ៍សុខភាពក្នុងពន្ធនាគារ គ្រួសាររបស់គាត់ ត្រូវយកថ្នាំនោះមកឲ្យគាត់ ហើយត្រូវបង់ប្រាក់ចំនួនពី ០.៥ ដុល្លារ ទៅ ១.២៥ ដុល្លារ រៀងរាល់ពេលដែលគ្រួសារយកមកម្តងៗ។ ដោយសារ ផល្លី មានបញ្ហាសុខភាពច្រើនបន្ទាប់ពីជាប់ក្នុងពន្ធនាគារ គ្រួសាររបស់ផល្លី យកអាហារ និងថ្នាំមកឲ្យផល្លី ពីរបីដងក្នុងមួយសប្តាហ៍ ហើយពួកគាត់មកជួបសួរសុខទុក្ខផល្លីរយៈពេលយូរ (តម្លៃ ៥ ដុល្លារ) ពីរ ឬ បីដង ក្នុងមួយខែ។ ក្នុងរយៈពេលជាប់ពន្ធនាគារចំនួនមួយឆ្នាំ ពួកគាត់ចំណាយថវិកាអស់ជិតចំនួន ២៥០ ដុល្លារ ហើយការចំណាយនេះសម្រាប់តែការសុំចូលសួរសុខទុក្ខប៉ុណ្ណោះ ដោយមិនគិតបញ្ចូលទាំងថ្លៃធ្វើដំណើរ និងថ្លៃចំណាយផ្សេងៗទៀត នោះទេ។*

ថ្វីបើការមកសួរសុខទុក្ខ ពីសំណាក់អ្នកខាងក្រៅមានសារៈសំខាន់សម្រាប់ជនជាប់ឃុំទាំងអស់គ្នា ផ្ទុយទៅវិញ មានជនជាប់ឃុំខ្លះទំនងជាទទួលរងផលប៉ះពាល់ នៅពេលដែលមានការរឹតត្បិតទៅលើលក្ខខណ្ឌ និងភាពញឹកញាប់នៃការមកសួរសុខទុក្ខ។ ឧទាហរណ៍ម្តាយ គួរតែត្រូវបានអនុញ្ញាតឲ្យជួបជាទៀងទាត់ និងជួបផ្ទាល់ជាមួយកូនតូចៗរបស់គាត់ ហើយនៅពេលមានអនីតិជនជាប់ឃុំឃាំង វាជារឿងចាំបាច់ សម្រាប់ពួកគាត់ក្នុងការបន្តផ្សាភ្ជាប់ទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ពួកគាត់ជាទៀងទាត់និងដោយមិនមានការរឹតត្បិត។ ប៉ុន្តែជាអកុសល ការស្រាវជ្រាវរបស់អង្គការលីកាដូ បង្ហាញថា កត្តាទាំងអស់ខាងលើនេះ មិនត្រូវបានយកទៅពិចារណានោះទេ ពេលដែល មន្ត្រីពន្ធនាគារ ទារថ្លៃចូលសួរសុខទុក្ខពីពួកគាត់។



ផ្លូវទៅកាន់មណ្ឌលអប់រំកែប្រែទី៤ មានសភាពលំបាក ឆ្នាំ២០១៤

កង្វះការប្រាស្រ័យទាក់ទងជាមួយគ្រួសារ ក៏ជាបញ្ហាគួរឲ្យបារម្ភណ៍ជាខ្លាំងផងដែរ ចំពោះជនជាប់ឃុំដែលជាប់នៅក្នុងពន្ធនាគារឆ្ងាយដាច់ស្រយាល ដូចជា មណ្ឌលអប់រំកែប្រែទី៣ និងមណ្ឌលអប់រំកែប្រែទី៤ ដែលដាក់ជនជាប់ឃុំជាទណ្ឌិតបុរស ដែលត្រូវបានផ្ទេរមកពីពន្ធនាគារខេត្តផ្សេងៗទូទាំងប្រទេស។ការធ្វើដំណើរទៅកាន់ពន្ធនាគារនីមួយៗក្នុងចំណោមពន្ធនាគារទាំងពីរនេះត្រូវចំណាយពេលវេលាជាង ៩០ នាទី ពីទីរួមខេត្តដែលស្ថិតនៅជិតទីនោះបំផុត ដូចជាពីទីរួមខេត្តកំពង់ចាម និងទីរួមខេត្តពោធិ៍សាត់ ដែលធ្វើឲ្យគ្រួសារ និងមិត្តភក្តិរបស់អ្នកជាប់ឃុំទាំងនោះជាច្រើន មិនអាចទៅសួរសុខទុក្ខពួកគាត់បាន។ លើលពីនេះទៅទៀត ពន្ធនាគារទាំងពីរស្ថិតនៅប្រមាណជា ៨០ គីឡូម៉ែត្រ ពីមន្ទីរពេទ្យខេត្ត ដែលជាពេទ្យស្ថិតនៅក្បែរនោះបំផុតផងដែរ។

*លោក ស សុង ជាអ្នកការពារសិទ្ធិមនុស្សម្នាក់ ដែលជាប់ឃុំឃាំងដោយសារសកម្មភាពការពារដីធ្លីរបស់គាត់ បានជាប់ពន្ធនាគារ ខេត្តកំពង់ឆ្នាំង អស់ជិតរយៈពេល ៥ឆ្នាំ ប៉ុន្តែបន្ទាប់ពីចូលរួមសវនាការសាលាឧទ្ធរណ៍ នៅរាជធានីភ្នំពេញ ហើយស្ថិតនៅមណ្ឌលអប់រំកែប្រែទី១ រយៈពេល ៣ ខែ មក គាត់ត្រូវបានគេបញ្ជូនទៅមណ្ឌលអប់រំកែប្រែទី៣ នៅខេត្តកំពង់ចាម ដោយមិនពន្យល់ហេតុផលសោះឡើយ។ គាត់ជាប់នៅមណ្ឌលអប់រំកែប្រែទី៣ អស់ រយៈពេល ១០ ខែ ដែលជារយៈពេលនៅសល់នៃកំណត់ទោសរបស់គាត់។ គាត់ជឿថា ការធ្វើបែបនេះ ដើម្បីរារាំងគ្រួសាររបស់គាត់ក្នុងការទៅសួរសុខទុក្ខគាត់ និងដើម្បីជាការព្រមានដល់សកម្មជនសហគមន៍ដទៃទៀតថា ពួកគាត់ក៏អាចត្រូវបញ្ជូនទៅមណ្ឌលអប់រំកែប្រែទី៣ ផងដែរ ប្រសិនបើពួកគាត់បង្កបញ្ហា។ ភរិយារបស់គាត់មិនត្រូវបានគេប្រាប់ អំពីការផ្ទេរគាត់នោះទេ។ ភរិយាគាត់ បានដឹងរឿងនេះ នៅពេលដែលគាត់ធ្វើដំណើរ មកសួរសុខទុក្ខស្វាមីរបស់គាត់នៅមណ្ឌលអប់រំកែប្រែទី១។ ដោយសារតែទីតាំងឆ្ងាយដាច់ស្រយាលរបស់មណ្ឌលអប់រំកែប្រែទី៣ ភរិយារបស់គាត់ បានមកសួរសុខទុក្ខគាត់បានត្រឹមតែម្តងប៉ុណ្ណោះ ក្នុងរយៈពេល ៣ ខែ ប៉ុន្តែកាលគាត់ជាប់ឃុំនៅពន្ធនាគារខេត្តកំពង់ឆ្នាំង ភរិយារបស់គាត់មកសួរសុខទុក្ខគាត់យ៉ាងហោចណាស់ ២ ដង ក្នុង ១ ខែ។*


ក្រុមគ្រួសារមកសួរសុខទុក្ខនៅពន្ធនាគារ ខេត្តកំពង់ចាម ឆ្នាំ២០១២

ក្នុងខែសីហាឆ្នាំ២០១៤អាជ្ញាធរពន្ធនាគារជម្រាបអង្គការ លីកាដូ ថាមានអ្នកមកសួរសុខទុក្ខជនជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី៣ ច្រើនបំផុត ត្រឹមតែ ៣ ឬ ៤ នាក់ ប៉ុណ្ណោះ។ នៅពេលនោះ មណ្ឌលអប់រំកែប្រែទី៣ មានផ្ទុកជនជាប់ឃុំចំនួន ១,៤១០ នាក់ ហើយភាគច្រើននៃអ្នកទាំងនោះមកពីខេត្តដទៃទៀត ជាជាងខេត្តកំពង់ចាម។ ដោយសារទីតាំងភូមិសាស្ត្រដាច់ស្រយាល អ្នកមកសួរសុខទុក្ខ ត្រូវចំណាយថវិកាសម្រាប់ការស្នាក់នៅ យ៉ាងតិចណាស់ ១ យប់ បន្ថែមទៅលើថ្លៃធ្វើដំណើរថែមទៀត។ ជាក្តីបារម្ភ អង្គការលីកាដូទទួលបានសេចក្តីរាយការណ៍ថា គេមានគម្រោងសាងសង់អគារឃុំឃាំង សម្រាប់ជនជាប់ឃុំជានារី និងអនីតិជន នៅមណ្ឌលអប់រំកែប្រែទី៣ នាពេលណាមួយផងដែរ។

## សិទ្ធិ មិនមែនជាបុព្វសិទ្ធិទេ

ជាការប៉ុនប៉ង ក្នុងការរារាំងដល់ការប្រាស្រ័យទាក់ទងរបស់ជនជាប់ឃុំ ដែលមានភាពអាម៉ាស់បំផុត គឺប្រហែលកើតមានកាលពីដើម ឆ្នាំ២០១៤ នៅពេលដែលសកម្មជន និងអ្នកការពារសិទ្ធិមនុស្សចំនួន ២៣ នាក់ ត្រូវបានចាប់ខ្លួនក្នុងអំឡុងពេល នៃការបង្ក្រាបដ៏សាហាវទៅលើការប្រមូលផ្តុំរបស់ក្រុមកម្មករ នៅរាជធានីភ្នំពេញ។ បន្ទាប់បង្ហាញខ្លួនមួយភ្លែតនៅតុលាការ បុរសទាំង ២៣ នាក់ រួមទាំងអនីតិជនម្នាក់ផង ត្រូវបានឃុំឃាំង ដោយមិនឲ្យមានទំនាក់ទំនងជាមួយនរណាម្នាក់នៅកន្លែងមិនស្គាល់មួយអស់រយៈពេលមួយសប្តាហ៍។ ចុងបញ្ចប់អាជ្ញាធរបានសារភាពថា ពួកគាត់ត្រូវបានឃុំឃាំង នៅមណ្ឌលអប់រំកែប្រែទី៣ ជាពន្ធនាគារដែលមានស្ថានភាពមិនល្អ ហើយស្ថិតនៅឆ្ងាយដាច់ស្រយាល ដែលជាពន្ធនាគារ សម្រាប់ដាក់តែទណ្ឌិតជាបុរស ដែលជាប់ទោសរយៈពេលយូរ។

ចំណាត់ការដ៏អាក្រក់ដែលបានគ្រោងទុករបស់អាជ្ញាធរនេះ ប្រាកដជាត្រូវបានរៀបចំឡើង ដើម្បីកាត់ផ្តាច់ទំនាក់ទំនងរបស់អ្នកទាំងអស់នេះ ពីពិភពខាងក្រៅ និងដើម្បីលាក់បាំង នូវស្ថានភាពដ៏អាក្រក់នៃការឃុំឃាំងពួកគាត់។ ១៣ នាក់ ក្នុងចំណោមអ្នកទាំងនោះ ត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលប៉ះទង្គិចគ្នា ដែលយ៉ាងហោចណាស់ មនុស្ស ៤ នាក់ បានបាញ់សម្លាប់ ហើយមនុស្សជាច្រើននាក់ផ្សេងទៀត បានរងរបួស។ ភាគច្រើន នៃបុរសទាំង ២៣ នាក់ ត្រូវវាយដំយ៉ាងធ្ងន់ធ្ងរ នាអំឡុងពេលចាប់ខ្លួន ហើយដំបូង មិនត្រូវបានអនុញ្ញាតឲ្យជួបគ្រូពេទ្យឯករាជ្យនោះទេ។

ដោយសារ ទីតាំងភូមិសាស្ត្រដាច់ស្រយាល របស់មណ្ឌលអប់រំកែប្រែទី៣ មានន័យថា បើមិនមានការជួយឧបត្ថម្ភគាំទ្រពីសំណាក់អង្គការមិនរដ្ឋាភិបាលទេ វាលំបាក សម្រាប់គ្រួសារសហសេវិក និងអ្នកគាំទ្រ ក្នុងការទៅសួរសុខទុក្ខពួកគាត់ ផ្តល់របស់របរផ្សេងៗ និងជួយផ្នែកផ្លូវចិត្ត និងប្រាប់អំពីការវិវត្តន៍នៃយុទ្ធនាការ ទូទាំងពិភពលោក ដើម្បីទាមទារឲ្យមានការដោះលែងអ្នកទាំងនោះ ឲ្យបានទៀងទាត់ណាស់។ ការសម្រេចចិត្ត ក្នុងការបញ្ជូនអ្នកទាំងនោះទៅកាន់ មណ្ឌលអប់រំកែប្រែទី៣ ក៏ទំនងជាដោយសារតែព្រួយបារម្ភ ចំពោះការតវ៉ាលក្ខណៈទ្រង់ទ្រាយធំនៅខាងមុខពន្ធនាគារដែលងាយស្រួលជាង (មណ្ឌលអប់រំកែប្រែ ទី១ នៅភ្នំពេញ) និងដើម្បីទប់ស្កាត់ព័ត៌មានអំពីការតវ៉ា កុំឲ្យរីករាលដាលនៅក្នុងពន្ធនាគារ នេះ។

ម្តាយរបស់អតីតជនជាប់ឃុំម្នាក់ បានប្រាប់មកអង្គការលីកាដូ ថា អំឡុងពេលដែលកូនប្រុសអាយុ ២២ ឆ្នាំ របស់គាត់ ជាប់ពន្ធនាគាររយៈពេល ១ ឆ្នាំ នៅមណ្ឌលអប់រំកែប្រែទី៤ គាត់មិនដែលបានទៅលេងសួរសុខទុក្ខកូនប្រុសរបស់គាត់ទេ សូម្បីតែម្តង ដោយសារតែឆ្ងាយ និងថ្លៃធ្វើដំណើរខ្ពស់។ ជាការជំនួស ពេលណាគាត់ឮថា មន្ត្រីពន្ធនាគារនៅមណ្ឌលអប់រំកែប្រែទី៤ ធ្វើដំណើរមកភ្នំពេញ គាត់តែងតែសូមផ្ញើរ មី និង របស់របរចាំចាច់សម្រាប់ហូបចុកផ្សេងទៀតទៅតាមមន្ត្រីពន្ធនាគារនោះ។ ចុងក្រោយ គាត់បានធ្វើដំណើរលើចម្ងាយផ្លូវ ២៥០ គីឡូម៉ែត្រ ទៅកាន់ពន្ធនាគារនោះ នាថ្ងៃដែលកូនប្រុសរបស់គាត់ត្រូវបានដោះលែង ដើម្បីជួបកូនរបស់គាត់នៅមុខខ្លោងទ្វារពន្ធនាគារ និងនាំកូនរបស់គាត់ត្រលប់មកផ្ទះវិញ។

វាមិនមែនតែនៅមណ្ឌលអប់រំកែប្រែទី៣ និងមណ្ឌលអប់រំកែប្រែទី៤ ប៉ុណ្ណោះទេ ដែលអ្នកសួរសុខទុក្ខអាចមានការលំបាកក្នុងការទៅដល់។ ពន្ធនាគារដែលទើបសាងសង់ថ្មី និងពន្ធនាគារដែលកំពុងសាងសង់ជាច្រើន ស្ថិតនៅទីតាំងមិនសមរម្យ និងដាច់ស្រយាលចម្ងាយរាប់គីឡូម៉ែត្រ ពីទីរួមខេត្ត ដោយសាងសង់ក្រោមកម្មវិធីដោះដូរដីដែលផ្តល់ផលកម្រៃច្រើន រវាងអាជ្ញាធរខេត្ត និងក្រុមហ៊ុនឯកជន។

បន្ថែមទៅលើការរំលោភសិទ្ធិ ក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកខាងក្រៅពន្ធនាគារ អង្គការលីកាដូ ក៏ទទួលបានការរាយការណ៍ ជាច្រើនផងដែរ ទាក់ទងនឹងការមិនអនុញ្ញាតឲ្យជនជាប់ឃុំជួបជាមួយគ្រួសារ ដែលពេលខ្លះមានរយៈពេលរាប់ខែម្តងៗ ជាការដាក់ពិន័យចំពោះរំលោភតូចតាចទៅលើវិន័យរបស់ពន្ធនាគារ។ ការដាក់ទណ្ឌកម្មបែបនេះ ក៏អនុវត្តចំពោះជនជាប់ឃុំជានារី ដែលមានកូនតូច និងអនីតិជនផងដែរ។

ការបដិសេធចំពោះការចូលជួបសួរសុខទុក្ខរបស់គ្រួសារ ជារឿងមិនអាចទទួលយកបានទៅហើយនោះ លើសពីនេះទៅទៀត អាជ្ញាធរកម្ពុជាបានដឹងច្បាស់ផងដែរថា ក្នុងប្រព័ន្ធពន្ធនាគារដែលខ្វះខាតធនធានស្រាប់ ការដាក់ពិន័យបែបនេះ ក៏បណ្តាលឲ្យប៉ះពាល់ដោយផ្ទាល់ទៅដល់ការទទួលបានម្ហូបអាហារ ថ្នាំ និងរបស់របរចាំបាច់ផ្សេងទៀត សម្រាប់អ្នកជាប់ពិន័យនោះផងដែរ។

សិទ្ធិក្នុងការប្រាស្រ័យទាក់ទងជាមួយពិភពខាងក្រៅ មិនមែន មានត្រឹមតែសិទ្ធិក្នុងការជួបជាមួយអ្នកសួរសុខទុក្ខប៉ុណ្ណោះទេ។ ជនជាប់ឃុំ គួរតែផ្តល់សិទ្ធិក្នុងការឆ្លើយឆ្លងលិខិតជាទៀតទាត់ ការទំនាក់ទំនងតាមទូរស័ព្ទ និងការទទួលបានព័ត៌មានពីប្រភពខាងក្រៅ ដូចជា តាមរយៈសៀវភៅ កាសែត ទស្សនាវដ្តី វិទ្យុ និងទូរទស្សន៍ ប្រសិនអាចធ្វើទៅបាន។ ទោះជាយ៉ាងណាក៏ដោយ ក៏សិទ្ធិទាំងអស់នេះ មិនត្រូវបានធានាសម្រាប់ជនជាប់ឃុំទាំងអស់គ្នានោះទេ នៅប្រទេសកម្ពុជា។

ចំណុចទី១ ថ្លៃទូរស័ព្ទនៅតាមពន្ធនាគារខ្លះ ធ្វើឲ្យជនជាប់ឃុំខ្លះមិនមានលទ្ធភាពប្រើប្រាស់ទូរស័ព្ទ។ ចំនុចទី២ ការទទួលបានព័ត៌មានអំពីហេតុការណ៍បច្ចុប្បន្ន អាចមិនស្មើគ្នា ហើយអាស្រ័យទៅលើស្ថានភាពនយោបាយ។ ជាឧទាហរណ៍ បន្ទាប់ពីការបោះឆ្នោតជាតិឆ្នាំ២០១៣ ដែលមិនឯកភាពគ្នា អង្គការលីកាដូ បានទទួលនូវសេចក្តីរាយការណ៍ថា នៅតាមពន្ធនាគារខ្លះ ជាពិសេសនៅភ្នំពេញ ការស្តាប់ការផ្សាយព័ត៌មាននៅតាមវិទ្យុ ត្រូវបានរឹតត្បិត។ ស្រដៀងគ្នានេះដែរ អំឡុងពេលការជួបជុំគ្នាក្នុងទ្រង់ទ្រាយធំ នាមុនពេល និងក្រោយពេលបោះឆ្នោតជាតិ ជនជាប់ឃុំខ្លះប្រាប់អង្គការលីកាដូ ថា វិទ្យុផ្ទាល់ខ្លួនត្រូវបានរឹបអូស ក្នុងការព្យាយាមយ៉ាងច្បាស់ ដើម្បីទប់ស្កាត់នូវនិន្នាការនយោបាយប្រឆាំងដែលមាននៅក្នុងពន្ធនាគារ។



ទឹកជំនន់នៅពន្ធនាគារ ខេត្តបន្ទាយមានជ័យ ឆ្នាំ២០១០

# ទឹកជំនន់លិចពន្ធនាគារ នាំឲ្យមានការជម្លៀសជនជាប់ឃុំ ក្នុងទ្រង់ទ្រាយធំ

កាលពីខែតុលា ឆ្នាំ២០១៣ ជនជាប់ឃុំជិត ៩០០ នាក់ ត្រូវបានជម្លៀសចេញ ពីពន្ធនាគារខេត្តបន្ទាយមានជ័យ បន្ទាប់ពីទឹកជំនន់ បានបំផ្លាញរបងពន្ធនាគារ និងជន់លិចបរិវេណពន្ធនាគារ។ ពន្ធនាគារនេះ ត្រូវបានសាងសង់ចប់ជាស្ថាពរក្នុងឆ្នាំ២០០៩ ហើយត្រូវបានសាងសង់ឡើង នៅលើទីតាំងមិនសមស្រប និងងាយជន់លិច ដែលមានចម្ងាយប្រហែល ៧ គីឡូម៉ែត្រ ពីក្រុងសេរីសោភ័ណ្ឌ ក្រោមកិច្ចព្រមព្រៀងដោះដូរដី ដែលមានផលចំណេញជាច្រើន។ ពន្ធនាគារនេះរងគ្រោះដោយសារទឹកជំនន់ជារៀងរាល់ឆ្នាំ ប៉ុន្តែមិនធ្លាប់មានការជម្លៀសចេញនោះទេកន្លងមក។

ជនជាប់ឃុំ ដោយរួមទាំងអនីតិជន និងកុមារតូចៗផង ត្រូវបានផ្ទេរទៅកាន់ពន្ធនាគារខេត្តសៀមរាប និងពន្ធនាគារខេត្តបាត់ដំបង ដែលកំពុងតែមានភាពចង្អៀតណែនយ៉ាងខ្លាំងស្រាប់ ហើយ ពួកគាត់ត្រូវស្នាក់ទៅនោះអស់រយៈពេលជាច្រើនសប្តាហ៍។ អង្គការលីកាដូ បានសំដែងការព្រួយបារម្ភ ទាក់ទងនឹងសមត្ថភាពរបស់មន្ត្រីពន្ធនាគារ ការចង្អៀតណែនក្នុងពន្ធនាគារទាំងពីរនោះ បញ្ហាអនាម័យ និងសុខភាព និងអសមត្ថភាពរបស់ពន្ធនាគារទាំងពីរ ក្នុងការដាក់ជនជាប់ឃុំដាច់ដោយឡែកតាមក្រុមឲ្យបានគ្រប់គ្រាន់។

ថ្វីបើធ្លាប់ជួបប្រទះបញ្ហាទឹកជំនន់លិចពន្ធនាគារ កន្លងមកហើយក៏ដោយ វាច្បាស់ថា អាជ្ញាធរមិនមានការត្រៀមរៀបចំ បានត្រឹមត្រូវ សម្រាប់ការជម្លៀសចេញទ្រង់ទ្រាយបែបនេះនោះទេ។ មន្ត្រីពន្ធនាគារមានប្រសាសន៍ថា ខ្លួនមិនបានទទួលការបណ្តុះបណ្តាលជាមុន សម្រាប់ការជម្លៀសជាបន្ទាន់ទោះទេ ហើយពន្ធនាគារខ្លួនឯងផ្ទាល់ក៏មិនមាននីតិវិធីក្នុងការជម្លៀសផងដែរ។ បើទោះជានារីត្រូវបានដឹកដោយឡានផ្សេងគ្នាពីបុរសក៏ដោយ ក៏ពួកគាត់ត្រូវបានអមដំណើរដោយមន្ត្រីពន្ធនាគារជាបុរសដដែល។

ពន្ធនាគារខេត្តសៀមរាប និងខេត្តបាត់ដំបង មិនអាចទ្រាំទ្រនឹងតម្រូវការបន្ថែម សម្រាប់អាហារ ថ្នាំពេទ្យ និងរបស់របរចាំបាច់ផ្សេងទៀត ដូចជា មុង កម្រាល ចាន និងប្រដាប់ប្រដា សម្រាប់ហូបអាហារនោះទេ ហើយពឹងផ្អែកលើការជួយរបស់អង្គការជាតិ និងអន្តរជាតិ។ ពេលវេលាចេញក្រៅបន្ទប់ឃុំឃាំង ត្រូវបានកាត់បន្ថយ ដោយសារចំនួនជនជាប់ឃុំបន្ថែម ខណៈដែល បើតាមការរាយការណ៍ ជនជាប់ឃុំ ត្រូវដាក់វេនគ្នា ទទួលទានដំណេក ដោយសារមិនមានកន្លែងទទួលទានដំណេកគ្រប់គ្រាន់។

អង្គការលីកាដូក៏បានលើកឡើងអំពី កង្វះនីតិវិធីដែលគួរតែមានស្រាប់ ដើម្បីធានាថា ជនជាប់ឃុំដែលត្រូវបានជម្លៀសទៅ នៅតែអាចចូលរួមសវនាការ ជួបជាមួយមេធាវី និងគ្រួសារ ហើយថា ជនជាប់ឃុំដែលនឹងត្រូវដោះលែង នឹងមិនបន្តជាប់ក្នុងពន្ធនាគារនោះទេ។ ការព្រួយបារម្ភថា ជនជាប់ឃុំដែលឈឺអាចនឹងមិនទទួលបានការថែទាំសុខភាពបានសមស្រប និងជាបន្តបន្ទាប់ ហើយកាលបរិច្ឆេទកំណត់ទាក់ទងនឹងដំណើរការផ្លូវច្បាប់ អាចនឹងត្រូវខកខានកាន់តែអាចកើតមានឡើង ដោយសារឯកសារពេទ្យ និងសំណុំរឿងរបស់ជនជាប់ឃុំមិនត្រូវផ្ទេរទៅជាមួយអ្នកទាំងនោះ។ លើសពីនេះទៅទៀត មេធាវី និងសមាជិកគ្រួសារ មិនត្រូវបានគេប្រាប់អំពីកន្លែង ដែលអតិថិជន ឬ សាច់ញាតិរបស់ខ្លួនត្រូវផ្ទេរទៅនៅឡើយ។

ពេលត្រលប់ទៅពន្ធនាគារខេត្តបន្ទាយមានជ័យវិញ ជនជាប់ឃុំជាច្រើនឃើញថា ទ្រព្យសម្បត្តិ ឬ របស់របរ របស់ពួកគាត់ត្រូវបានបំផ្លាញក្នុងទឹកលិច ឬ ផ្នែកខ្លះ ត្រូវបានបំផ្លាញ និងដុតចោលដោយមន្ត្រីពន្ធនាគារ។ ជនជាប់ឃុំមិនទទួលបានសំណងអ្វីនោះទេ ចំពោះ របស់របរដែលត្រូវបានបំផ្លាញទាំងនោះ។

អង្គការលីកាដូ បានឆ្លើយតបទៅនឹងស្ថានភាពនេះដោយបានបញ្ជូនក្រុមគ្រូពេទ្យពីរក្រុមភ្លាមៗ ដើម្បីព្យាបាលអ្នកដែលភៀសខ្លួនទាំងនោះ។ អង្គការលីកាដូ ក៏បានផ្តល់នូវអាហារ សម្ភារៈ និងថ្នាំពេទ្យបន្ថែមទៅពន្ធនាគារសៀមរាប និងបាត់ដំបង ដើម្បីជួយអ្នកទាំងនោះ សម្របខ្លួនទៅនឹងលំហូរនៃអ្នកជាប់ពន្ធនាគារបន្ថែមជាច្រើន។


ជនជាប់ឃុំជាបុរសកំពុងសាងសង់ពន្ធនាគារថ្មី នៅខេត្តឧត្តរមានជ័យ ឆ្នាំ២០១៤

# ពលកម្មក្នុងពន្ធនាគារ

ក្នុងឆ្នាំ២០១២ អង្គការលីកាដូ បានផ្តល់នូវអនុសាសន៍លើសេចក្តីប្រកាសអន្តរក្រសួង ស្តីពីការហាមឃាត់ចំពោះការប្រើប្រាស់ពលកម្មក្នុងពន្ធនាគារ ដើម្បីផលិតទំនិញនាំចេញទៅក្រៅប្រទេស។[១៤] ប្រកាសនេះត្រូវបានរៀបចំឡើង ក្នុងពេលដែលមានសេចក្តីរាយការណ៍ លើប្រព័ន្ធផ្សព្វផ្សាយជាច្រើនថា ក្រុមហ៊ុននៅកម្ពុជា បានជួលជនជាប់ឃុំឲ្យផលិតសម្លៀកបំពាក់សម្រាប់នាំចេញ និងការព្រួយបារម្ភរបស់អង្គការលីកាដូ ផ្ទាល់ ចំពោះមាត្រា ៧១ នៃច្បាប់ស្តីពី ពន្ធនាគាររបស់កម្ពុជា ដែលអនុញ្ញាតឲ្យក្រុមហ៊ុនឯកជនជួលជនជាប់ឃុំជានិយោជិក។

អង្គការលីកាដូបានស្វាគមន៍ចំពោះប្រកាសថ្មីនេះ ប៉ុន្តែបានសំដែងនូវការព្រួយបារម្ភថា ពាក្យពេចន៍ក្នុងចំណុចសំខាន់ៗជាច្រើននៅមានភាពមិនច្បាស់លាស់។ ទោះជាយ៉ាងណា ចាប់តាំងពីការបង្កើតប្រកាសនេះមក អង្គការលីកាដូ មានក្តីរីករាយ ដោយកត់សំគាល់ឃើញថាអង្គការលីកាដូមិនបានទទួល នូវសេចក្តីរាយការណ៍ទាក់ទងនឹងទំនិញនាំចេញ ដែលផលិតដោយពលកម្មក្នុងពន្ធនាគារនោះទេ។ ប៉ុន្តែ ទោះបីជាមានជំហានវិជ្ជមាននេះក៏ដោយ អង្គការលីកាដូ នៅតែព្រួយបារម្ភជាខ្លាំង ចំពោះបញ្ហាជាច្រើន ជុំវិញពលកម្មក្នុងពន្ធនាគារនៅកម្ពុជា រួមទាំងបញ្ញត្តិនៃមាត្រា ៧១ ផងដែរ។

អង្គការពលកម្មអន្តរជាតិកំណត់ថា ជនជាប់ឃុំអាចធ្វើការឲ្យក្រុមហ៊ុនឯកជនបានតែក្នុងលក្ខខណ្ឌថា ពួកគាត់ធ្វើដោយស្ម័គ្រចិត្ត ហើយក្នុងលក្ខខណ្ឌ "ប្រហាក់ប្រហែលនឹងទំនាក់ទំនងការងារដោយសេរី"[១៥] ហើយតែក្នុងលក្ខខណ្ឌនៃការបំពេញពលកម្ម មិនត្រូវទាបជាងទីផ្សារសេរីពេកនោះទេ បើពុំនោះវាអាចចាត់ទុកជាការកេងប្រវ័ញ្ចកំលាំងពលកម្ម។"[១៦]

យោងតាមអង្គការពលកម្មអន្តរជាតិ សូចនាករនៃទំនាក់ទំនងការងារដោយសេរី រួមមាន ការយល់ព្រមជាផ្លូវការរបស់ជនជាប់ឃុំ ក្នុងការធ្វើការងារ និងលទ្ធភាពក្នុងការដកខ្លួនចេញពេលណាក៏បាន លក្ខខណ្ឌការងារមានលក្ខណៈស្រដៀងគ្នានឹងការងារនៅក្រៅពន្ធនាគារ ហើយតម្លៃពលកម្មប្រហាក់ប្រហែលនឹងកម្មករសេរី ដែលមានជំនាញ និងបទពិសោធន៍ប្រហាក់ប្រហែលគ្នា។ តម្លៃពលកម្មគួរតែទូទាត់ឲ្យទៅ ពលករផ្ទាល់ ហើយលក្ខខណ្ឌការងារគួរតែអនុលោមទៅតាមបទដ្ឋានសុខភាព និងសុវត្ថិភាព។

គួរឲ្យសោកស្តាយ ចម្លើយដែលអង្គការលីកាដូទទួលបានកន្លងមក រួមជាមួយនឹងសេចក្តីរាយការណ៍លើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននាពេលថ្មីៗនេះ បង្ហាញថា ជនជាប់ឃុំនៅកម្ពុជានៅតែធ្វើការឲ្យក្រុមហ៊ុនឯកជន ក្នុងលក្ខខណ្ឌការងារដែលមិនស្រដៀងគ្នានឹងទំនាក់ទំនងទីផ្សារសេរីដដែល។ ជាឧទាហរណ៍ ការស៊ើបអង្កេតនាពេលថ្មីៗនេះ ដោយកាសែតខេមបូឌាដេលី បង្ហាញថា ជនជាប់ឃុំប្រហែល ១៥ នាក់ មកពីពន្ធនាគារបណ្តោះអាសន្នខេត្តឧត្តរមានជ័យ បានកំពុងធ្វើការ កសាងពន្ធនាគារថ្មី ក្រោមកិច្ចសន្យាសាងសង់របស់ក្រុមហ៊ុនឯកជន ក្នុងលក្ខខណ្ឌការងារគួរឲ្យសង្ស័យ។

[១៤] http://www.licadho-cambodia.org/reports/files/166LICADHOBriefing-PrisonLabor%20Prakas2012-English.pdf
[១៥] អង្គការពលកម្មអន្តរជាតិ របាយការណ៍ឆ្នាំ២០០៧ ស្តីពីការលុបបំបាត់ការងារដោយបង្ខំ៖ ជំពូក ll អនុសញ្ញាស្តីពីការងារដោយបង្ខំ ឆ្នាំ១៩៣០ (លេខ ២៩) កថាខ័ណ្ឌ ១៦
[១៦] អង្គការពលកម្មអន្តរជាតិ របាយការណ៍ទូទៅស្តីពីគណៈកម្មាធិការជំនាញ នៃការអនុវត្តន៍ អនុសញ្ញា និងអនុសញ្ញា ឆ្នាំ២០០១ កថាខ័ណ្ឌ ១៤៣។

*"ក្រៅពីមិនមានវិធានការដើម្បីធានាសុវត្ថិភាព និងសុខភាព នៅកន្លែងសាងសង់ក្នុងខេត្តឧត្តរមានជ័យជនជាប់ឃុំមួយចំនួនធ្វើការដោយមិនមានស្បែកជើងហើយមិនមាននរណាម្នាក់ពាក់ឧបករណ៍ការពារសុវត្ថិភាពឡើយ។ ពួកគាត់ទទួលបានថ្លៃពលកម្មតិចជាង ១ ដុល្លារ ប៉ុណ្ណោះក្នុងមួយថ្ងៃ ដែលថ្លៃពលកម្មនេះ ទាបជាងថ្លៃពលកម្ម ៥ ដុល្លារ ឬ ច្រើនជាងនេះ ដែលកម្មករខាងក្រៅពន្ធនាគារទទួលបានយ៉ាងច្រើន។"*[១៧]

ស្រដៀងគ្នានេះដែរ នាពេលថ្មីៗនេះ កាសែតភ្នំពេញប៉ុស្តិ៍ បានរាយការណ៍ថា អាជីវកម្មឯកជន ធ្វើគ្រឿងសង្ហារឹម ហើយផ្តល់កម្រៃខ្ពស់ កំពុងដំណើរការនៅក្នុងពន្ធនាគារខេត្តបាត់ដំបង ហើយបានប្រើប្រាស់ជនជាប់ឃុំធ្វើការក្នុងស្ថានភាពកេងប្រវ័ញ្ចពលកម្មយ៉ាងច្បាស់។

*ជនជាប់ឃុំដែលមិនព្រមធ្វើការ ឬ ឈប់សម្រាកដោយសារឈឺ មិនត្រូវគេអនុញ្ញាតឲ្យជួបគ្រួសារដែលមកសួរសុខទុក្ខ ឬក៏ត្រូវគេចាក់សោក្នុងបន្ទប់ឃុំឃាំង ជាការដាក់ទណ្ឌកម្ម ឬ ក៏ត្រូវគេដាក់ខ្នោះដៃរយៈពេលយូរជាទម្រង់មួយនៃទារុណកម្ម...។ "យើងមិនចង់ឲ្យគេដាក់ទណ្ឌកម្ម ដូច្នេះហើយ យើងត្រូវតែធ្វើការ បើទោះជាយើងឈឺក៏ដោយ។" មន្ត្រីពន្ធនាគារម្នាក់ និយាយក្នុងលក្ខខណ្ឌសូមមិនបញ្ចេញឈ្មោះ បានពិពណ៌នាស្ថានភាពនៅទីនោះយ៉ាងច្បាស់លាស់។ "ពួកគេបង្ខំជនជាប់ឃុំឲ្យធ្វើការឲ្យពួកគេ (ធ្វើគ្រឿងសង្ហារឹម) សម្រាប់លក់ ហើយជនជាប់ឃុំមិនទទួលបានផលប្រយោជន៍អ្វីសោះឡើយ។ យើងមិនមានអំណាច ដូច្នេះហើយ យើងមិនអាចនិយាយអ្វីចេញបានទេ។"*[១៨]



ពលកម្មនៅពន្ធនាគារ ខេត្តពោធិ៍សាត់ ឆ្នាំ២០១០

គួរឲ្យអាសូរ ការងារក្នុងពន្ធនាគារដែលគ្រប់គ្រងចាត់ចែងដោយរដ្ឋគឺ ក៏នឹងងាយរងការរំលោភបំពានផងដែរ។ គម្រោងរកប្រាក់ចំណេញដូចជា កម្មវិធីកសិកម្មខ្នាតធំនៅមណ្ឌលអប់រំកែប្រែទី៣ និងមណ្ឌលអប់រំកែប្រែទី៤ ជារឿយៗ មានលក្ខណៈបង្ខិតបង្ខំ ហើយជនជាប់ឃុំមួយចំនួនបានប្រាប់ថា មិនទទួលបានការទូទាត់អ្វីទាល់តែសោះ ខណៈដែលនៅតាមពន្ធនាគារតូចៗវិញ ជនជាប់ឃុំបានប្រាប់អង្គការលីកាដូ ថា ពួកគាត់ត្រូវបង់ប្រាក់ ដើម្បីទទួលបានឱកាសចេញមកខាងបន្ទប់ឃុំឃាំង ធ្វើការនៅសួនបន្លែរបស់ពន្ធនាគារ ធ្វើការនៅផ្ទះបាយ ឬក៏ធ្វើការឲ្យគម្រោងដេរប៉ាក់ ឬ សិប្បកម្មខ្នាតតូច។

គោលការណ៍មូលដ្ឋាននៃពលកម្មក្នុងពន្ធនាគារ ដូចដែលអាជ្ញាធរកម្ពុជា[១៩] បានទទួលស្គាល់នោះ គឺថាកម្មវិធីការងារគួរតែមានគោលបំណង បង្កើនជំនាញវិជ្ជាជីវៈឲ្យអ្នកជាប់ឃុំ ដើម្បីជួយសម្រួលដល់ការធ្វើសមាហរណកម្មពួកគាត់ចូលក្នុងសង្គម នាពេលដែលពួកគាត់ត្រូវបានដោះលែង។ ជនជាប់ឃុំ គួរតែផ្តល់នូវសម្ភារៈ/ឧបករណ៍ការពារសុវត្ថិភាព ដើម្បីធានានូវសុវត្ថិភាពនៅកន្លែងធ្វើការងារ។ ប៉ុន្តែ អង្គការលីកាដូ ទទួលបានរបាយការណ៍ជាច្រើនដែលអាចបញ្ជាក់បានថា គេគិតពីប្រាក់ចំណេញពីកម្មវិធីការងារនោះ ច្រើនជាងការព្រួយបារម្ភអំពីសុវត្ថិភាព និងឱកាសការងារនាពេលខាងមុខរបស់ជនជាប់ឃុំ។

## ការទទួលរងទណ្ឌកម្មចំពោះការមិនព្រមធ្វើការ

អតីតជនជាប់ឃុំ ជាស្ត្រីម្នាក់នៃពន្ធនាគារមួយ បានពិពណ៌នាប្រាប់អង្គការលីកាដូអំពី ការរឹតត្បិតពេលវេលាចេញក្រៅបន្ទប់ឃុំឃាំងដល់ជនជាប់ឃុំទាំងអស់ ពេលដែលមិនមានចំនួននារីគ្រប់គ្រាន់ មកពីបន្ទប់ឃុំឃាំងនោះ ចេញទៅធ្វើការនៅរោងផលិតក្រណាត់ជូតឡាន។ អង្គការលីកាដូ ក៏ទទួលបានសេចក្តីរាយការណ៍ជាច្រើនផងដែរ ទាក់ទងនឹងស្ត្រីជាប់ឃុំខ្លះ ត្រូវបានគំរាមកំហែង ពេលដែលពួកគាត់មិនព្រមចេញទៅធ្វើការបើទោះពេលពួកគាត់ឈឺក៏ដោយ ដូចជាទណ្ឌកម្មដោយប្រាប់ថា គ្រួសាររបស់ពួកគាត់នឹងមិនអាចមកសួរសុខទុក្ខពួកគាត់ បានឡើយ។

រោងជាងទៀតសោត ត្រូវបានគេរាយការណ៍ថា មានសភាពក្តៅយ៉ាងខ្លាំងដោយសារដំបូលទាប និងខ្យល់អាកាសចេញចូលតិច។ ជាលទ្ធផល នារីដែលធ្វើការនៅទីនោះជាច្រើន មានបញ្ហាសុខភាព ប៉ុន្តែពួកគាត់មិនទទួលបានការព្យាបាលនោះទេ។ អ្នកខ្លះរាយការណ៍ថា ពួកគាត់មិនទទួលបានប្រាក់កម្រៃ អ្វីនោះទេ ហើយផ្ទុយទៅវិញ ប្រាក់ដែលបានពីការលក់ក្រណាត់ជូតឡាន ត្រូវមន្ត្រីពន្ធនាគារ និងមេបន្ទប់ចែកគ្នា។

[១៧] http://www.cambodiadaily.com/news/amid-overcrowding-inmates-build-new-prison-67129/
[១៨] http://www.phnompenhpost.com/national/made-conviction
[១៩] សម្រាប់ជាឧទាហរណ៍ សូមមើលក្របខ័ណ្ឌគោលនយោបាយសម្រាប់ការកំណែទម្រង់ពន្ធនាគារ

# កុមារក្នុងពន្ធនាគារ–គ្រោះថ្នាក់នៃការរំលោភបំពាន និងការកេងប្រវ័ញ្ច

បន្ទាប់ពីរយៈពេល ១០ ឆ្នាំ នៃការធ្វើសេចក្តីព្រាងច្បាប់ ច្បាប់ ស្តីពីកុមារក្នុងទំនាស់ជាមួយច្បាប់ នៅមិនទាន់បានបញ្ចប់នៅឡើយទេ គិតត្រឹមខែធ្នូ ឆ្នាំ២០១៤ ហើយទំនងជាមិនទាន់អនុម័តនាពេលឆាប់ៗខាងមុខនោះទេ។ សេចក្តីព្រាងច្បាប់នេះ ដែលអង្គការលីកាដូ[២០] បានឃើញ មានការលើកឡើងអំពីគោលការណ៍ និងសិទ្ធិជាមូលដ្ឋានមួយចំនួន ដែលមានចែងរួចហើយនៅក្នុងច្បាប់កម្ពុជាដែលមានស្រាប់ ដូចជាមុខងារនៃការស្តានីតិសម្បទា និងសមាហរណកម្ម នៃការឃុំឃាំង ការបែងចែងដាច់ដោយឡែករវាងជនជាប់ឃុំជានីតិជន និងអនីតិជន ការហាមឃាត់ដាច់ខាតចំពោះទារុណកម្ម និងការដាក់ទណ្ឌកម្ម និងអំពើឃោឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប ហើយនិង លក្ខខណ្ឌដែលថា ការឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការ គឺជាមធ្យោបាយចុងក្រោយបំផុតផងដែរ។

ខណៈដែលមានការលើកកម្ពស់ ការប្រើប្រាស់ជម្រើសទណ្ឌកម្មផ្សេងៗ ជំនួសឲ្យការដាក់ទោសជាប់ពន្ធនាគារ និងវិធានការបង្វែរទោសលើអនីតិជន សេចក្តីព្រាងច្បាប់ក៏បានចែងអំពីវិធានខ្លះៗ សម្រាប់ការឃុំឃាំងអនីតិជន ទាំងនៅពន្ធនាគារ និងកន្លែងឃុំឃាំងរបស់នគរបាល។ តាមចម្លើយដែលអង្គការលីកាដូ ទទួលបាន បង្ហាញនូវភាពបន្ទាន់នៃការអនុម័ត និងអនុវត្តច្បាប់នេះ ដោយមិនមានការពន្យាពេលបន្តទៀត។ បច្ចុប្បន្ន អនីតិជនដែលជាប់ឃុំឃាំង ប្រឈមនឹងការរំលោភបំពាន ការប្រមាថ និងការបន្ថោកបន្ទាប ដូចអ្នកជាប់ឃុំឃាំងជានីតិជនដែរ ហើយទំនងជាត្រូវបានប្រព្រឹត្តចំពោះដោយអាស្រ័យទៅលើស្ថានភាពហិរញ្ញវត្ថុ ជាជាងអាយុរបស់អ្នកទាំងនោះ។

កុមារក្នុងពន្ធនាគារ ភាគច្រើនមកពីក្រុមគ្រួសារខ្សត់ខ្សោយ ហើយគ្រួសាររបស់អ្នកទាំងនោះទំនងជាជួបការលំបាក ក្នុងការផ្គត់ផ្គង់ពួកគាត់ ទាំងថវិកា និងទាំងរបស់របរផ្សេងៗ។ នេះមានន័យថា ក្នុងប្រព័ន្ធពន្ធនាគារ ដែលមានការបែងចែកឋានៈទៅតាមអំណាចទឹកប្រាក់ ក្រុមដែលងាយរងគ្រោះស្រាប់នេះ នឹងប្រឈមនឹងការកេងប្រវ័ញ្ច និងស្ថិតក្រោមការបង្គាប់បញ្ជារបស់គេបន្ថែមទៀត។ អ្នកខ្លះធ្លាក់ក្រោមការគ្រប់គ្រងរបស់អ្នកមានទឹកប្រាក់ ក្រោមការគ្រប់គ្រងរបស់ជនជាប់ឃុំជានីតិជន ដែលបានក្លាយជាឪពុកធម៌របស់ខ្លួន និងក្រោមការគ្រប់គ្រងរបស់ជន ដែលជនជាប់ឃុំជាកុមារនេះធ្វើការឲ្យ ដើម្បីជាថ្នូរនឹងការទទួលបានការពារ ការចេញក្រៅបន្ទប់ឃុំឃាំងច្រើន ឬ ដើម្បីទឹកប្រាក់បន្តិចបន្តួច។ អ្នកផ្តល់ការការពារនេះ អាចក្លាយជាអ្នករំលោភបំពានលើជនជាប់ឃុំជាកុមារយ៉ាងឆាប់រហ័ស ប្រសិនបើជនជាប់ឃុំជាកុមារនេះ ធ្វើកិច្ចការអ្វីមួយមិនបានល្អឲ្យជនជាប់ឃុំជានីតិជននេះ ឬ ក៏ជនជាប់ឃុំជានីតិជនលែងត្រូវការជនជាប់ឃុំជាកុមារនេះទៀតហើយ។

*"ប្រសិនបើកុមារាម្នាក់គ្មានគ្រួសារ ឬ មកពីគ្រួសារខ្សត់ខ្សោយ មកជាប់ក្នុងពន្ធនាគារ ជនជាប់ឃុំជានីតិជននឹងជ្រើសរើសកុមារានោះឲ្យស្នាក់នៅ និងរស់នៅក្នុងបន្ទប់ឃុំឃាំងជាមួយខ្លួន និងដើម្បីបម្រើខ្លួន។ ជនជាប់ឃុំជាកុមារានេះ នឹងត្រូវឲ្យចំអិនអាហារ និងផ្តល់ការម៉ាស្សាពេលយប់ដល់ជនជាប់ឃុំជានីតិជន។*

ទោះជាមានពន្ធនាគារជាច្រើន បានព្យាយាមដាក់អនីតិជន និងនីតិជន ឲ្យនៅដាច់ដោយឡែកពីគ្នាក៏ដោយ នៅមានពន្ធនាគារមួយចំនួនទៀត មិនមានការបែងចែកបែបនេះទេ ហើយនៅពន្ធនាគារខ្លះ ការដាក់ដាច់ដោយឡែកពីគ្នាអាស្រ័យទៅលើចំនួនអ្នកជាប់ឃុំក្នុងពេលវេលាមួយ។ ឧទាហរណ៍ ប្រសិនបើមានជនជាប់ឃុំជាអនីតិជនជាបុរសចំនួនត្រឹមតែបីបួននាក់ អាជ្ញាធរពន្ធនាគារប្រហែលជាសម្រេចថា ចំនួនប៉ុននេះមិនចាំបាច់មានបន្ទប់ដាច់ដោយឡែកនោះទេ ហើយផ្ទុយទៅវិញ ប្រសិនបើបន្ទប់ឃុំអនីតិជនចង្អៀតខ្លាំង ពួកគាត់នឹងត្រូវផ្ទេរឲ្យទៅនៅជាមួយបន្ទប់ជនជាប់ឃុំជានីតិជន។

ពេលដែលអនីតិជន ត្រូវបានដាក់ឲ្យនៅដាច់ដោយឡែកពីនីតិជន ពួកគាត់ប្រហែលជាមានកន្លែងសម្រាប់គេង និងរស់នៅធំជាងមុន ប៉ុន្តែ ដោយសារតែអត្រាអ្នករស់នៅក្នុងបន្ទប់នីមួយៗច្រើន មានន័យថា អនីតិជនជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការ កម្រដាក់ដោយឡែកពីអនីតិជនជាទណ្ឌិត ហើយមិនមានការដាក់អនីតិជនដាច់ដោយឡែកទៅតាមប្រភេទបទល្មើសឬប្រភេទបទចោទនោះទេ។

បើទោះជាមានកន្លែងដាក់ឲ្យនៅដាច់ពីគ្នាក៏ដោយ ក៏មានការព្យាយាមតិចតួចណាស់ ក្នុងការការពារអនីតិជនឲ្យបានពេញលេញ ពីឥទ្ធិពលអវិជ្ជមានរបស់ជនជាប់ឃុំជានីតិជន ពីព្រោះជាញឹកញាប់ ពួកគាត់ទាំងពីរក្រុមធ្វើការទំនាក់ទំនងគ្នា បានងាយស្រួលពេលចេញពីបន្ទប់ឃុំឃាំង ។ អង្គការលីកាដូក៏បានដឹងផងដែរ ចំពោះពន្ធនាគារខ្លះ ដែលដាក់ជនជាប់ឃុំជានីតិជន នៅក្នុងបន្ទប់ឃុំឃាំងរបស់អនីតិជន ហើយដើរតួនាទីជាប្រធានបន្ទប់ ក្នុងនាមជាអ្នកទប់ស្កាត់ការឈ្លោះទាស់ទែងរបស់យុវជន។ ប៉ុន្តែតាមការពិត ការរៀបចំបែបនេះ ជម្រុញឲ្យមានការបែងចែកអំណាចរវាងអនីតិជន និងនីតិជន ហើយធ្វើឲ្យជនជាប់ឃុំជាអនីតិជនងាយប្រឈមនឹងហានិភ័យមិនចាំបាច់ដូចជាអំពើហិង្សា និងការកេងប្រវ័ញ្ចជាដើម។

គួរឲ្យសោកស្តាយ អង្គការលីកាដូ នៅតែបន្តទទួលបានករណីដែលអនីតិជនត្រូវជាប់ឃុំឃាំងបណ្តោះអាសន្ន រង់ចាំសវនាការ និងដាក់ទោសជាប់ពន្ធនាការ ដោយសារបទល្មើសតូចតាចបំផុត ដោយមិនគិត អំពីផលប៉ះពាល់រយៈពេលយូរដែលអាចកើតមានចំពោះអនាគតរបស់អ្នកទាំងនោះ។ នាពេលថ្មីៗនេះ អង្គការលីកាដូ បានជួបកុមារាអាយុ ១៥ ឆ្នាំ ម្នាក់ ដែលនៅពេលជួបនោះ គាត់កំពុងជាប់ឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការ អស់រយៈពេល ៦ ខែ ដោយសារតែគាត់លួចអង្ករមួយការ៉ុង។ ពេលដែល អង្គការលីកាដូ ជួបគាត់ គាត់មិនដឹងថា គាត់មានមេធាវី ឬអត់ ហើយមិនដឹងសូម្បីថាតើ មានការបើកសវនាការទៅលើករណីរបស់គាត់ហើយ ឬនៅ។ មួយ

[២០] អង្គការលីកាដូ មិនដឹងថា តើសេចក្តីព្រាងច្បាប់បច្ចុប្បន្ន មានកែប្រែច្រើនពីសេចក្តីព្រាង ច្បាប់មុនដែលអង្គការលីកាដូបានឃើញនោះទេ។

ខែក្រោយមក មានការបើកសវនាការលើករណីរបស់គាត់ ហើយគាត់ត្រូវបានផ្តន្ទាទោស ឲ្យជាប់ពន្ធនាគាររយៈពេល ៧ ខែ ហើយគាត់ត្រូវបានដោះលែងនៅសប្តាហ៍បន្ទាប់។

ក្នុងនាមជាជនជាប់ឃុំ អនីតិជនមានសេចក្តីត្រូវការជាពិសេស ដើម្បីការលូតលាស់ផ្នែករាយកាយ បញ្ញាស្មារតី និងការយល់ដឹងអំពីសង្គម ប៉ុន្តែ គួរឲ្យអាសូរសេចក្តីត្រូវការទាំងនេះ កម្របានបំពេញឲ្យបានពេញលេញណាស់ នៅក្នុងពន្ធនាគារនៅកម្ពុជា។ ដូចគ្នានេះដែរ សេចក្តីត្រូវការក្នុងការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏មានលក្ខណៈខុសប្លែកគ្នា ពីសេចក្តីត្រូវការរបស់នីតិជន អាស្រ័យទៅលើអាយុ ភេទ និងសមត្ថភាពរាយកាយ។

ទោះជាយ៉ាងណា ឱកាសទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាកត្តាសំខាន់ សម្រាប់ការស្តានីតិសម្បទាដ៏ជោគជ័យ និងកាត់បន្ថយអត្រាកើតឡើងវិញនៃបទល្មើស មិនបានផ្តល់ជូនដល់ជនជាប់ឃុំវ័យក្មេងទាំងអស់នោះទេ។ បើទោះជា អ្នកទាំងនោះមួយចំនួន ប្រហែលជាទទួលបានផលប្រយោជន៍ពីកម្មវិធីបណ្តុះបណ្តាល ដែលរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល ដែលរៀបចំជាពិសេសទៅតាមអាយុ និងសេចក្តីត្រូវការរបស់ពួកគាត់ក៏ដោយ ក៏អង្គការលីកាដូ នៅតែបន្តទទួលបានការរាយការណ៍ថា កម្មវិធីខ្លះ គឺមានតែសម្រាប់តែអ្នកមានលទ្ធភាពបង់ប្រាក់ប៉ុណ្ណោះ។ នៅតាមពន្ធនាគារខ្លះ ដែលមានទីតាំងដាច់ស្រយាល ហើយមិនសូវមានអង្គការមិនមែនរដ្ឋាភិបាល វាមិនមានឱកាសបណ្តុះបណ្តាលដល់អនីតិជនទាល់តែសោះ។

*"កុមារាមួយចំនួនត្រូវបានឃុំក្នុងបន្ទប់ឃុំឃាំង ហើយមិនបានអនុញ្ញាតឲ្យចេញមកសិក្សានោះទេ។ វាពិតជាអយុត្តិធម៌ ដែលអ្នកមានប្រាក់បង់អាចរៀនបាន ហើយអ្នកដែលក្រីក្រ ត្រូវជាប់ឃុំឃាំងក្នុងបន្ទប់។"*

តាមសភាពពិត ការទទួលបានសេវា ឬ របស់របរផ្សេងៗរបស់ជនជាប់ឃុំជាអនីតិជន គឺអាស្រ័យទៅលើលុយ មិនមែនអាយុនោះទេ។ ការមកសួរសុខទុក្ខញឹកញាប់របស់គ្រួសារ ដែលមានសារៈសំខាន់ជាខ្លាំងសម្រាប់សុខមាលភាព និងការធ្វើសមាហរណកម្មកុមារ គឺអាស្រ័យទៅស្ថានភាពហិរញ្ញវត្ថុ។ ដូចគ្នានេះដែរ ការទទួលបានអាហារូបត្ថម្ភ ពេលវេលាហាត់ប្រាណទៀងទាត់ និងការលេងកីឡា ដែលមានសារៈសំខាន់យ៉ាងខ្លាំង ចំពោះការអភិវឌ្ឍន៍ផ្នែករាយកាយ មិនអាចធានាបានទេ ប្រសិនបើគ្មានប្រាក់។

ដូចគ្នានឹងនីតិជនផងដែរ អនីតិជននៅក្នុងពន្ធនាគារកម្ពុជាមិនមានការការពារ និងយន្តការដែលមានប្រសិទ្ធិភាព ក្នុងការប្តឹងអំពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមិនសមរម្យនោះទេ។ ពួកគាត់រាយការណ៍អំពីការវាយ ទាត់ ទះ ដោយជនជាប់ឃុំដទៃទៀត ហើយពេលខ្លះ ក្រោមបញ្ជាពីមន្ត្រីពន្ធនាគារ។ នេះរួមទាំងការវាយដំទៅលើជនជាប់ឃុំពេលដែលមកដល់ពន្ធនាគារដំបូង និងការដាក់ទណ្ឌកម្មចំពោះការធ្វើខុសបន្តិចបន្តួចពីបទបញ្ជាក្នុងពន្ធនាគារ។



ជនជាប់ឃុំជាអនីតិជន នៅពន្ធនាគារតាខ្មៅ ឆ្នាំ២០១៣

# កុមារីក្នុងពន្ធនាគារ–ក្រុមដែលមិនត្រូវបានគេយកចិត្តទុកដាក់

គួរឲ្យសោកស្តាយ សេចក្តីព្រាងនៃច្បាប់ស្តីពីកុមារទំនាស់ជាមួយច្បាប់ ដែលបានឃើញដោយអង្គការលីកាដូ មិនមានសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់ ទាក់ទងនឹងការពិចារណាទៅលើស្ថានភាពពាក់ព័ន្ធនឹងភេទ នៅពេលសវនាការ ឬ ពេលកាត់ទោសអនីតិជននោះទេ។

លើសពីនេះទៅទៀត សេចក្តីព្រាងច្បាប់នេះ បានត្រឹមតែសរសេរចំណុចទូទៅ បីបួនចំណុចប៉ុណ្ណោះ ទាក់ទងនឹងសេចក្តីត្រូវការជាក់លាក់របស់កុមារីក្នុងពន្ធនាគារ។ ក្រៅពីការបញ្ជាក់អំពីថា អនីតិជនគួរតែទទួលបាននូវការការពារ និងតម្រូវការ ទៅតាមអាយុ ភេទ និងចរិកលក្ខណៈរបស់គាត់ ហើយនិងចែងថា កន្លែងឃុំឃាំងដាច់ដោយឡែកគួរតែមានទៅតាមលក្ខណៈយេនឌ័រ ហើយថា អនីតិជនជាកុមារីគួរតែស្ថិតក្រោមការថែទាំពីសំណាក់មន្ត្រីពន្ធនាគារជានារី សេចក្តីព្រៀងច្បាប់នេះមិនបានស្វែងយល់ឲ្យបានត្រឹមត្រូវ និងដោះស្រាយឲ្យគ្រប់គ្រាន់ចំពោះបញ្ហាប្រឈមជាក់លាក់នានា ដែលកុមារីជួបប្រទះក្នុងពេលជាប់ឃុំឃាំងនោះទេ។

ដោយសារកុមារីក្នុងពន្ធនាគារមានចំនួនតិចតែប៉ុណ្ណោះ វាមិនមានហេតុផលអ្វីដែលត្រូវមិនយកចិត្តទុកដាក់ចំពោះអ្នកទាំងនោះ។ តាមពិត ក្នុងនាមជាក្រុមភាគតិចដែលជាប់នៅក្នុងពន្ធនាគារ ដែលត្រូវបានកសាង និងរៀបចំឡើង សម្រាប់ជនជាប់ឃុំជាបុរសជាចំបងនោះ អ្នកទាំងនោះពិតជាងាយគ្រោះ ហើយត្រូវការការយកចិត្តទុកដាក់ជាពិសេស។ យោងតាមវិធានអប្បបរមានៃបទដ្ឋានអង្គការសហប្រជាជាតិ សម្រាប់ការគ្រប់គ្រងយុត្តិធម៌របស់អនីតិជន (វិធានក្រុងប៉េកាំង) ចែងថា *"ជនល្មើសជានារីវ័យក្មេង ដែលជាប់ឃុំនៅកន្លែងមួយ គួរតែទទួលបាននូវការយកចិត្តទុកដាក់ជាពិសេស ទៅតាមសេចក្តីត្រូវការផ្ទាល់ខ្លួន និងបញ្ហារបស់អ្នកទាំងនោះ។ មិនមានហេតុផលណា ដែលពួកគាត់ទទួលបានការថែទាំយកចិត្តទុកដាក់ ការការពារ ការផ្តល់ជំនួយ ការប្រព្រឹត្តចំពោះ និងការបណ្តុះបណ្តាលតិចជាងជនល្មើសជាបុរសវ័យក្មេងនោះទេ។ ការប្រព្រឹត្តចំពោះដោយស្មើភាពគ្នាគួរតែត្រូវបានធានា។"*[២១]

ជាអកុសល កុមារីនៅក្នុងពន្ធនាគារកម្ពុជា ទំនងជាមិនទទួលបានការថែទាំយកចិត្តទុកដាក់ជាពិសេសនោះទេ។ ដោយពួកគាត់មានចំនួនតិច ពួកគាត់កម្រត្រូវគេដាក់ឲ្យនៅដាច់ដោយឡែកពីជនជាប់ឃុំជានីតិជនណាស់។ ហេតុដូចនេះ មានការយកចិត្តទុកដាក់តិចតួចណាស់ចំពោះតម្រូវការខាងសុខភាពផ្លូវកាយ និងផ្លូវចិត្ត ជាពិសេសរបស់អ្នកទាំងនោះ សេចក្តីត្រូវការផ្នែកអនាម័យរបស់ពួកគាត់ និងស្ថានភាពទូទៅនៃការឃុំខ្លួនពួកគាត់។

*ស្រីមុំ អាយុ ១៧ ឆ្នាំ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល ៦ ខែ ក្នុងឆ្នាំ២០១៣ ពីបទចោរកម្ម។ នៅក្នុងពន្ធនាគារ គាត់មិនមានឱកាសទទួលបានការអប់រំអ្វីនោះទេ ប៉ុន្តែ បែរជាត្រូវគេចាត់តាំងឲ្យធ្វើការនៅរោងដេរជាមួយជនជាប់ឃុំជានីតិជនទៅវិញ។ជាការផ្ទុយនិងចិត្តរបស់គាត់ គាត់ដេរក្រណាត់សម្រាប់ជូតឡាន ដើម្បីលក់យកផលចំណេញសម្រាប់ពន្ធនាគារ។ ស្រីមុំមានបញ្ហាសុខភាពដោយសារហូបអាហារមិនមានជីវជាតិគ្រប់គ្រាន់នៅក្នុងពន្ធនាគារហើយដោយសារស្ថានភាពការងារមិនល្អ។ គាត់វិលមុខជាញឹកញាប់ ប៉ុន្តែទទួលបានតែថ្នាំ បារ៉ាសេតាមុល ពីប៉ុស្តិ៍សុខភាពពន្ធនាគារតែប៉ុណ្ណោះ។ គាត់ជាប់នៅក្នុងបន្ទប់ឃុំឃាំងដែលមានជនជាប់ឃុំជានីតិជនចំនួន ៤៥ រូប ហើយមន្ត្រីពន្ធនាគារដែលយាមពួកគាត់មានទាំងបុរស និងនារី។*

ដូចគ្នាទៅនឹងករណីរបស់អនីតិជនជាបុរសដែរ វាហាក់ដូចជា មានការព្យាយាមតិចតួចណាស់ ក្នុងការការពារកុមារីពីការរំលោភបំពាន ឬក៏ ដើម្បីសិក្សាវាយតម្លៃពីចរិកលក្ខណៈនៃបទល្មើសរបស់ពួកគាត់ ឬក៏ ស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគាត់ នៅពេលដែលធ្វើការកំណត់ថាតើគាត់គួរបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារឬអត់។ ក្នុងចំណោមកុមារី ១៨ រូប ដែលជាប់ឃុំឃាំង ត្រឹមពាក់កណ្តាលខែកញ្ញា ឆ្នាំ២០១៤ នេះ ម្នាក់គត់ត្រូវបានផ្តន្ទាទោស ហើយភាគច្រើននៃអ្នកទាំងនោះជាប់ឃុំឃាំងដោយសារបទល្មើសតូចតាច។

## ករណីសិក្សា

ករណីទី១៖ សុជាតា មានអាយុ ១៧ ឆ្នាំ។ គាត់ត្រូវបានចាប់ខ្លួន កាលពីខែសីហា ឆ្នាំ២០១៤ ពីបទចោរកម្ម ហើយបច្ចុប្បន្នកំពុងជាប់ឃុំឃាំងបណ្តោះអាសន្ន រង់ចាំសវនាការ។ សុជាតា បានប្រាប់អង្គការលីកាដូ ថា គាត់ត្រូវបានទទួលរងការរំលោភសេពសន្ថវៈ ពីសំណាក់ឪពុកមា និងបងប្រុសរបស់នាង តាំងពីអាយុ ៦ឆ្នាំមកម្ល៉េះ ហើយម្តាយរបស់នាងមិនអាចផ្តល់ការថែទាំ យកចិត្តទុកដាក់ឲ្យនាងបាន។ នាងបានចាកចេញពីផ្ទះ ហើយបានទៅរស់នៅជាមួយមិត្តភក្តិ។ នាងមិនដឹងថា តើនាងមានមេធាវី ឬអត់នោះទេ ហើយមិនដឹងថា ពេលណាសវនាការនឹងប្រព្រឹត្តទៅផងដែរ។

ករណីទី២៖ វណ្ណី មានអាយុ ១៧ ឆ្នាំ ហើយមានផ្ទៃពោះ ពេលដែលនាងត្រូវបានចាប់ខ្លួនកាលពីខែមេសា ឆ្នាំ២០១៤ ទាក់ទងនឹងការសង្ស័យប្រព្រឹត្តអំពើចោរកម្ម។ នៅប៉ុស្តិ៍នគរបាល មន្ត្រីនគរបាលបានទះកំផ្លៀងនាងជាច្រើនដៃ វាយនាង និងគំរាមរំលោភសេពសន្ថវៈ និងគំរាមសម្លាប់នាង ប្រសិនបើនាងមិនសារភាព។ វណ្ណី បានជាប់ឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការ អស់រយៈពេល ៥ ខែ។ ក្រោយមក នាងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំ កន្លះ។

[២១] វិធានអប្បបរមានៃបទដ្ឋានអង្គការសហប្រជាជាតិ សម្រាប់ការគ្រប់គ្រងយុត្តិធម៌របស់អនីតិជន ("វិធានក្រុងប៉េកាំង") វិធាន ២៦.៤

ដូចបានកត់សម្គាល់ដោយអង្គការលីកាដូ នៅក្នុងពន្ធនាគារនៅកម្ពុជា ឱកាសទទួលបានការបណ្តុះបណ្តាល ហាក់ដូចជាសម្រាប់ជនជាប់ឃុំជាបុរសជាសំខាន់ ហើយជនជាប់ឃុំជានារី រួមទាំងកុមារីផងដែរ ជារឿយៗ មិនទទួលបានការបណ្តុះបណ្តាលសមស្រប ដែលជាការជួយពួកគាត់ ក្នុងការរកការងារធ្វើក្នុងពេលអនាគតដូចបុរសនោះទេ។ នៅក្នុងពន្ធនាគារខ្លះ នារី និងកុមារី មិនបានទទួលការបណ្តុះបណ្តាលអ្វីទាល់តែសោះ។

នាទិវានារីអន្តរជាតិឆ្នាំ២០១៤ អង្គការលីកាដូ បានអំពាវនាវដល់អាជ្ញាធរពន្ធនាគារ ឲ្យផ្តល់ជនជាប់ឃុំជានារី ជាពិសេសជនជាប់ឃុំជានារី ជាអនីតិជន នូវឱកាសស្តានីតិសម្បទាសំបូរបែប ក្នុងការកសាងទំនុកដល់អ្នកទាំងនោះ និងផ្តល់នូវជំនាញសមស្រប ដើម្បីជួយឲ្យពួកគាត់ទទួលបានការងារសមរម្យនៅពេលដែលត្រូវបានដោះលែង។[២២]

# ជនជាប់ឃុំជានារី

ជាទូទៅ នារីជាប់ក្នុងពន្ធនាគារនៅកម្ពុជា ប្រឈមនឹងការរំលោភបំពានសិទ្ធិដូចជនជាប់ឃុំជាបុរសដែរ ហើយមានការយកចិត្តទុកដាក់តិចតួចណាស់ ចំពោះសេចក្តីត្រូវការផ្ទាល់ខ្លួនរបស់អ្នកទាំងនោះ។ ស្ថានភាពគ្រួសាររបស់អ្នកទាំងនោះ រួមទាំងការទទួលខុសត្រូវក្នុងការថែទាំកូន មិនត្រូវបានយកមកពិចារណានោះទេ នាពេលកាត់ទោស។

យោងតាមលទ្ធផលនៃការស្ទាបស្ទង់នាពេលថ្មីៗនេះ ជាមួយជនជាប់ឃុំ ៤៧៩ នាក់ អង្គការលីកាដូ បានរកឃើញថា ជាងមួយភាគបី ក្នុងចំណោមអ្នកទាំងនោះ ត្រូវបានចោទប្រកាន់ ឬ កាត់ទោសពីបទល្មើស ទាក់ទងនឹងគ្រឿងញៀន ខណៈដែរ ៣១ ភាគរយ ផ្សេងទៀត បានជាប់ក្នុងពន្ធនាគារ ដោយសារបទល្មើសតូចតាច ដូចជាលួច ទទួលផលចោរកម្ម រំលោភសេចក្តីទុកចិត្ត បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងនេសាទខុសច្បាប់។ គិតត្រឹមពាក់កណ្តាល ខែកញ្ញា ឆ្នាំ២០១៤ ៧០ភាគរយនៃនារីក្នុងពន្ធនាគារ ស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ រួមទាំងអ្នករង់ចាំបណ្តឹងឧទ្ធរណ៍ ឬ សាលក្រមស្ថាពរ (តុលាការកំពូល)។ បើទោះជាអង្គការលីកាដូ មិនមានស្ថិតិអំពីចំនួននារីដែលមានការទទួលខុសត្រូវថែទាំកូនក៏ដោយ តួលេខទំនងជាខ្ពស់។

បច្ចុប្បន្ននេះ ជនជាប់ឃុំជានារីមានចំនួនប្រមាណ ៨ ភាគរយ នៃចំនួនជនជាប់ឃុំសរុប ប៉ុន្តែមិនមានស្ថាប័ន ឬ អង្គភាពដាច់ដោយឡែកសម្រាប់តែស្ត្រីនោះទេ។ កន្លែងដាក់ជនជាប់ឃុំជានារីដែលធំជាងគេ គឺមណ្ឌលអប់រំកែប្រែទី២ នៅរាជធានីភ្នំពេញ ដែលគិតត្រឹមពាក់កណ្តាលខែកញ្ញា ឆ្នាំ២០១៤ មានជនជាប់ឃុំជានារីចំនួន ៤៣២ នាក់ និងអនីតិជនជាបុរសចំនួន ១៥៤ នាក់។ នៅក្នុងមណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី៣ និងមណ្ឌលអប់រំកែប្រែទី៤ មិនមានជនជាប់ឃុំឃាំងជានារីនោះទេ។

នៅក្នុងពន្ធនាគារខេត្តទាំងអស់ និងកន្លែងឃុំឃាំងរបស់នគបាល (PJ) នៅរាជធានីភ្នំពេញ នារីត្រូវបានដាក់ឲ្យនៅក្នុងបន្ទប់ដាច់ដោយឡែកពីបុរស ប៉ុន្តែមិនជានិច្ចជាកាល ស្ថិតនៅក្នុងអគារដាច់ដោយឡែកពីគ្នានោះទេ។ ជាទូទៅ ពន្ធនាគារកម្ពុជាត្រូវបានរៀបចំឡើង ដើម្បីតែបម្រើសេចក្តីត្រូវការរបស់ជនជាប់ឃុំបុរសជាចំបង ជាពិសេស ទាក់ទងនឹងសកម្មភាពលំហែកំសាន្ត និងឱកាសទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដូចដែលបានកត់សម្គាល់កន្លងមក ការមិនទទួលបានឱកាសបែបនេះ ជាទូទៅស្មើនឹងការមិនទទួលបានពេលវេលាចេញក្រៅបន្ទប់គ្រប់គ្រាន់ និងអត្ថប្រយោជន៍ផ្សេងទៀត។ ជាធម្មតា ស្ត្រីក៏ទំនងជាមិនមានធនធានថវិកាដូចបុរស ក្នុងការសូកប៉ាន់មន្ត្រីពន្ធនាគារ ដើម្បីទទួលបាន ‘សិទ្ធិពិសេស’ បែបនេះដែរ។



ជនជាប់ឃុំជាស្ត្រី នៅពន្ធនាគារខេត្តកំពង់ឆ្នាំង ឆ្នាំ២០០៩

នៅក្នុងពន្ធនាគារមួយ មន្ត្រីពន្ធនាគារបានទទួលស្គាល់នាពេលថ្មីៗនេះ ថាមិនមានឱកាសការងារ ឬ ឱកាសបណ្តុះបណ្តាលទាល់តែសោះសម្រាប់នារី។ ខណៈដែល ជនជាប់ឃុំជាបុរស ដែលត្រូវធ្វើការ ត្រូវបានអនុញ្ញាតឲ្យចេញក្រៅបន្ទប់ឃុំឃាំង យ៉ាងតិច ៥ ម៉ោងក្នុងមួយថ្ងៃ នារីម្នាក់ដែលជាប់នៅក្នុងពន្ធនាគារនេះ បានប្រាប់អង្គការលីកាដូ ថា ដោយសារនារីមិនអាចចូលរួមក្នុងសកម្មភាពខាងក្រៅទាំងនេះបាន នារីត្រូវបានអនុញ្ញាតឲ្យចេញក្រៅបន្ទប់ឃុំឃាំងត្រឹមតែ ៣០ នាទី ប៉ុណ្ណោះ ក្នុងមួយថ្ងៃ។ គួរឲ្យកត់សម្គាល់ផងដែរថា ពេញមួយឆ្នាំ២០១៣ ចំនួនជនជាប់ឃុំជានារីជាមធ្យម មានចំនួន ៨

[២២] http://www.licadho-cambodia.org/pressrelease.php?perm=340

ភាគរយ ប៉ុន្តែយោងតាមស្ថិតិរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្នុងចំណោមជនជាប់ឃុំ ១,៦៤៣ នាក់ ដែលទទួលបានកម្មវិធីអប់រំ ឬបណ្តុះបណ្តាលវិជ្ជាជីវៈ នារីមានតែ ៥.៦ ភាគរយប៉ុណ្ណោះ។[២៣]

អង្គការលីកាដូ បានសម្ភាសន៍អតីតជនជាប់ឃុំជានារី ដែលបានអធិប្បាយអំពីផលប៉ះពាល់នៃការជាប់ឃុំឃាំង មកលើខ្លួនរបស់គាត់ផ្ទាល់ និងមកលើគ្រួសាររបស់គាត់។ ចំពោះកុមារខ្លះ ការជាប់ឃុំឃាំងរបស់ម្តាយ អាចបណ្តាលឲ្យមានផលប៉ះពាល់ស៊ីជម្រៅ និងយូរអង្វែង ចំពោះអារម្មណ៍ និងស្ថានភាពក្នុងសង្គមរបស់អ្នកទាំងនោះ។ អង្គការលីកាដូបានជួបជាមួយនារីជាម្តាយជាច្រើននាក់ ដែលបានប្រាប់ថា កូនៗរបស់ពួកគាត់ឈប់រៀន នៅពេលដែលម្តាយជាប់ពន្ធនាគារជាចំបង ដោយសារតែបញ្ហាថវិកា។

*"ខ្ញុំព្រួយបារម្ភចំពោះកូនៗខ្ញុំយ៉ាងខ្លាំង...មុនពេលខ្ញុំត្រូវបានចាប់ខ្លួន ពួកគាត់ដូចកុមារដ៏ទៀតដែរ ប៉ុន្តែឥឡូវ ពួកគាត់គិត និងប្រព្រឹត្តដូចនីតិជនអញ្ចឹង។ វាហាក់ដូចជា ពួកគាត់បានបាត់បង់វ័យកុមារភាពរបស់ពួកគាត់ទៅហើយ។"*

ប្រសិនបើម្តាយរបស់អ្នកទាំងនោះ ជាប់ឃុំនៅក្នុងពន្ធនាគារដែលស្ថិតនៅឆ្ងាយពីផ្ទះ ករណី ទូទៅទាក់ទងនឹងអ្នកជួញគ្រឿងញៀន វាពិតជាពិបាកខ្លាំងណាស់ សម្រាប់កុមារទាំងនោះ ទៅសួរសុខទុក្ខម្តាយរបស់ពួកគាត់ជាទៀងទាត់ ឬ ក៏មិនបានទៅសោះ។ ស្លាកស្នាមអាក្រក់ក្នុងសង្គម មានចំពោះស្ត្រីដែលជាប់ឃុំក៏ទំនងជា មានខ្លាំងជាងចំពោះបុរសផងដែរ។ កត្តានេះអាចនាំឲ្យមានហានិភ័យខ្ពស់ដែលកូនៗរបស់គាត់ ក៏នឹងទទួលរងនូវបញ្ហានេះដែរ។

ប៉ុន្តែកត្តាទាំងនេះ ជាធម្មតា មិនត្រូវបានយកទៅពិចារណានោះទេ នៅពេលវិនិច្ឆ័យថា តើនារីម្នាក់ត្រូវជាប់ក្នុងពន្ធនាគារ ឬអត់។ អង្គការលីកាដូ ជឿថា នារីដែលមានកូន មិនគួរដាក់ឲ្យជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការនោះទេ លែងលែងតែចាំបាច់បំផុត។ អង្គការលីកាដូក៏ជឿជាក់ផងដែរថាជម្រើសផ្សេងៗសម្រាប់ការដាក់ទោសមិនជាប់ឃុំ គួរតែយកមកពិចារណាជានិច្ច នៅពេលកាត់ទោសនារីជាម្តាយ ឬ ជាអាណាព្យាបាលរបស់កុមារ ដោយពិចារណាទៅលើផលប៉ះពាល់ដែលអាចកើតមានចំពោះកូនៗរបស់គាត់។ ជាអកុសល នៅកម្ពុជា សូម្បីតែនារីមានផ្ទៃពោះ ហើយនិងនារីដែលទើបសម្រាលបុត្ររួច ក៏ត្រូវចាប់បញ្ជូនមកឃុំឃាំងនៅពន្ធនាគារដែរ ដោយមិនពិចារណាទៅលើសារតា និងស្ថានភាពគ្រួសារបស់អ្នកទាំងនោះឡើយ។

[២៣] កិច្ចប្រជុំប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធនាគារ ស្តីពីសមិទ្ធិផលសម្រេចបានក្នុង ឆ្នាំ២០១៣ និងការកំណត់ទិសដៅសម្រាប់ឆ្នាំ២០១៤ (ថ្ងៃទី២-៣ ឆ្នាំ២០១៤)



ក្មេងប្រុស និងម្តាយ ក្នុងទិវាសិទ្ធិនារីអន្តរជាតិ នៅមណ្ឌលអប់រំកែប្រែទី២ ឆ្នាំ២០១១

# កុមារក្នុងពន្ធនាគារ-លូតលាស់ក្នុងពន្ធនាគារនៅកម្ពុជា

ត្រឹមខែតុលា ឆ្នាំ២០១៤ ក្នុងចំណោមពន្ធនាគារដែលអង្គការលីកាដូ ធ្វើការឃ្លាំមើល[២៤] មានកុមារចំនួន ៣៥ នាក់ អាយុចន្លោះពី ១ ខែ រហូតដល់ ៣ ឆ្នាំកន្លះ កំពុងរស់នៅជាមួយម្តាយ ក្នុងពន្ធនាគារនៅកម្ពុជា។ ប្រមាណពាក់កណ្តាលក្នុងចំណោមពួកគេ បានចាប់កំណើតនៅក្នុងពន្ធនាគារ ហើយមិនស្គាល់រស់ជាតិជីវិតខាងក្រៅរបងពន្ធនាគារនោះឡើយ។ បើទោះជាមានការសិក្សាលម្អិតតិចតួចអំពីផលប៉ះពាល់រយៈពេលយូរ ដោយសារការរស់នៅក្នុងពន្ធនាគារចំពោះការលូតលាស់របស់កុមារក៏ដោយ ក៏ពិតច្បាស់ថា ចំពោះកុមារមួយចំនួន បឋមវ័យក្នុងពន្ធនាគារអាចមាន ផលប៉ះពាល់យ៉ាងខ្លាំងទៅលើការលូតលាស់ផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ ហើយការប៉ះពាល់ទាំងនោះ គឺគ្មានការលើកលែងនោះទេ។

ចាប់តាំងពីការដាក់ឲ្យប្រើប្រាស់ច្បាប់ស្តីពីពន្ធនាគារ ខែធ្នូ ឆ្នាំ២០១១ ដែលបានកាត់បន្ថយកម្រិតអាយុរបស់កុមារ ដែលត្រូវអនុញ្ញាតឲ្យរស់នៅក្នុងពន្ធនាគារ ពី ៦ ឆ្នាំ មកត្រឹម ៣ ឆ្នាំ មក ចំនួនកុមាររស់នៅក្នុងពន្ធនាគារកម្ពុជា បានថយចុះជាង ៥០ ភាគរយ។ ក្នុងខែបន្ទាប់ពីការអនុម័តច្បាប់នេះ មានកុមារចំនួន ៧១ នាក់ នៅក្នុងពន្ធនាគារចំនួន ១៧ អាយុលើពី ៣ ឆ្នាំ ហើយជិត ៣ ឆ្នាំ ក្រោយមកមានកុមារត្រឹមតែ ៦ នាក់ ប៉ុណ្ណោះ ដែលមានអាយុលើស ៣ ឆ្នាំ រស់នៅក្នុងពន្ធនាគារ។

អង្គការលីកាដូ ស្វាគមន៍ចំពោះការកែប្រែច្បាប់កាលពីឆ្នាំ ២០១១ ហើយមានកម្លាំងចិត្តយ៉ាងខ្លាំង ចំពោះការកាត់បន្ថយដ៏ច្រើននៃចំនួនកុមាររស់នៅជាមួយម្តាយ ក្នុងពន្ធនាគារ។ ក៏ប៉ុន្តែតួលេខនេះភាគច្រើន ជាលទ្ធផលនៃការបន្តកិច្ចខិតខំប្រឹងប្រែង របស់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការជាមួយកុមារ និងនារីក្នុងពន្ធនាគារ រួមទាំងអង្គការលីកាដូផងដែរ ហើយគួរឲ្យសោកស្តាយ ជាក់ស្តែង មានតិចណាស់ ជាលទ្ធផលនៃការបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ភាគីអគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្ថាប័នដែលគួរទទួលខុសត្រូវដឹកនាំ ក្នុងការវាយតម្លៃចំពោះការថែទាំសមស្រប និងការដកហូត និងប្តូរទីកន្លែងរស់នៅរបស់កុមារចេញពីពន្ធនាគារ។

គួរសោកស្តាយ ប្រព័ន្ធពន្ធនាគារកម្ពុជា មិនមានសមត្ថភាពក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការជាមូលដ្ឋានភាគច្រើន ដូចជា ការអប់រំ អាហារូបត្ថម្ភសមស្រប ការថែទាំសុខភាព និងការប្រាស្រ័យទាក់ទងក្នុងសង្គមនោះទេ។ កុមារដែលរស់ដាច់ដោយឡែកពីពិភពខាងក្រៅ ហើយទទួលទានអាហារមិនគ្រប់គ្រាន់ ជារឿយៗជួបប្រទះបញ្ហាធ្ងន់ធ្ងរ ទាក់ទងនឹងការលូតលាស់របស់កុមារ ហើយមានការលំបាកក្នុងការសម្របខ្លួន ចូលក្នុងសង្គម ពេលដែលអ្នកទាំងនោះចេញពីពន្ធនាគារ។ អង្គការលីកាដូក៏បានដឹងអំពីករណីដែលកុមារវ័យក្មេងទទួលរងការវាយដំ នៅក្នុងពន្ធនាគារ ដោយមិនមានការអន្តរាគមន៍ ឬវិធានការការពារពីសំណាក់អាជ្ញាធរផងដែរ។

ការសម្រេចអនុញ្ញាតឲ្យកុមារអាយុក្រោម ៣ ឆ្នាំ រស់នៅជាមួយម្តាយក្នុងពន្ធនាគារ គួរតែអាស្រ័យទៅលើការវាយតម្លៃឲ្យបានពេញលេញទៅស្ថានភាពផ្ទាល់ខ្លួន និងអាស្រ័យលើឧត្តមប្រយោជន៍របស់កុមារ។[២៥] ការវាយតម្លៃ គួរតែធ្វើការពិចារណាទៅលើ អាយុ ភេទ ការធំធាត់ សុខភាព និងទំនាក់ទំនងជាមួយម្តាយ ហើយនិងជម្រើសសមរម្យដែលមាននៅខាងក្រៅ និងផលប៉ះពាល់ ដែលទំនងកើនមានចំពោះសុខភាព និងការលូតលាស់របស់កុមារដោយសារការរស់នៅក្នុងពន្ធនាគារ។ ការវាយតម្លៃស្រដៀងគ្នានេះគួរតែធ្វើឡើងផងដែរ ពេលដែលកុមារបានចាប់កំណើត ក្នុងពេលម្តាយជាប់ពន្ធនាគារ ដើម្បីសម្រេច ថាតើកុមារគួរតែស្នាក់នៅក្នុងពន្ធនាគារ ឬអត់ ហើយរយៈពេលប៉ុន្មាន ឬក៏ មិនគួរស្នាក់នៅទាល់តែសោះតែម្តង។ តាមទស្សនៈរបស់អង្គការលីកាដូ ការវាយតម្លៃនេះត្រូវតែធ្វើជាបន្តបន្ទាប់ ដោយសារតែការប្រែប្រួលស្ថានភាពក្នុងពន្ធនាគារ និងការប្រែប្រួលនៃសេចក្តីត្រូវការសម្រាប់លូតលាស់របស់កុមារ។

នៅពេលដែលកុមារមានអាយុ ៣ ឆ្នាំ ការដាក់ឲ្យនៅដាច់ដោយឡែក ត្រូវតែធ្វើឡើង ដោយមានលក្ខណៈសមស្រប មានការជម្រាបឲ្យដឹងច្បាស់លាស់ និងមានការប្រុងប្រយ័ត្នឲ្យបានត្រឹមត្រូវ ហើយការដាក់ឲ្យនៅដាច់ដោយឡែកនេះ អាចធ្វើទៅបាន លុះត្រាតែមានការរៀបចំចាត់ចែងការថែទាំកុមារនៅខាងក្រៅបានត្រឹមត្រូវ។

គួរឲ្យសោកស្តាយ នៅកម្ពុជា វាហាក់ដូចជាមិនមានប្រព័ន្ធ និងគោលការណ៍ណែនាំច្បាស់លាស់ ដើម្បីកំណត់ឲ្យដឹងថា ពេលណាជាពេលវេលាសមស្របសម្រាប់កុមារ រស់នៅក្នុងពន្ធនាគារ ហើយ ត្រូវយកកុមារចេញពីម្តាយរបស់ពួកគាត់ដោយរបៀបណា ពេលដែលកុមារមានអាយុ៣ឆ្នាំ។ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ អង្គការមិនមែនរដ្ឋាភិបាល ជារឿយៗ នៅតែដើរតួនាទីដឹកនាំ ពាក់ព័ន្ធនឹងការវាយតម្លៃលើករណីរបស់កុមារម្នាក់ៗ ហើយនិងស្វែងរកកន្លែងខាងក្រៅដែលសមស្របសម្រាប់កុមារ។

ក្នុងឆ្នាំ២០១៣ អង្គការលីកាដូ បានទទួលព័ត៌មានថា នៅក្នុងពន្ធនាគារមួយ ដែលពេលនោះ មានកុមារច្រើននាក់ មានអាយុលើស ៣ ឆ្នាំ រស់នៅទីនោះ ម្តាយរបស់កុមារត្រូវគេឲ្យពេលវេលាត្រឹមតែ ១ សប្តាហ៍ តែប៉ុណ្ណោះ ដើម្បីស្វែងរកកន្លែងរស់នៅផ្សេងសម្រាប់កូនរបស់អ្នកទាំងនោះ។ នាយកពន្ធនាគារដ៏ទៃទៀតក៏បានពន្យល់ប្រាប់អង្គការលីកាដូថា ពួកគាត់មិនមានសមត្ថភាពក្នុងការធានាថា ការដកហូតកុមារចេញពីម្តាយក្នុងពន្ធនាគារ ប្រព្រឹត្តទៅបានត្រឹមត្រូវនោះទេ ហើយថា ពួកគាត់មិនបានទទួលជំនួយអ្វីសោះពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ដើម្បីឆ្លើយតប ចំពោះស្ថានភាពកុមារដែលរស់នៅក្នុងពន្ធនាគារ ជាមួយម្តាយ អង្គការលីកាដូកំពុងបន្តចេញផ្សាយនូវករណីសិក្សាជាបន្តបន្ទាប់ ដែលធ្វើការសិក្សាវាយតម្លៃអំពីផលប៉ះពាល់ដែលមាន ចំពោះកុមារ ដែលលូតលាស់នៅក្នុងពន្ធនាគារនៅកម្ពុជា

[២៤] នៅក្នុងពន្ធនាគារកម្ពុជា មិនមានកុមាររស់នៅជាមួយឪពុក ឬ អាណាព្យាបាលផ្សេងទៀត នោះទេ។
[២៥] វិធានក្រុងបាងកក ៤៩ និង ៥២ និងមាត្រា ៣ (១) នៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ។

រួមទាំងអនុសាសន៍មួយចំនួន ជូនចំពោះអាជ្ញាធរកម្ពុជា អំពីរបៀបក្នុងការធានាថា សិទ្ធិរបស់កុមារ និងម្ដាយរបស់អ្នកទាំងនោះ ត្រូវបានគោរពពេញលេញ។ ករណីសិក្សាទី១ បង្ហាញពីសាច់រឿងរបស់ សុគន្ធ[២៦] ដែលបានចាប់កំណើត និងត្រូវបានចិញ្ចឹមបីបាច់ក្នុងពន្ធនាគារ រហូតដល់គាត់អាយុជិត ៧ ឆ្នាំ។ សាច់រឿងរបស់សុគន្ធបានបង្ហាញថា ប្រព័ន្ធពន្ធនាគារនាពេលបច្ចុប្បន្ន មិនមានសមត្ថភាពក្នុងការផ្ដល់ជូន និងការពារកុមារក្នុងពន្ធនាគារនោះទេ។ ករណីសិក្សាទី២ បានសិក្សាវាយតម្លៃអំពីបទពិសោធន៍របស់ ដារ៉ា ដែលបានរស់នៅជាមួយម្ដាយ ក្នុងពន្ធនាគារតាខ្មៅ តាំងពីចាប់កំណើត រហូតដល់ដារ៉ា មានអាយុជាង ៣ ឆ្នាំ កន្លះ។

# អំពើទារុណកម្ម និងការធ្វើបាប

កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ ក្នុងអំឡុងពេលប្រជុំជាមួយលោក សុរិយា ស៊ូប៊ែឌី អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ឯកឧត្តម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ថា អាជ្ញាធរកម្ពុជានឹងមិនអត់អោនចំពោះការធ្វើទារុណកម្មក្នុងពេលឃុំឃាំងនោះទេ។

ប្រាំមួយ ថ្ងៃ ក្រោយមក អង្គការលីកាដូ បានចេញផ្សាយរបាយការណ៍មួយ[២៧] ដើម្បីប្រារព្ធទិវាអន្តរជាតិ គាំទ្រជនរងគ្រោះដោយអំពើទារុណកម្ម ថ្ងៃទី២៦ ខែមិថុនា ដោយយោងទៅលើការចោទប្រកាន់អំពីការរំលោភបំពានជាង ៥០០ ករណី ដែលប្រព្រឹត្តដោយមន្ត្រីរដ្ឋាភិបាល នៅប៉ុស្ដិ៍នគរបាល និងនៅពន្ធនាគារ ចាប់តាំងពីខែមករា ឆ្នាំ២០០៨ មក ដោយរួមទាំងការរំលោភបំពានលើនារី និងអនីតិជន ហើយនិងអ្នកដែលជួបបញ្ហាផ្លូវចិត្តផងដែរ។ របាយការណ៍នោះបង្ហាញថា មិនមានការផ្លាស់ប្ដូរជាក់ស្ដែងណាមួយ ទាក់ទងនឹងប្រភេទភាពញឹកញាប់ និងភាពធ្ងន់ធ្ងរនៃការរំលោភបំពាន ដែលត្រូវបានរាយការណ៍ប៉ុន្មានឆ្នាំចុងក្រោយនេះ នោះទេ។

ស្ត្រីមានផ្ទៃពោះម្នាក់បាននិយាយថា៖ "...មន្ត្រីនគរបាលបានអានលិខិតសារភាព ប៉ុន្តែមិនមែនជាពាក្យសម្ដីរបស់ខ្ញុំទេ។ ខ្ញុំក៏បានបដិសេធ មិនផ្ដិតមេដៃលើលិខិតសារភាពនោះទេ។ រំពេចនោះ មន្ត្រីនគរបាល បានយករំពាត់មកវាយស្មា និងខ្នងរបស់ខ្ញុំ.... បើទោះជាខ្ញុំប្រាប់គាត់ថា ខ្ញុំមានផ្ទៃពោះក៏ដោយ...។"

ទិន្នន័យរបស់អង្គការលីកាដូ បង្ហាញថា ភាគច្រើននៃអ្នកដែលបានរាយការណ៍អំពី ភាពឃោឃៅរបស់នគរបាល និងមន្ត្រីពន្ធនាគារ បានរៀបរាប់ថា ខ្លួនត្រូវបានគេ វាយ ទាត់ ធាក់ ទះកំផ្លៀង ដាល់ ហើយជាញឹកញាប់ រហូតដល់ពួកគាត់ ហូរឈាម ឬ បាត់បង់



ជញ្ជាំងពន្ធនាគារ ខេត្តកំពង់ឆ្នាំង ឆ្នាំ២០០៩

[២៦] http://www.licadho-cambodia.org/reports/files/182LICADHOReportChildrenBehindBars2013-English.pdf
[២៧] សូមមើល http://www.licadho-cambodia.org/reports.php?perm=195

សន្លប់។ អ្នកទាំងនោះ ជាច្រើននាក់ត្រូវបានគេវាយគ្រប់កន្លែង លើខ្លួនរបស់ពួកគាត់ ព្រមទាំងក្បាល និងកផងដែរ។ អ្នកខ្លះត្រូវបានគេរុញក្បាលរបស់គាត់ផ្ទប់នឹងជញ្ជាំងក៏មានដែរ។ វត្ថុដែលត្រូវបានប្រើប្រាស់ក្នុង ពេលវាយដំ មានដូចជា កាំភ្លើង ដំបងឈើ ដែក ដំបងឆក់ វិទ្យុទាក់ទង ខ្នោះដៃ ច្រវ៉ាក់ ខ្សែពួរ ខ្សែភ្លើងអគ្គិសនី អិដ្ឋ និងខ្សែក្រវ៉ាត់។ ជនជាប់ឃុំខ្លះត្រូវបានគេយកថង់ប្លាស្ទិក និងវត្ថុផ្សេងទៀត គ្របមុខ ក្នុងពេលវាយដំ។ ភាគច្រើននៃអ្នកដែលបានផ្តល់សម្ភាសន៍ប្រាប់ថា អ្នកទាំងនោះត្រូវបានគេវាយ ដើម្បីបង្ខំឲ្យពួកគាត់សារភាព ឬ បង់ប្រាក់ទៅឲ្យអ្នក ដែលបំពានលើអ្នកទាំងនោះ។ ចំពោះអ្នកដែលមិនអាចអានអក្សរខ្មែរបានត្រូវ បង្ខំឲ្យផ្តិតមេដៃលើលិខិតសារភាព ដែលអ្នកទាំងនោះមិនយល់ទៀតផង។

អង្គការលីកាដូក៏ទទួលបានការរាយការណ៍ ទាក់ទងនឹងជនជាប់ឃុំត្រូវបានគេទាញសក់ទម្លាក់មកលើដី បង្ខំឲ្យឈរជើងមួយរយៈពេលយូរ ហើយមន្ត្រីពន្ធនាគារមួយចំនួនឈរជាន់លើខ្លួន និងមុខ បញ្ចូលវត្ថុអ្វីមួយចូលមាត់ អុជនឹងបារី លុតជង្គង់រយៈពេលយូរ រួមទាំងនៅក្រោមកំដៅព្រះអាទិត្យ ច្របាច់ក និងការប្រើប្រាស់ឧបករណ៍ឆក់ផ្សេងទៀត សម្រាប់ការធ្វើទារុណកម្មផងដែរ។

ពួកគាត់ជាច្រើននាក់បានប្រាប់ពីការរងការគំរាមកំហែង ឬក៏ គ្រួសាររបស់ពួកគាត់រងការគំរាមកំហែង ដោយនគរបាល ឬ មន្ត្រីពន្ធនាគារ ជាទូទៅ ដើម្បីជំរិតយកប្រាក់ ឬ បង្ខំឲ្យសារភាព។ អ្នកខ្លះទទួលរងការគំរាមសម្លាប់ ឬក៏ ការគំរាមបំពានផ្លូវភេទ ហើយអ្នកផ្សេងទៀត ត្រូវគេយកកាំភ្លើងភ្ជង់ក្បាល ឬ គំរាមឆក់នឹងដំបងឆក់។ ការគំរាមដកក្រចកក៏ត្រូវបានលើកឡើង ផងដែរ។ អ្នកទាំងនោះជាច្រើននាក់ក៏បាននិយាយថា ពួកគាត់ត្រូវបានគេមិនផ្តល់អាហារ ឬ ទឹក នៅកន្លែងឃុំឃាំងរបស់នគរបាលនោះទេ។

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប កាលពីឆ្នាំ២០០៧។ ក្នុងចំណោមចំណុចឯទៀត ពិធីសារនេះតម្រូវឲ្យ រដ្ឋភាគីទាំងឡាយ បង្កើតយន្តការបង្ការថ្នាក់ជាតិដែលឯករាជ្យ មួយ (NPM) ក្នុងរយៈពេលមួយឆ្នាំ នៃការផ្តល់សច្ចាប័ន។ ប្រទេសកម្ពុជា មិនទាន់បានបង្កើតស្ថាប័នបែបនេះ

## ថ្នាក់ដឹកនាំក្នុងបន្ទប់ឃុំឃាំង

រចនាសម្ព័ន្ធគ្រប់គ្រង ក្នុងបន្ទប់ឃុំឃាំង ដែលលក្ខណៈមិនផ្លូវការ និងមិនមានការគ្រប់គ្រង រួមមាន មេបន្ទប់ និងមេបន្ទប់រង។ អ្នកទាំងនោះត្រូវបានជ្រើសតាំង ដោយសារភក្តីភាព ចំពោះថ្នាក់គ្រប់គ្រងពន្ធនាគារ ហើយពួកគេជាអ្នកបង្កើត និងអនុវត្តវិន័យពន្ធនាគារដ៏មានប្រសិទ្ធិភាព ហើយ អនុវត្តប្រព័ន្ធស្រដៀងគ្នានៃការគ្រប់គ្រងពន្ធនាគារ ដែលយកវិន័យរបស់ពួកគាត់ ជាជាងវិន័យ និងនីតិវិធី ផ្លូវការ។ ហេតុដូចនេះ មេបន្ទប់ និងសមាជិកនៃគណៈកម្មាធិការគ្រប់គ្រង ក្នុងបន្ទប់ប្រព្រឹត្តទៅដោយមាននិទណ្ឌភាព ហើយជាទម្លាប់ វាយដំជនជាប់ឃុំថ្មី ជាការ "ស្វាគមន៍" ចំពោះជីវិតក្នុងពន្ធនាគារ ហើយអាចប្រព្រឹត្តអំពើហិង្សាដល់ជនជាប់ឃុំដ៏ទៃទៀត ក្នុងនាមថាដាក់វិន័យ។ ការវាយដំបែបនេះ ជារឿងៗកើតឡើង ហើយឃោឃៅ ហើយអ្នកដែលក្លាយជនរងគ្រោះ មិនមានមធ្យោបាយក្នុងការប្តឹងផ្តល់នោះទេ។



ពន្ធនាគារ ខេត្តឧត្តរមានជ័យ ឆ្នាំ២០១៤

ដែលមានគោលបំណងចំបង ដើម្បីឃ្លាំមើល និងទប់ស្កាត់អំពើទារុណកម្ម និងការធ្វើបាបផ្សេងៗនៅក្នុងទីកន្លែងឃុំឃាំងនៅឡើយ។ ផ្ទុយទៅវិញ គណៈកម្មាធិការអន្តរក្រសួង ដែលមាន សមាសភាពមន្ត្រីរាជរដ្ឋាភិបាល ផ្សេងៗ ត្រូវបានបង្កើតឡើង ក្នុងឆ្នាំ២០០៩។ គណៈកម្មាធិការ នេះ មិនឯករាជ្យ ហើយមិនមានប្រសិទ្ធិភាពទៀត។

បន្ថែមទៅលើការរំលោភបំពានដោយមន្ត្រីរាជរដ្ឋាភិបាលនៅប៉ុស្តិ៍នគរបាល និងពន្ធនាគារ អង្គការលីកាដូបានកត់ត្រាជាទៀងទាត់នូវការរំលោភបំពានដោយនគរបាល និងកងកម្លាំង សន្តិសុខរបស់រដ្ឋដទៃទៀត នៅកន្លែងចាប់ខ្លួន និងកន្លែងឆ្លងកាត់មុនពេលទៅដល់ប៉ុស្តិ៍នគរបាល។ ពេលដល់ពន្ធនាគារ ក៏អាចមានរំលោភបំពានពីសំណាក់ជនជាប់ឃុំដូចគ្នាផងដែរ ជាធម្មតាក្រោបមបញ្ជាផ្ទាល់ ឬក្រោមការយល់ព្រម ពីអាជ្ញាធរពន្ធនាគារ។

លើសពីនេះទៅទៀត អង្គការលីកាដូជឿជាក់ថា ស្ថានភាពនៃការឃុំឃាំងនៅកន្លែងឃុំឃាំងមួយចំនួន រួមទាំងការបដិសេធក្នុងការទទួលបានការព្យាបាលត្រឹមត្រូវ ប្រហែលជាដូចគ្នាទៅនឹងការប្រព្រឹត្ត ដែលមានលក្ខណៈដែលឃោឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ផងដែរ។ ក្តីបារម្ភជាខ្លាំងគឺទាក់ទងនឹងការរាយការណ៍ថា អ្នកដែលមានបញ្ហាផ្លូវចិត្ត ប្រឈមនឹងហានិភ័យដោយការរំលោភបំពាននៅក្នុងពន្ធនាគារ និងកន្លែងឃុំឃាំងរបស់នគរបាល។

ការឆ្លើយតបរបស់អាជ្ញាធរកម្ពុជាទៅនឹងរបាយការណ៍របស់អង្គការលីកាដូ មិនអាចទទួលយកបានទេ។ ឯកឧត្តម គុយ ប៊ុនសន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ បានអះអាងថា មិនមានការធ្វើទារុណកម្ម កើតមាននៅក្នុងពន្ធនាគារណាមួយនៅកម្ពុជានោះទេ តាំងពីអតីតកាល រហូតមកដល់ពេលបច្ចុប្បន្ន ខណៈដែល លោក ខៀវ សុភ័ក្ត្រ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលបានកំពុងចាត់វិធានការណ៍ចំពោះអំពើទារុណកម្ម ហើយយោងតាមស្ថិតិរបស់ក្រសួងផ្ទាល់ មានការថយចុះនៃចំនួនអំពើទារុណកម្មពីមួយឆ្នាំ ទៅមួយឆ្នាំ។ អង្គការលីកាដូ សូមមិនឯកភាពចំពោះការអះអាងបែបនេះនោះទេ។ តាមពិត ក្នុងរយៈពេល ៣ ខែបន្ទាប់ពីការចេញផ្សាយរបាយការណ៍នោះ អង្គការលីកាដូបានទទួលព័ត៌មានអំពីការចោទប្រកាន់ចំនួន ៥៣ ទាក់ទងនឹងការរំលោភបំពាន (ការធ្វើបាប) រួមទាំងករណី បុរសម្នាក់ ដែលត្រូវបញ្ជូនទៅមន្ទីរពេទ្យបន្ទាប់ពីរងការវាយដំដោយកាំភ្លើងពីសំណាក់មន្ត្រីនគរបាល រហូតដល់សន្លប់ ។


គ្រូពេទ្យអង្គការលីកាដូ ផ្ដល់ការព្យាបាលដល់ជនជាប់ឃុំឃាំង ឆ្នាំ២០១៤

# ស្ថានភាពមិនល្អនៃសម្ភារៈបរិក្ខារពេទ្យក្នុងពន្ធនាគារ

ពេលដែលរដ្ឋមួយ ដកហូតសេរីភាពរបស់បុគ្គលម្នាក់ រដ្ឋនោះត្រូវទទួលខុសត្រូវ ចំពោះសុខុមាលភាពនៃរាងកាយរបស់បុគ្គលនោះ។ សុខុមាលភាពនេះមិនមែនត្រឹមតែការប្រព្រឹត្តចំពោះអ្នកទាំងនោះ និងស្ថានភាពនៃការឃុំឃាំងប៉ុណ្ណោះទេ ប៉ុន្តែត្រូវធានាផងដែរថា អ្នកទាំងនោះទទួលបានការថែទាំសុខភាព ដោយមិនមានការរើសអើងដោយសារស្ថានភាពផ្លូវច្បាប់របស់ពួកគាត់។[២៨]

គួរឲ្យសោកស្ដាយណាស់ ប្រព័ន្ធពន្ធនាគារកម្ពុជាមិនទាន់បានអនុវត្តចំណុចទាំងពីរខាងលើនេះនៅឡើយទេ។ ស្ថានភាពនៃការឃុំឃាំង ជាញឹកញាប់មិនអាចបំពេញនូវតម្រូវការសុខភាពជាមូលដ្ឋាន ដូចជាការទទួលបានអាហារ ទឹក ខ្យល់បរិសុទ្ធ ទំហំកន្លែងសម្រាប់ម្នាក់ៗ ពន្លឺព្រះអាទិត្យ និងខ្យល់ចេញចូល។ ការមិនផ្ដល់វេលាចេញក្រៅបន្ទប់ឃុំឃាំង និងសកម្មភាពសម្រាប់រាងកាយគ្រប់គ្រាន់ ក៏មានឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំង ចំពោះសុខុមាលភាពផ្នែករាយកាយ និងផ្លូវចិត្តផងដែរ។

បន្ថែមលើបញ្ហាទាំងនេះទៀត សម្ភារៈបរិក្ខារពេទ្យពន្ធនាគារមិនគ្រប់គ្រាន់ហើយខ្វះខាតធនធានយ៉ាងខ្លាំងហើយពន្ធនាគារខ្លះមិនមានទាំងប៉ុស្តិ៍សុខភាពថែមទៀតផង។ ចំពោះពន្ធនាគារដែលមានប៉ុស្តិ៍សុខភាពវិញ ជាទូទៅខ្វះខាតថ្នាំ និងមិនមានសម្ភារៈបរិក្ខារគ្រប់គ្រាន់ ហើយបុគ្គលិកពេទ្យវិញជាធម្មតា មិនមានចំណេះដឹងវិជ្ជាជីវៈសមស្រប ដោយទទួលបានតែការបណ្ដុះបណ្ដាលកម្រិតមូលដ្ឋានប៉ុណ្ណោះ។ ប៉ុស្តិ៍សុខភាពនៅតាមពន្ធនាគារជាច្រើន មិនបានធានានូវភាពដាច់ពីគេគ្រប់គ្រាន់ ហើយមានការព្យាយាមតិចតួចណាស់ក្នុងការធានាថា ការពិគ្រោះជម្ងឺប្រព្រឹត្តទៅដោយភាពសម្ងាត់ពេញលេញ។

សិទ្ធិទទួលបានភាពសម្ងាត់ និងសមភាពក្នុងទទួលបានការព្យាបាល ក៏ត្រូវបានប៉ះពាល់ផងដែរ ដោយសារថា សំណើរសុំការថែទាំសុខភាព ត្រូវឆ្លងកាត់ប្រធានបន្ទប់ ឬ មន្ត្រីពន្ធនាគារ ដែលជាអ្នកកំណត់ថា តើករណីមួយណាមានអាទិភាពហើយទាមទារប្រាក់ជាការដោះដូរជាមួយនឹងការផ្ដល់អទិភាពក្នុងការពិនិត្យសុខភាពនេះ។

អតីតជនជាប់ឃុំម្នាក់បានប្រាប់អង្គការលីកាដូថា ទាល់តែជនជាប់ឃុំដែលមានភាពជិតស្និទ្ធជាមួយមន្ត្រីពន្ធនាគារ ទើបទទួលបានការព្យាបាលត្រឹមត្រូវ ហើយថា ទោះបីជាគាត់មានអារម្មណ៍ថាល្ហិតល្ហៃជាប្រចាំ ហើយវិលមុខញឹកញាប់ ក៏គាត់មិនទទួលបានការព្យាបាលត្រឹមត្រូវនោះទេ។ បន្ទាប់ពីមានអន្តរាគមន៍ពីខាងក្រៅ គាត់ត្រូវបានផ្ទេរឲ្យទៅបន្ទប់មួយដែលមិនសូវចង្អៀត ដែលទុកសម្រាប់ដាក់ជនជាប់ឃុំឈឺ។ ប៉ុន្តែ គាត់បានប្រាប់អង្គការលីកាដូ ថា ជនជាប់ឃុំនៅក្នុងបន្ទប់ជាមួយគាត់ខ្លះមួយចំនួន អត់ឈឺទាល់តែសោះ។ ផ្ទុយទៅវិញ គាត់ជឿថា ពួកគេបានសូកប៉ាន់បុគ្គលិកប៉ុស្តិ៍សុខភាព ហើយថាបានយកបញ្ហាសុខភាព ដើម្បីបានប្ដូរទៅបន្ទប់ដែលស្រួលជាងមុន។

អង្គការលីកាដូ ទទួលបាននូវការរាយការណ៍ខ្លះដែលគួរឲ្យបារម្ភជាខ្លាំង ទាក់ទងនឹងការថែនាំសុខភាព និងការព្យាបាលដែលត្រូវផ្ដល់ឲ្យតែចំពោះអ្នកដែលមានលទ្ធភាពបង់ប្រាក់ប៉ុណ្ណោះ។ ហើយជនជាប់ឃុំមួយចំនួនរាយការណ៍ជាញឹកញាប់ថា បើទោះជាពួកគាត់អាច

[២៨] គោលការណ៍មូលដ្ឋានសម្រាប់ការប្រព្រឹត្តចំពោះជនជាប់ឃុំ គោលការណ៍ទី៩។

ទៅប៉ុស្តិ៍សុខភាព នៅពេលដែលពួកគាត់ឈឺក៏ដោយ ក៏ពួកគាត់ មិនបានទទួលការពិនិត្យសុខភាពឲ្យបានត្រឹមត្រូវនោះទេ។ ផ្ទុយទៅវិញ ពួកគាត់ត្រូវបានប្រាប់ឲ្យត្រលប់មកវិញ ដោយគេគ្រាន់តែឲ្យថ្នាំបំបាត់ការឈឺចាប់ បើទោះជាបញ្ហាសុខភាពពិតប្រាកដរបស់ អ្នកទាំងនោះគួរឲ្យព្រួយបារម្ភយ៉ាងណាក៏ដោយ។ ដោយសារតែ ពន្ធនាគារមិនមានសមត្ថភាពក្នុងការផ្តល់ថ្នាំសមស្រប ដល់អ្នកដែលមានបញ្ហាសុខភាព ជនជាប់ឃុំជាច្រើនអាស្រ័យលើគ្រួសារ ឬ មិត្តភក្តិរបស់ពួកគាត់ ក្នុងការនាំយកថ្នាំមកឲ្យពួកគាត់ ហើយជាធម្មតា ពួកគាត់ត្រូវបង់ប្រាក់ដើម្បីទទួលបានថ្នាំទាំងនោះ។

*អ្នកជាប់ឃុំម្នាក់បាននិយាយថា៖ "មិនមានប៉ុស្តិ៍សុខភាពនៅក្នុងពន្ធនាគារនេះទេ ដូច្នេះ ពេលដែលខ្ញុំឈឺ ខ្ញុំពឹងមន្ត្រីពន្ធនាគារជួយខ្ញុំ។ មន្ត្រីពន្ធនាគារឆ្លើយតបដោយឲ្យថ្នាំប៉ារ៉ាសេតាមុលខ្ញុំមួយចំរៀក ហើយខ្ញុំត្រូវបង់ប្រាក់ឲ្យគាត់ ០,៣ ដុល្លារ។"*

វាស្ទើតែប្រាកដហើយថា ការជាប់ឃុំឃាំងនឹងមានផលប៉ះពាល់ខ្លាំង ទៅលើសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនជាប់ឃុំ ប៉ុន្តែ អាជ្ញាធរពន្ធនាគារត្រូវតែព្យាយាមគ្រប់មធ្យោបាយ ដើម្បីទប់ស្កាត់គ្រោះថ្នាក់ទាំងនេះ។នៅកម្ពុជាអ្នកដែលមានបញ្ហាសុខភាពស្រាប់មុនចូលពន្ធនាគារ មិនបានទទួលការព្យាបាលដូចដែលពួកគាត់ត្រូវការនោះទេ ហើយអ្នកដែលមានសុខភាពធម្មតា មុនពេលជាប់ក្នុងពន្ធនាគារ ជាធម្មតាតែងតែមានបញ្ហាសុខភាពគួរឲ្យចាប់អារម្មណ៍ ពេលដែលពួកគេចេញពីពន្ធនាគារ ដែលបណ្តាលមកពីការជាប់ឃុំឃាំង។នៅក្នុងពន្ធនាគារខ្លះ នារីមានផ្ទៃពោះ នារីដែលទើបតែសម្រាលកូនរួច និងកូនតូចរបស់ពួកគាត់ មិនបានទទួលការថែទាំពិសេស ឬការប្រឹក្សាយោបល់ផ្នែកសុខភាពនោះទេ។

ចន្លោះខែមករា ដល់ ខែមិថុនា ឆ្នាំ២០១៤ បុគ្គលិកពេទ្យរបស់អង្គការលីកាដូ បានព្យាបាលជនជាប់ឃុំចំនួន ៣,៤៣៣ នាក់ ដោយចុះទៅព្យាបាលចំនួន ៥៩ ដង នៅពន្ធនាគារចំនួន ១៦ កន្លែង។ បញ្ហាសុខភាពដែលមានច្រើនជាងគេ ក្រៅពីផ្តាសាយ មានដូចជា ជម្ងឺស្បែក ជម្ងឺអស់កម្លាំង ជម្ងឺពិបាករំលាយអាហារ ជម្ងឺរលាកក្រពះ និងជម្ងឺលើសឈាម។ ក្នុងករណីជាច្រើន ជនជាប់ឃុំមិនបានទទួលការព្យាបាល ឬ ថ្នាំជាមុន ពីបុគ្គលិកពេទ្យរបស់ពន្ធនាគារនោះទេ។

ពេលចូលក្នុងពន្ធនាគារលើកដំបូង ជនជាប់ឃុំថ្មីទាំងអស់គួរតែទទួលបាន ការពិនិត្យសុខភាពឲ្យបានត្រឹមត្រូវភ្លាមៗតាមដែលអាចធ្វើទៅបាន ហើយគួរតែផ្តល់នូវការព្យាបាល និងថែទាំសុខភាពដោយឥតគិតថ្លៃ ប្រសិនបើចាំបាច់។[២៩] ប៉ុន្តែ ជនជាប់ឃុំថ្មីជាច្រើនមិនទទួលបានការពិនិត្យ និង ឆែកមើលរកជម្ងឺឆ្លង ដូចជា ជម្ងឺរបេងឲ្យបានទាំងអស់គ្នានោះទេ។

អង្គការលីកាដូ ក៏មានមន្ទិលជាខ្លាំងផងដែរ អំពីប្រសិទ្ធិភាពនៃការពិនិត្យសុខភាពពេលដំបូងដែលបានធ្វើឡើង។ ទម្រង់ផ្លូវការសម្រាប់កត់ត្រា ការពិនិត្យសុខភាពជនសង្ស័យ ពេលមកដល់ពន្ធនាគារដំបូង មិនបានតម្រូវឲ្យផ្តល់ព័ត៌មាន ទាក់ទងនឹងប្រវត្តិនៃការទទួលទានស្រា ឬ ប្រើប្រាស់គ្រឿងញៀន ប្រវត្តិមានបញ្ហាចិត្ត-សង្គម ប្រសិនបើអាចប្រឈមនឹងការធ្វើអត្តឃាត ឬ ធ្វើបាបខ្លួនឯង ប្រសិនបើមានការរំលោភបំពានផ្លូវភេទ ហើយក្នុងករណីនារី និងកុមារីវិញ ប្រសិនអាចមានផ្ទៃពោះជាដើម។

ជនជាប់ឃុំភាគច្រើនត្រូវបានបញ្ជូនទៅពន្ធនាគារ ក្នុងរយៈពេលតិចជាង ៤៨ ម៉ោង បន្ទាប់ពីការចាប់ខ្លួន ដែលនេះអាចបញ្ជាក់បានថា ស្លាកស្នាមនៃការរំលោភបំពានលើរាងកាយ នៅកន្លែងឃុំឃាំងរបស់នគរបាល ដូចជា ស្នាមជាំ ស្នាមរបួស និងស្នាមរលាក នៅតែអាចមើលឃើញច្បាស់ នៅពេលមន្ត្រីពន្ធនាគារធ្វើការពិនិត្យលើរាងកាយជនជាប់ឃុំ ពេលពួកគាត់មកដល់ពន្ធនាគារដំបូង។ តាមការពិត បើពិចារណាទៅលើកម្រិតនៃការរំលោភបំពានលើផ្លូវកាយដែលកើតមានឡើងនៅកន្លែងឃុំឃាំងរបស់នគរបាល វាពិតជាមិនទំនងទាល់តែសោះដែលថា បុគ្គលិកពេទ្យពន្ធនាគារពេលខ្លះមិនដឹងអំពីស្លាកស្នាមលើរាងកាយ ដោយសារអំពើហិង្សា នៅពេលដែលពួកគាត់ធ្វើការពិនិត្យសុខភាព។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ទំនងថា បុគ្គលិកពេទ្យពន្ធនាគារប្រហែលមិនមានឯករាជ្យភាព និងសមត្ថកិច្ច (អំណាច) ក្នុងពិនិត្យ កត់ត្រា និងរាយការណ៍ឲ្យបានត្រឹមត្រូវ ទាក់ទងនឹងស្លាកស្នាមនៃការរំលោភបំពាន ដែលប្រព្រឹត្តដោយមន្ត្រីរាជរដ្ឋាភិបាល។

ដោយសារតែបុគ្គលិកប៉ុស្តិ៍សុខភាពពន្ធនាគារ ជាទូទៅមានចំណេះវិជ្ជាជីវៈមិនគ្រប់គ្រាន់ខ្លាំងហើយខ្វះធនធានដែលមិនអាចផ្តល់សូម្បីតែការថែទាំសុខភាព មាត់ធ្មេញ និងបញ្ហា ផ្លូវចិត្តមូលដ្ឋានបាន។ ដូចនេះមិនជារឿងគួរឲ្យភ្ញាក់ផ្អើលនោះទេដែលថា ពួកគាត់មិនអាចបំពេញមុខងារពេទ្យសំខាន់ផ្សេងទៀតបាននោះ ដូចជាផ្តល់ការកំណត់និងវាយតម្លៃឲ្យត្រឹមត្រូវ ទៅលើសមត្ថភាពរាងកាយរបស់ជនជាប់ឃុំ ដើម្បីការធ្វើការងារ ការត្រួតពិនិត្យ និងការផ្តល់ប្រឹក្សាអំពីគុណភាពម្ហូបអាហារ កម្រិតអនាម័យ និងគុណភាពនៃសកម្មភាពរាងកាយ និងកីឡា ដោយសារវាពាក់ព័ន្ធនឹងសុខភាព។ ដូចគ្នានេះដែរ តាមអ្វីដែលអង្គការលីកាដូបានដឹងមក បុគ្គលិកពេទ្យពន្ធនាគារ មិនពាក់ព័ន្ធ (ពីព្រោះពួកគាត់គួរតែពាក់ព័ន្ធ) ក្នុងការសិក្សាវាយតម្លៃអំពីផលប៉ះពាល់លើរាងកាយ និងផ្លូវចិត្ត របស់ជនដែលរងការដាក់ទណ្ឌកម្ម និងឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្នែកសុខភាព បន្ទាប់ពីមានអំពើហិង្សាកើតមានក្នុងពន្ធនាគារនោះទេ។

ក្នុងករណីខ្លះ អង្គការលីកាដូ ជឿថាការបដិសេធដែលគិតទុកជាមុន ឬ មិនអើពើក្នុងការផ្តល់សេវាព្យាបាលឲ្យទាន់ពេលវេលា និង សមរម្យនៅក្នុងពន្ធនាគារកម្ពុជា បានបណ្តាលឲ្យជនជាប់ឃុំស្លាប់ដោយមិនត្រូវស្លាប់។ អ្នកដែលមានជំងឺធ្ងន់ធ្ងរ តែងតែត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យយឺតពេល ព្រោះលក្ខណៈជំងឺរបស់អ្នកទាំងនោះមិនត្រូវបានឃើញច្បាស់ ឬ មិនត្រូវបានអើពើរហូតដល់អ្នកទាំងនោះឈឺធ្ងន់ ឬ ត្រូវបានធ្វើរោគវិនិច្ឆ័យខុស និងព្យាបាលខុស។ អង្គការលីកាដូមានការព្រួយបារម្ភអំពីអត្រាមរណៈនៃជនជាប់ឃុំវ័យក្មេង ដែលមិនមានបញ្ហាសុខភាពមុនពេលចូលពន្ធនាគារ។

[២៩] គួសេចក្តីនៃគោលការណ៍សម្រាប់ការការពារជនទាំងអស់ដែលស្ថិតនៅក្នុងទម្រង់នៃការឃុំឃាំង ឬ ដាក់ពន្ធនាគារណាមួយ។

# បញ្ហាសុខភាពផ្លូវចិត្ត ដែលមិនបានយកចិត្តទុកដាក់

ក្រមព្រហ្មទណ្ឌរបស់កម្ពុជាចែងថា កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះ មិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ។ ការបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស។[៣០]

ជាអកុសលនៅកម្ពុជា ជនសង្ស័យបទល្មើសព្រហ្មទណ្ឌ កម្រត្រូវបានសិក្សាវាយតម្លៃ អំពីបញ្ហាសុខភាពផ្លូវចិត្តណាស់ ដើម្បីឲ្យដឹងពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ពួកគេ។ ផ្ទុយទៅវិញ អ្នកទាំងនោះត្រូវបានកាត់ទោស ជាញឹកញាប់ដោយមិនមានមេធាវីការពារពួកគាត់ ហើយត្រូវឃុំនៅកន្លែងឃុំឃាំង ដែលគ្មានការថែទាំសុខភាពផ្លូវចិត្ត ហើយជាកន្លែងដែលទំនងជាមិនត្រូវគេយកចិត្តទុកដាក់ និងរងការរំលោភបំពានទាល់តែសោះ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាបន្តប្រើប្រាស់អ្វីដែលថា "មណ្ឌលសង្គមកិច្ច" ដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រៅពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីឃុំខ្លួនបណ្តោះអាសន្ននូវជនដែលសង្គម "មិនត្រូវការ" ដូចជា អ្នកប្រើគ្រឿងញៀន អ្នករកស៊ីផ្លូវភេទ ជនអណាថា អ្នកសុំទាន និងអ្នកមានបញ្ហាផ្លូវចិត្ត។[៣១]

ទោះបីជាមានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីពន្ធនាគារដែលចែងថា ជនជាប់ឃុំដែលមានជម្ងឺផ្លូវចិត្ត គួរតែទទួលបាននូវការថែទាំជាក់លាក់[៣២] ហើយមានការបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រស្តីអំពីការអភិវឌ្ឍន៍យុទ្ធសាស្ត្រ រយៈពេល ៤ ឆ្នាំ របស់អគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីធ្វើឲ្យប្រសើរឡើង នូវការអប់រំសុខភាពផ្លូវចិត្ត និងកម្មវិធីព្យាបាល សម្រាប់ជនជាប់ឃុំ ដែលមានបញ្ហាផ្លូវចិត្តក៏ដោយ[៣៣] ក៏ហាក់ដូចជានៅតែមានការព្យាយាមតិចតួចណាស់ ក្នុងសិក្សាវាយតម្លៃសុខភាពផ្លូវចិត្ត របស់ជនជាប់ឃុំ ពេលដែលពួកគាត់មកដល់ពន្ធនាគារ ឬ ផ្តល់ការព្យាបាលសមស្រប ដល់អ្នកដែលមានបញ្ហាពិតប្រាកដ។

នៅកម្ពុជា បុគ្គលិកពេទ្យពន្ធនាគារ ជាធម្មតា មិនមានបទពិសោធន៍ស្រាប់ ទាក់ទងនឹងការថែទាំសុខភាពផ្លូវចិត្ត ហើយឱកាសទទួលបានការបណ្តុះបណ្តាល ក៏មិនមានគ្រប់គ្រាន់ផងដែរ។ ជនជាប់ឃុំដែលមានបញ្ហាសុខភាពស្រាប់ ជាទូទៅ អាចទទួលបានការព្យាបាល និងជួយគាំទ្រជាលក្ខណៈបុគ្គល ដែលពួកគាត់ត្រូវការ តាមរយៈសេវាកម្មមានកម្រិតរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមានជំនាញខាងបញ្ហាសុខភាពផ្លូវចិត្ត។

នេះគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ បើពិចារណាអំពីការខ្វះខាតជាទូទៅនៃធនធាន ជំនាញឯកទេស និងការយល់ដឹងអំពីបញ្ហាសុខភាពផ្លូវចិត្តនៅកម្ពុជា។ ការសិក្សាមួយ កាលពីឆ្នាំ២០១២ របស់មជ្ឈមណ្ឌល ឡេតនឺ ដើម្បីច្បាប់អន្តរជាតិ និងយុត្តិធម៌ បានបាន់ប្រមាណថា នាពេលនោះ ថវិកា សម្រាប់សុខភាពផ្លូវចិត្តមានតែ ០,០២ ភាគរយ នៃថវិកាសុខភាពសរុបរបស់កម្ពុជា ហើយបានកត់សម្គាល់ថា មិនមានអង្គភាពពេទ្យរោគផ្លូវចិត្តដាច់ដោយឡែកដែលមានកន្លែងទទួលអ្នកជម្ងឺស្នាក់នៅនោះទេក្រៅពីមាននៅទីក្រុងភ្នំពេញ និងខេត្តសៀមរាប។[៣៤]

យោងតាមអង្គការចិត្តសង្គម និងអន្តរវប្បធម៌ (TPO)[៣៥] កម្ពុជា ដែលជាដៃគូររបស់អង្គការលីកាដូ ហើយជាអង្គការឈានមុខគេរបស់កម្ពុជា ក្នុងវិស័យសុខភាពផ្លូវចិត្ត និងការជួយ

## ករណីសិក្សា

ហានវិសុទ្ធដែលមានសញ្ជាតិខ្មែរអាមេរិកកាំង ត្រូវបានចាប់ខ្លួនកាលពី ខែសីហា ឆ្នាំ២០១៤ នៅខាងក្រៅព្រះបរមរាជវាំង ជាមួយនឹងផ្ទាំងសារ ដែលមាន សរសេរថា លោកនាយកមន្ត្រី ហ៊ុន សែន ភរិយារបស់គាត់ និងកូនប្រុសច្បងរបស់គាត់ បានបាត់បង់ជីវិត ហើយថាលោកជាអ្នកដឹកនាំថ្មីរបស់ប្រទេសកម្ពុជា។ ថ្វីបើមានការរាយការណ៍ថា ដំបូងនគរបាលមានមន្ទិលសង្ស័យ ទាក់ទងនឹងសុខភាពផ្លូវចិត្តរបស់គាត់ ហើយនិយាយថា ការសិក្សាវាយតម្លៃ ទៅលើស្ថានភាពផ្លូវចិត្តរបស់គាត់នឹងត្រូវធ្វើឡើង ប៉ុន្តែជាក់ស្តែង មិនមានការសិក្សាវាយតម្លៃ បែបនេះធ្វើឡើងនោះទេ។

ផ្ទុយទៅវិញ ហានវិសុទ្ធ ត្រូវគេប្រកាសថា មានសតិល្អគ្រប់គ្រាន់ ក្នុងការចូលរួមសវនាការ ហើយត្រូវបានបញ្ជូនទៅតុលាការ នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន។ គាត់ការពារក្តីដោយខ្លួនឯង ហើយបានអះអាងថា ព្រះជាម្ចាស់បានប្រាប់ឲ្យគាត់ត្រលប់មកដឹកនាំកម្ពុជា។ ក្នុងអំឡុងពេលសវនាការ បើតាមការរាយការណ៍ ព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ថា ហាន វិសុទ្ធ មានសុខភាពផ្លូវចិត្តល្អគ្រប់គ្រាន់ ហើយត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ប៉ុន្តែជាក់ស្តែង ព្រះរាជ-អាជ្ញា មិនបានផ្តល់ភស្តុតាងអ្វីនោះទេ ដើម្បីការពារការអះអាងរបស់គាត់។ ហាន វិសុទ្ធ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ២ ឆ្នាំ។

យោងតាមការរាយការណ៍នៅលើប្រព័ន្ធផ្សព្វផ្សាយ ឯកសារសុខភាពរបស់ ហាន វិសុទ្ធ មកពីសហរដ្ឋអាមេរិក សរសេរថា ហាន វិសុទ្ធ ត្រូវបានគេធ្វើរោគវិនិច្ឆ័យ ហើយឃើញថាមានជម្ងឺវិកលចរិត និងជម្ងឺភ័យព្រួយ។[៣៦]

[៣០] ក្រមព្រហ្មទណ្ឌ មាត្រា ៣១
[៣១] សម្រាប់ព័ត៌មានបន្ថែម សូមមើល "ពួកគេប្រព្រឹត្តមកលើយើងដូចសត្វ៖ ការធ្វើបាបចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងចំពោះ "ជនដែលគេមិនត្រូវការ" នៅក្នុងមណ្ឌលឃុំឃាំងអ្នកប្រើប្រាស់គ្រឿងញៀនកម្ពុជា"៖ http://www.hrw.org/node/120957 និង http://www.licadho-cambodia.org/pressrelease.php?perm=365
[៣២] ច្បាប់ស្តីពីពន្ធនាគារ មាត្រា ៣៨
[៣៣] អគ្គនាយកដ្ឋានពន្ធនាគារ ផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨ វត្ថុបំណង ៣.២.៥
[៣៤] http://www.leitnercenter.org/files/2012%20Leitner%20Cambodia%20Report%20%28with%20photos%29.pdf
[៣៥] http://www.tpocambodia.org/
[៣៦] http://www.cambodiadaily.com/news/for-mentally-ill-man-justice-served-without-mercy-67725/

ផ្នែកចិត្តសង្គម បញ្ហាធ្លាក់ទឹកចិត្ត ជម្ងឺវិកលចរិត បញ្ហាភ័យបារម្ភ និងបញ្ហាតក់ស្លុត ជាបញ្ហាសុខភាពផ្លូវច្រើនជាងគេ ក្នុងពន្ធនាគារកម្ពុជា ហើយពួកគាត់ជាច្រើន មិនអាចទទួលបានការព្យាបាលដែលពួកគាត់ ត្រូវការនោះឡើយ។

ផលប៉ះពាល់ផ្លូវចិត្ត ដោយសារការរស់នៅក្នុងពន្ធនាគារនៅកម្ពុជា មិនមែនត្រឹមតែជាក្ដីកង្វល់ ចំពោះការដែលជួបប្រទះបញ្ហាសុខភាពផ្លូវចិត្តពេលគាត់ជាប់ពន្ធនាគារនោះទេ។ ចំពោះអ្នកខ្លះ ការជាប់ពន្ធនាគារ អាចជាចាប់ផ្ដើមនៃបញ្ហាសុខភាពផ្លូវចិត្តផងដែរ ខណៈដែលស្ថានភាពមិនល្អនៃការឃុំឃាំង កង្វះអាហារ និងការទទួលទានដំណេកមិនបាន គួបផ្សំជាមួយការប្រាស្រ័យទាក់ទងជាមួយអ្នកខាងក្រៅពន្ធនាគារ អាចធ្វើឲ្យស្ថានភាពរបស់អ្នកដែលមានបញ្ហាសុខភាពផ្លូវចិត្តស្រាប់ កាន់តែធ្ងន់ធ្ងរថែមទៀត។

អង្គការលីកាដូ មានការព្រួយបារម្ភថា អ្នកដែលជួបប្រទះបញ្ហាសុខភាព ក្លាយជាគោលដៅនៃការរំលោភបំពាន ដោយនគរបាល និងអាជ្ញាធរពន្ធនាគារ រួមទាំងជនជាប់ឃុំដូចគ្នាផងដែរ។ អង្គការចិត្តសង្គមអន្តរវប្បធម៌ បានកាត់ត្រានូវការរំលោភបំពាន ដែលកើតមានចំពោះអតិថិជនរបស់ខ្លួន ហើយស្វែងយល់អំពីផលប៉ះពាល់រយៈពេលយូរ ដែលមានចំពោះសុខភាពផ្លូវចិត្តរបស់អ្នកទាំងនោះ។ របាយការណ៍ទាំងនេះ គឺស្របជាមួយនឹងប្រភេទនៃការចោទប្រកាន់ដែលទទួលបានដោយអង្គការលីកាដូ ហើយក្នុងនោះរួមមាន ជនជាប់ឃុំត្រូវបានទះ ទាត់ និងរុញច្រាន ហើយត្រូវបានវាយជាមួយនឹងវត្ថុដូចជាកាំភ្លើង ធ្វើឲ្យរលាកដោយសារទឹកពុះ និងបារី ធ្វើឲ្យថប់ដង្ហើមដោយប្រើថង់ផ្លាស្ទីក ឬ យកក្រណាត់បិទភ្នែក ត្រូវបានគេយកវត្ថុស៊កចូលក្នុងទ្វារធំ ត្រូវគេគំរាមសម្លាប់ រំលោភសេពសន្ថវៈ ប្របាច់ក៏ និងអំពើហិង្សាលើរាងកាយផ្សេងទៀត ហើយត្រូវបានគេបង្ខំឲ្យអង្គុយឈរ ឬ លុតជង្គង់ នៅក្នុងជំហរដដែលរយៈពេលច្រើនម៉ោង។

អ្នកជម្ងឺរបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ ក្នុងពន្ធនាគារដែលត្រូវបានរងទុក្ខ ឬ បន្តរងទុក្ខ ឬ រងការធ្វើបាប បានរាយការណ៍អំពីអាការៈ ដែលរួមមានការឈឺក្បាល រសាប់រសល់ បាក់ទឹកចិត្ត រំខានដំណេក លឺសម្លេង ការភ័យព្រួយខ្វាប់ខ្វួន ឆាប់ឆេវឆាវ និងឆាប់ខឹង ហើយនឹងមានប្រតិកម្មភ្ញាក់ផ្អើល។ អ្នកជម្ងឺខ្លះរបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ ដែលបានឆ្លងកាត់ការបំពានបានព្យាយាមធ្វើអត្តឃាត។ អ្នកឯទៀត បានបង្ហាញឲ្យឃើញគំនិតចង់ធ្វើអត្តឃាត។ ជាអកុសល អ្នកដែលប៉ុនប៉ងធ្វើអត្តឃាត ឬ ធ្វើបាបខ្លួនឯង ប្រហែលជាយល់ឃើញថា ពួកគាត់មិនបានទទួលការគ្រប់គ្រង និងជួយគាំទ្រសមស្របនោះទេ។

*"មន្ត្រីពន្ធនាគារមិនខ្វល់ ប្រសើនបើជនជាប់ឃុំចង់ធ្វើអត្តឃាត។ ឥរិយាបថរបស់អ្នកទាំងនោះ គឺថា ប្រសិនបើអ្នកចង់សម្លាប់ខ្លួន សូមអញ្ជើញ។ ពេលដែលខ្ញុំប្រាប់មន្ត្រីពន្ធនាគារលើកដំបូងថា ខ្ញុំមានអារម្មណ៍ចង់ធ្វើអត្តឃាត មន្ត្រីពន្ធនាគារបានស្ដីបន្ទោសឲ្យខ្ញុំ ហើយប្រាប់ខ្ញុំថា ពួកគាត់នឹងមិនអនុញ្ញាតឲ្យគ្រួសារខ្ញុំមកសួរសុខទុក្ខខ្ញុំទៀតទេ។"*


ជនជាប់ឃុំជាស្ត្រីចំណាស់ នៅមណ្ឌលអប់រំកែប្រែទី២ ឆ្នាំ២០១១

# លើសពីសមត្ថភាព

ក្នុងខែកក្កដា ឆ្នាំ២០១០ អង្គការលីកាដូ បានរាយការណ៍នូវចំនួនជនជាប់ឃុំនៅក្នុងពន្ធនាគារនៅកម្ពុជា ដែលមានការកើនឡើងយ៉ាងខ្លាំង ដែលពេលនោះ ចំនួនជនជាប់ឃុំមានចំនួន ១៣,៣២៥ នាក់ ដែលស្មើនឹង ១៦៧ ភាគរយ នៃសមត្ថភាពផ្ទុករបស់ពន្ធនាគារ ដែលមានត្រឹមតែ ៨,០០០ នាក់។

ដោយសារតែចំនួនជនជាប់ឃុំបានបន្តកើនឡើងក្នុងរយៈពេល ២ ឆ្នាំ កន្លះ ទៀត (មកដល់ត្រឹមពាក់កណ្តាល ខែមករា ឆ្នាំ២០១៣ ចំនួនជនជាប់ឃុំសរុបបានកើនឡើងរហូតដល់ ១៥,៥៤២ នាក់) អង្គការលីកាដូ បានបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការតស៊ូមតិ ដោយបានផ្តល់ហេតុផលថា ការពង្រីកប្រព័ន្ធពន្ធនាគារ មិនមែនជាដំណោះស្រាយយូរអង្វែងនោះទេ ហើយផ្ទុយមកវិញ អំពាវនាវឲ្យមានការកាត់បន្ថយការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំ សវនាការ ហើយបង្កើនការប្រើប្រាស់ការផ្តន្ទាទោសមិនជាប់ពន្ធនាគារ។

ពេញមួយឆ្នាំ២០១៣ ការកើនឡើងជាបន្តបន្ទាប់នៃចំនួនជនជាប់ឃុំ បានចាប់ផ្តើមធូរស្រាលមកវិញ មួយផ្នែកដោយសារការកើនឡើងនៃការលើកលែងទោស។ ទោះជាយ៉ាងណា ចំនួនជនជាប់ឃុំជាទូទៅមិនមានការថយចុះគួរកត់សម្គាល់នោះទេ ហើយដំណោះស្រាយច្បាស់លាស់ និងយូរអង្វែង ចំពោះបញ្ហាចង្អៀតណែននេះក៏មិនទាន់មាននោះដែរ។ តាមការពិត ពន្ធនាគារនៅកម្ពុជាកំពុងដំណើរការដោយមានការផ្ទុកជនជាប់ឃុំ លើសពីសមត្ថភាពរបស់ខ្លួនយ៉ាងខ្លាំង បើប្រៀបធៀប ឆ្នាំ២០១០ ដែលមានចំនួនជនជាប់ឃុំសរុប ១៥,១៨២ នាក់ ហើយត្រឹម ពាក់កណ្តាលខែកញ្ញា ឆ្នាំ២០១៤ នេះ ចំនួនជនជាប់ឃុំស្មើនឹង ១៧៩ ភាគរយ នៃសមត្ថភាព ផ្ទុករបស់ពន្ធនាគារ ដែលមានត្រឹមតែ ៨,៥០០ នាក់។[៣៧]



ជនជាប់ឃុំជាបុរស នៅពន្ធនាគារខេត្តកំពង់ឆ្នាំ ឆ្នាំ២០០៩

## ទំហំកន្លែងសម្រាប់ស្នាក់នៅត្រូវបង់តម្លៃបន្ថែម

កម្រិតនៃភាពចង្អៀតណែនក្នុងពន្ធនាគារមិនដូចគ្នានោះទេ ពីព្រោះពន្ធនាគារខ្លះដាក់ជន ជាប់ឃុំតិចជាងសមត្ថភាពផ្ទុករបស់ពន្ធនាគារ (១០០ ភាគរយ) ខណៈពន្ធនាគារខ្លះទៀត ដាក់ជនជាប់ឃុំលើសសមត្ថភាព រហូតដល់ទៅ ២០០ ភាគរយ។ លើសពីនេះទៅទៀត សូម្បីតែនៅក្នុងពន្ធនាគារតែមួយបន្ទប់ និងអគារខ្លះមានភាពចង្អៀតណែនខ្លាំងជាងបន្ទប់ និងអគារផ្សេងទៀត។ ក្នុងពន្ធនាគារខ្លះ អតីតជនជាប់ឃុំ បានរាយការណ៍ថា ពួកគាត់អាចបង់ប្រាក់ ដើម្បីបានទៅនៅក្នុងបន្ទប់ ដែលមិនសូវចង្អៀតណែន ហើយ បំពាក់ទៅដោយសម្ភារៈបរិក្ខារប្រសើរជាង។ ពួកគាត់ ក៏រាយការណ៍ថា ជនជាប់ឃុំ អាចចំណាយប្រាក់ពីរបីរយដុល្លារ ឬ លើសពីនេះ ដើម្បីទិញបន្ទប់មួយស្នាក់នៅម្នាក់ឯង។

សូម្បីតែស្នាក់នៅក្នុងបន្ទប់ជាមួយគ្នា ជនជាប់ឃុំខ្លះទទួលបានទំហំធំជាងជនជាប់ឃុំដ៏ទៃទៀត ដោយសារឋានៈសង្គម ឬ ស្ថានភាពហិរញ្ញវត្ថុ។ជនជាប់ឃុំដែលត្រូវបានដោះលែង បានរាយការណ៍មកអង្គការលីកាដូ ថា ជនជាប់ឃុំដែលមានប្រាក់បង់ បានទទួលទានដំណេកនៅលើផ្ទើរ ខណៈជនជាប់ឃុំដែលអត់មានប្រាក់បង់ ត្រូវទទួលដំណេកនៅលើកម្រាលឥដ្ឋ។ ជនជាប់ ឃុំដែលមានធនធានតិចជាងគេ ជាទូទៅទទួលទានដំណេកនៅលើកម្រាលឥដ្ឋក្បែរបន្ទប់ទឹក ហើយជាញឹកញាប់ ត្រូវគេដើរជាន់នាពេលយប់។

[៣៧] "កំណែតម្រង់ដំណើរការនៃការសម្រេចទៅលើការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ" បទបង្ហាញដោយឯកឧត្តម អ៊ិត រ៉ាឌី អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌

*"ខ្ញុំស្នាក់នៅក្នុងបន្ទប់ឃុំឃាំង ជាមួយស្រ្តី ៧០ នាក់ ផ្សេងទៀត។ ក្នុងនាមជាអ្នកមកថ្មី ខ្ញុំ ត្រូវគេងនៅលើកម្រាលអិដ្ឋជាមួយនារី ២០ នាក់ ផ្សេងទៀត។ ពួកយើងម្នាក់ៗ ទទួលបានទំហំ ប្រហែល ០.៥ ប៉ុណ្ណោះសម្រាប់គេង ហេតុដូចនេះ ជានិច្ចជាកាល យើងគេងផ្អៀងខ្លួន។ យើងមិន អាចប្រែខ្លួននោះទេ ហើយប្រសិនបើយើងប្រែខ្លួន យើងនឹងប៉ះអ្នកគេងក្បែរយើង។ ពេលយប់ ជនជាប់ឃុំដ៏ទៃទៀតក្នុងបន្ទប់ ដើរជាន់ខ្ញុំជាញឹកញាប់ ពេលពួកគាត់ទៅបន្ទប់ទឹក។ អ្នកដែលគេងលើ ផ្ទើរសម្រាប់គេង ត្រូវបង់ប្រាក់ចាប់ពី ២០ ដុល្លារ ទៅ ៣០ ដុល្លារ។"*

ក្នុងខែមករា ឆ្នាំ២០១៣ អង្គការលីកាដូ កត់ត្រាឃើញថា អគារមួយ នៅក្នុងពន្ធនាគារ មួយនោះ មានបន្ទប់ចំនួន ១២ ដែលមានទំហំដូចគ្នា ប៉ុន្តែមានចំនួនជនជាប់ឃុំក្នុងបន្ទាប់នីមួយៗ ចន្លោះពី ១ នាក់ ទៅ ១២ នាក់។ អង្គការលីកាដូ ដឹងថា ក្នុងករណីនេះ ជនជាប់ឃុំដែលស្នាក់នៅ ក្នុងបន្ទប់ឃុំមួយម្នាក់ឯង មិនមែនត្រូវបានដាក់ឲ្យនៅដាច់ដោយឡែក ដោយសារមូលហេតុ សុវត្ថិភាព ឬ ក៏មូលហេតុសមស្របអ្វីទៀតនោះទេ ប៉ុន្តែដោយសារសិទ្ធិពិសេស និងស្ថានភាពហិរញ្ញវត្ថុ។

បន្ទប់ភាគច្រើន ក្នុងចំណោមបន្ទប់ទាំង ១២ នេះ ដាក់ជនជាប់ឃុំជាមធ្យម ៧ នាក់។ ដោយសារបន្ទប់មួយមានទំហំ ៥.៤៦ ម៉ែត្រការ៉េ អញ្ចឹងជនជាប់ឃុំម្នាក់ៗ ទទួលបានទំហំត្រឹមតែ ០,៧៨ ម៉ែត្រការ៉េ តែប៉ុណ្ណោះ។ នាពេលយប់ មានជនជាប់ឃុំត្រឹមតែ ២ ឬ ៣ នាក់ តែប៉ុណ្ណោះ ដែលគេងនៅក្នុងបន្ទប់ឃុំឃាំងនេះ ខណៈជនជាប់ឃុំដ៏ទៃទៀត គេងនៅលើផ្លូវដើរមុខបន្ទប់។ អាជ្ញាធរពន្ធនាគារ ប្រាប់អង្គការលីកាដូ ថា មានតែជនជាប់ឃុំដែលមានកម្រិតសុវត្ថិភាពកម្រិតទាបតែប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យគេងនៅខាងមុខបន្ទប់ ប៉ុន្តែដូចនៅពន្ធនាគារ ដ៏ទៃទៀតដែរ ជនជាប់ឃុំបានរាយការណ៍ថា វាមិនដោយសារកម្រិតសុវត្ថិភាពនោះទេ។ ពួកគាត់បង់ប្រាក់ ដើម្បីបានគេងនៅខាងមុខបន្ទប់ពីព្រោះវាមានខ្យល់ចេញចូល និងពន្លឺធម្មជាតិ ច្រើនជាង។

# ឆ្ពោះទៅបញ្ចប់ការចង្អៀតណែនក្នុងពន្ធនាគារ

ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវជម្រើសផ្សេងៗ ជំនួសឲ្យការដាក់ពន្ធនាគារ តាមរយៈការត្រួតពិនិត្យតាមផ្លូវតុលាការ ការព្យួរទោស និងការងារសហគមន៍។ ទោះជាយ៉ាងណា ជម្រើសផ្សេងៗ ជំនួសឲ្យការដាក់ពន្ធនាគារ កម្រយកទៅពិចារណា នាពេលកាត់ទោសណាស់ ហើយវិធានការចំពោះការមិនឃុំឃាំង នៅតែពិចារណាដោយមន្ទិលសង្ស័យនៅឡើយ និងដោយការសារភាពខ្លួនឯងផ្ទាល់ របស់ក្រសួងយុត្តិធម៌ ហើយបញ្ញត្តិ និងគោលការណ៍ណែនាំ សម្រាប់ការត្រួតពិនិត្យតាមផ្លូវតុលាការ មិនទាន់បានអនុវត្តឲ្យបានត្រឹមត្រូវ សមស្រប និងមានប្រសិទ្ធិភាពនៅឡើយទេ ខណៈដែលការព្យួរទោស និងការងារសហគមន៍ មិនត្រូវបានប្រតិបត្តិឲ្យមានប្រសិទ្ធភាព និងរលូននោះឡើយ។[៣៨]



ជាការឆ្លើយតបចំពោះបញ្ហានេះ រាជរដ្ឋាភិបាលបង្កើតក្រុមការងារមួយ ទាក់ទងនឹងជម្រើសផ្សេងៗ ជំនួសឲ្យការដាក់ពន្ធនាគារ ដែលបានធ្វើការផ្សព្វផ្សាយសារាចរចំនួន ៣ នៅដើម ឆ្នាំ២០១៤ ក្នុងគោលបំណងផ្តល់ការណែនាំបន្ថែមទៀត ដល់មន្ត្រីយុត្តិធម៌ ក្នុងការអនុវត្តន៍ជម្រើសផ្សេងៗ សម្រាប់ការដាក់ទោសដោយពុំមានការឃុំឃាំង ក្នុងន័យដើម្បីធានាថា ព្រះរាជអាជ្ញា និងចៅក្រមសើបសួរគោរពទៅតាមគោលការណ៍ច្បាប់ ដោយពិនិត្យពិចារណាឲ្យបានល្អិតល្អន់ទៅលើលក្ខណៈនៃបទល្មើស និងបុគ្គលិកលក្ខណៈ និងស្ថានភាពផ្ទាល់ខ្លួនរបស់ជនជាប់ចោទ។

អង្គការលីកាដូ ស្វាគមន៍ចំពោះគោលការណ៍ណែនាំនេះ ប៉ុន្តែមិនទាន់បានឃើញនូវភស្តុតាងនៃលទ្ធផលវិជ្ជមាន ឬ ការប្តេជ្ញាចិត្តពិតប្រាកដ ក្នុងធ្វើឲ្យមានភាពប្រសើរឡើងពិតប្រាកដនៅឡើយទេ។

ឆ្មាំពន្ធនាគារ នៅពន្ធនាគារខេត្តកំពង់ឆ្នាំ ឆ្នាំ២០០៩

[៣៨] សារាចររបស់ក្រសួងយុត្តិធម៌លេខ ១០/១៤ និង ០៣/១៤

*នៅខេត្តសៀមរាប កម្មវិធីមួយ របស់អង្គការមិត្តសំលាញ់អន្តរជាតិ[៣៩] ដែលមានឈ្មោះថា កល្យាណមិត្ត បានធ្វើការជាមួយប៉ុស្តិ៍នគរបាល នៅតាមមូលដ្ឋាន តាំងពីឆ្នាំ២០០៩ មកម្ល៉េះ ដើម្បីបង្វែរអនីតិជនដែលជាប់ចោទពីបទល្មើសតូចតាច ចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ហើយជំនួសដោយការផ្តល់ឲ្យពួកគាត់នូវកន្លែងស្នាក់នៅបណ្តោះអាសន្នដែលមានសុវត្ថិភាព រួមទាំងមានការអប់រំ និងឱកាសទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផងដែរ។ ក្នុងឆ្នាំ២០១៣ នគរបាលបានបញ្ជូនអនីតិជនចំនួន ៧៦ រូប មកឲ្យកម្មវិធីនេះ ដោយ ១៥ រូប នៃអ្នកទាំងនោះបានប្រព្រឹត្តបទល្មើសតូចតាច ហើយប្រសិនបើមិនបញ្ជូនទៅទីនោះទេ ពួកគាត់អាចជាប់ក្នុងពន្ធនាគារ។*

បើទោះជាចំនួនជនជាប់ឃុំលែងកើនឡើង ក្នុងអត្រាមួយដូចកាលពី ពីរឆ្នាំមុនក៏ដោយ ការចង្អៀតណែននៅតែជាបញ្ហាដំបងដដែល ហើយយោងតាមរបាយការណ៍សង្ខេប ស្តីពីស្ថានភាពពន្ធនាគារពិភពលោក របស់មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាអំពីពន្ធនាគារ (ICPS)[៤០] ពន្ធនាគារកម្ពុជាជាប់ចំណាត់ថ្នាក់ទី២៩ ក្នុងចំណោមពន្ធនាគារ ដែលមានភាពចង្អៀតណែនបំផុតក្នុងពិភពលោក។ អាជ្ញាធរកម្ពុជាគួរតែដោះស្រាយកែលម្អបញ្ហានេះ ហើយព្យាយាមសម្រេចឲ្យបាននូវកម្រិត ១០០ ភាគរយ ឬ ទាបជាងនេះ ចំពោះ អត្រាជនជាប់ឃុំក្នុងពន្ធនាគារ (ធៀបនឹងសមត្ថភាពផ្ទុកជាក់ស្តែងរបស់ពន្ធនាគារ) ក្នុងរយៈពេលសមស្របមួយ។ ដើម្បីសម្រេចវាបាន អាជ្ញាធរត្រូវបំពេញកិច្ចការជាច្រើន មិនមែនគ្រាន់តែសាងសង់ពន្ធនាគារ និងអគារឃុំឃាំងបន្ថែម ផ្ទេរជនជាប់ឃុំពីពន្ធនាគារទៅពន្ធនាគារមួយទៀត[៤១] ឬ បង្កើនចំនួនអភ័យទោសនោះទេ។

ផ្ទុយទៅវិញ ដើម្បីជាការដោះស្រាយយូរអង្វែង និងសមស្រប ចំបាច់គួរតែមានការផ្លាស់ប្តូរជាមូលដ្ឋាន ចំពោះការឃុំខ្លួនបណ្តោះអាសន្ន រង់ចាំសវនាការ ដែលអនុវត្តជានិច្ចកាលចំពោះជនគ្រប់រូបកន្លងមក ហើយបង្កើនទូទាំងប្រទេស នូវជម្រើសផ្សេងៗសម្រាប់ការដាក់ទោសមិនជាប់ឃុំសម្រាប់បទល្មើសតូចតាច។

ការរកឃើញរបស់អង្គការលីកាដូ ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ និងការឃុំឃាំងមិនចាំបាច់ និងងាយគ្រោះថ្នាក់ ចំពោះអ្នកដែលត្រូវបានផ្តន្ទាទោស ពីបទល្មើសតូចតាច បង្ហាញនូវភាពចាំបាច់យ៉ាងខ្លាំង ចំពោះការផ្លាស់ប្តូរនេះ។ ការផ្លាស់ប្តូរមិនត្រឹមតែជួយកាត់ទិ្ធពលអវិជ្ជមានពីការឃុំឃាំង ដែលអាចកើតមានចំពោះបុគ្គល គ្រួសារ និងសហគមន៍ផងដែរ។

ទោះជាមាននីតិវិធីថ្មី សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ដែលបានបង្កើតឡើងនៅដើម ឆ្នាំ២០១៤ និងការចំណាយធនធានគួរសមរម្យ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងការបង្កើតគោលការណ៍ណែនាំសម្រាប់សម្រើសផ្សេងៗ ជំនួយឲ្យការឃុំខ្លួនក៏ដោយ មកដល់ពេលបច្ចុប្បន្ន មិនឃើញមានអ្វីដែលជាភស្តុតាងច្បាស់លាស់ នៃការកំណែទម្រង់ពិតប្រាកដនោះឡើយ។ បន្ថែមទៅលើការធ្វើឲ្យប្រសើរឡើងនូវគោលការណ៍ណែនាំ ត្រូវតែមានការផ្លាស់ប្តូរពិតប្រាកដនិងសមស្របចំពោះរបៀបដែលប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដំណើរ ហើយនិងការផ្លាស់ប្តូរពីការឥរិយាបទដែលពិបាកផ្លាស់ប្តូរ ទាក់ទងនឹងបទល្មើស និងការដាក់ទោស ដែលចូលចិត្តឃុំឃាំងលើសអ្វីៗទាំងអស់។

[៣៩] សូមមើល http://www.friends-international.org/
[៤០] http://www.prisonstudies.org/world-prison-brief
[៤១] ជាឧទាហរណ៍ ក្នុងឆ្នាំ២០១២ អគ្គនាយកដ្ឋានពន្ធនាគារបានធ្វើការផ្ទេរជនជាប់ឃុំចំនួន ៦៨៦ រូប រួមទាំងនារី៤០ ទៅពន្ធនាគារដ៏ទៃទៀត ដើម្បីកាត់បន្ថយភាពចង្អៀតណែន (របាយការណ៍ប្រចាំឆ្នាំ២០១២ របស់អគ្គនាយកដ្ឋានពន្ធនាគារ និងវត្តបំណងឆ្នាំ២០១៣)

# ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ គួរតែជាករណីលើកលែង មិនមែនជាវិធានការណ៍នោះទេ

ដូចមានចែងយ៉ាងច្បាស់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។[៤២] ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ គួរតែធ្វើទៅតែជាមធ្យោបាយចុងក្រោយ ហើយចំពោះតែករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈឹម ដែលមានច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពីមួយឆ្នាំប៉ុណ្ណោះ។[៤៣] ជាពិសេសទៅទៀត ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ក៏តម្រូវឲ្យចៅក្រមស៊ើបសួរដែលសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នរង់ចាំសវនាការ តាមដីកាដោយមានសំអាងហេតុ។[៤៤]

ប៉ុន្តែទោះជាយ៉ាងណា ក្នុងការអនុវត្តន៍ ប្រព័ន្ធយុត្តិធម៌កម្ពុជាបានផ្តោតស្ទើរតែទាំងស្រុង ទៅលើការឃុំឃាំងជនត្រូវចោទ ហើយការសម្រេចចិត្តក្នុងការឃុំឃាំងជនសង្ស័យមួយរូប មុនពេលសវនាការទំនងជាធ្វើឡើងដោយស្វ័យប្រវត្តិ ដោយមិនបានធ្វើការពិចារណាទៅលើស្ថានភាពផ្ទាល់ខ្លួនរបស់ជនសង្ស័យ ឬក៏ កត្តាផ្សេងៗ ក្នុងការសម្រាលទោសនោះទេ។ ពិតណាស់ វាត្រូវបានគេសន្មត់ជាទូទៅថា ទាល់តែអ្នកមានទំនាក់ទំនងកម្រិតខ្ពស់ ឬ អ្នកមានធនធាន ក្នុងការផ្តល់សំណូកដល់មន្ត្រីតុលាការ ដែលអាចគេចពីជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការបាន។ ការអនុវត្តន៍ជាទូទៅនៃការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ជាការបង្ហាញនូវភាពទន់ខ្សោយជាប្រព័ន្ធ ក្នុងការអនុត្តន៍គោលការណ៍របស់រដ្ឋធម្មនុញ្ញ ដែលសន្មត់ជាមុនថាគ្មានទោស រហូតដល់រកឃើញថាមានទោស។[៤៥]

យោងតាមច្បាប់នេះ ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ គួរតែត្រូវបានបង្គាប់ជាការចំបាច់ ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតជាថ្មី ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ដើម្បីការពារ សន្តិសុខឲ្យជនត្រូវចោទ ឬ ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។[៤៦]

ប៉ុន្តែទោះបីជាយ៉ាងណា មកដល់ពេលបច្ចុប្បន្ននេះ គម្លាតរវាងច្បាប់ និងការអនុវត្តន៍កាន់តែធំជាងមុន។ ជាទម្លាប់ពីមុន ចៅក្រមគ្រាន់តែគូសលើប្រអប់មួយ ឬ ច្រើន ដែលមានសរសេរនូវចំណុចសំអាងហេតុទាំង ៦ នៅលើទម្រង់លិខិតរបស់តុលាការ ដោយមិនបានស្តាប់ការជជែកដេញដោល ពីគ្រប់ភាគី ឬ បញ្ជាក់ឲ្យបានច្បាស់អំពីមូលហេតុសម្រេចឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការនោះទេ។

ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ត្រូវបានចេញដោយមិនមានមូលហេតុសមស្រប ហើយមិនមានការពិចារណាទៅលើការពិតជាក់ស្តែងរបស់ករណី ឬ ស្ថានភាពផ្ទាល់ខ្លួនរបស់ជនត្រូវចោទនោះទេ។ ជាលទ្ធផល បុគ្គលរាប់ពាន់នាក់រួមទាំងអនីតិជន និងនារីមានផ្ទៃពោះផង ត្រូវបានឃុំឃាំង ដោយពុំចាំបាច់ ដោយគ្រាន់តែប្រព្រឹត្តបទល្មើសតូចតាចបំផុត ដូចជា គ្រាន់តែលួចស្រូវមួយការុងជាដើម។ ដូចដែលបានកត់សម្គាល់ដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ការដាក់ទោសដោយមិនមានហេតុផល និងហួសហេតុបែបនេះ ស្មើគ្នាទៅនឹងការឃុំឃាំងខុសច្បាប់។[៤៧]

ភាគរយ នៃចំនួនជនជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ នៅតែមានកម្រិតខ្ពស់ ហើយមិនមានសញ្ញាថាធ្លាក់ចុះនោះទេ។ យោងតាម របាយការណ៍សង្ខេបស្តីពីស្ថានភាពពន្ធនាគារពិភពលោក របស់មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាអំពីពន្ធនាគារ (ICPS) ប្រទេសកម្ពុជាចាប់ចំណាត់ថ្នាក់ទី២៣ ក្នុងចំណោមប្រទេស ២១១ (ពីខ្ពស់ទៅទាប) នៅពេលដែលនិយាយអំពីភាគរយនៃជនជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ។[៤៨]

ស្ថិតិរបស់អគ្គនាយកដ្ឋានពន្ធនាគារ បង្ហាញថា ក្នុងខែធ្នូ ឆ្នាំ២០១២ ចំនួនជនជាប់ឃុំជានីតិជន ដែលជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ រួមទាំងអ្នករង់ចាំបណ្តឹងឧទ្ធរណ៍ និងចាំសេចក្តីសម្រេចចុងក្រោយ[៤៩] មានចំនួន ៦១ ភាគរយ នៃចំនួនជនជាប់ឃុំសរុប ខណៈដែលនៅ ខែកញ្ញា ឆ្នាំ២០១៤ មានចំនួន ៦៣ ភាគរយ។ ជាការកត់សម្គាល់ នាពេលបច្ចុប្បន្ន ភាគរយនៃជនជាប់ឃុំខ្លួនបណ្តោះអាសន្នជានារី និងជាអនីតិជន មានកម្រិតខ្ពស់ជាងបុរស ដោយនារីមាន ៧០ ភាគរយ នៃចំនួនជនជាប់ឃុំជានារី ហើយគួរឲ្យព្រួយបារម្ភមាន ៨៣ ភាគរយ នៃចំនួនជនជាប់ឃុំជាកុមារ ដែលកំពុងរង់ចាំសវនាការបណ្តឹងឧទ្ធរណ៍ ឬ សាលក្រមស្ថាពរ ក្នុងខែកញ្ញា ឆ្នាំ២០១៤។ ក្នុងចំណោមអនីតិជនជានារីចំនួន ១៨ រូប មានតែ ១ រូប ប៉ុណ្ណោះ ដែលបានកាត់ទោសរួច។

[៤២] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៣
[៤៣] ដូចខាងលើ មាត្រា ២០៤
[៤៤] ដូចខាងលើ មាត្រា ២០៦
[៤៥] រដ្ឋធម្មនុញ្ញ មាត្រា ៣៨
[៤៦] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៥
[៤៧] កិច្ចស្វាគមន៍ដោយលោកស្រី Wan-Hea Lee តំណាងរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា នៅឯសន្និសីទស្តីពីការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ និងជម្រើសផ្សេងៗជំនួយសឲ្យការឃុំឃាំង សណ្ឋាគារកាំបូដឌីយ៉ាណា ភ្នំពេញ ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៤។ កិច្ចស្វាគមន៍នេះត្រូវបានអាននៅឯសន្និសីទនោះដោយតំណាងរងMarie-Dominique Parent
[៤៨] http://www.prisonstudies.org/highest-to-lowest/pre-trial-detainees?field_region_taxonomy_tid=All
[៤៩] យោងតាម Open Society Justice Initiative ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ត្រូវបានឲ្យនិយមន័យថា ជារយៈពេលដែលបុគ្គលមួយរូបត្រូវបានដកហូតសេរីភាព រហូតដល់ការបញ្ចប់នៃសវនការបទល្មើស (រួមទាំងការប្តឹងឧទ្ធរណ៍ផងដែរ)។ ស្រដៀងគ្នានេះដែរ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាអំពីពន្ធនាគារ រួមបញ្ចូលនូវនិយមន័យនៃការជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ថា បុគ្គលដែលកំពុងរង់ចាំបណ្តឹងឧទ្ធរណ៍ ឬ សាលក្រមស្ថាពរ។



ច្រកចូលទៅកាន់មណ្ឌលអប់រំកែប្រែទី៤ ឆ្នាំ២០១៤

# ទម្រង់ថ្មីរបស់តុលាការ-ជំហានមួយទៀតឆ្ពោះទៅកំណែទម្រង់

ថ្វីត្បិតតែការឃុំខ្លួននៅតែអនុវត្តជានិច្ច ចំពោះអ្នករង់ចាំសវនាការ ដោយមិនគិតពីចរិកលក្ខណៈនៃបទល្មើស ស្ថានភាពគ្រួសារ ឬ អាយុក៏ដោយ ក៏មានការខិតខំប្រឹងប្រែងជាច្រើននាពេលថ្មីៗនេះ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ក្រោយពេលប្រឹក្សាយោបល់ពេញមួយឆ្នាំ នីតិវិធី និងទម្រង់ថ្មី សម្រាប់កំណត់ពីការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការត្រូវបានបង្កើតឡើង និងផ្សព្វផ្សាយទៅកាន់តុលាការទាំងអស់នាដើម ឆ្នាំ២០១៤។

ដោយយោងតាមនីតិវិធីថ្មីនេះ ចៅក្រមតម្រូវអោយធ្វើការពិចារណាអោយបានត្រឹមត្រូវ ទៅលើអំណះអំណាងស្រប និងប្រឆាំងចំពោះការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ រួមទាំង ស្ថានភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗផងដែរ។ ដើម្បីធ្វើដូចនេះ ចៅក្រមគួរតែយកចិត្តទុកដាក់ជាពិសេសទៅលើថា តើជនត្រូវចោទជាកុមារ មនុស្សចាស់ នារីមានផ្ទៃពោះ ឬ នារីដែលមានកូនតូចនៅជាមួយ។

មុនពេលចេញដីកាបង្គាប់ ឲ្យឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ឥឡូវចៅក្រម គួរតែបង្ហាញថា ខ្លួនបានធ្វើការពិចារណាយ៉ាងល្អិតល្អន់ទៅលើតថភាពពាក់ព័ន្ធនានា មុនពេលដែលអ្នកទាំងនោះដកហូតសេរីភាពរបស់អ្នកណាម្នាក់ ហើយត្រូវតែពន្យល់ដោយបានច្បាស់ពីហេតុផលមួយណានៃហេតុផលទាំង៦ ចំណុចដើម្បីធ្វើការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ដូចដែលមានចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងករណីមួយ ដោយមានហេតុផលពន្យល់ច្បាស់លាស់ ។

អង្គការ លីកាដូ ស្វាគមន៍ចំពោះការបោះជំហានទៅរកកំណែទម្រង់នីតិវិធី ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ប៉ុន្តែមានការសោកស្តាយ ដែលប្រព័ន្ធត្រួតពិនិត្យតាមដាន ប្រកបដោយប្រសិទ្ធិភាពមិនត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យថា តើនីតិវិធីទាំងនេះត្រូវបានអនុវត្តសមស្របហើយ ឬនៅ។ ក្នុងសន្និសីទ កាលពីខែមីនា ឆ្នាំ២០១៤ ស្តីពី ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ក្រសួងយុត្តិធម៌បានធ្វើការប្រកាសថា ខ្លួននឹងបង្កើតក្រុមការងារមួយដើម្បីត្រួតពិនិត្យតាមដានការអនុវត្តលើនីតិវិធីថ្មីនេះ ប៉ុន្តែមកដល់ពេលនេះ ក្រុមការងារនោះ មិនទាន់បង្កើតនៅឡើយទេ។

ព័ត៌មានទទួលបានពីអង្គការដៃគូនានាឃើញថា បើទោះជាចៅក្រមប្រហែល ៥០ ភាគរយ បានប្រើប្រាស់ទម្រង់នីតិវិធីថ្មីនៃការឃុំខ្លួនបណ្តោះអាសន្នមុនសវនាការក៏ដោយ ក៏ពួកគាត់នៅតែមិនបានផ្តល់នូវហេតុផលច្បាស់លាស់ ចំពោះការសម្រេចចិត្តរបស់ពួកគាត់ក្នុងការបញ្ជូនជនណាម្នាក់ ទៅធ្វើការឃុំខ្លួនបណ្តោះអាសន្នរង់ចាំពេលសវនាការនោះទេ។ ទោះបីជាវាមិនទាន់ច្បាស់នៅឡើយថា តើមានជនត្រូវចោទតិចជាងមុន ត្រូវបានឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ដោយសារនីតិវិធីថ្មីនេះក៏ដោយ ក៏ប៉ុន្តែអត្រាខ្ពស់នៃការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការនៅក្នុងពន្ធនាគារ បង្ហាញថា ការអនុវត្តន៍ទម្រង់នីតិវិធីច្បាប់នេះ នៅមិនទាន់មានឥទ្ធិពលគួរឲ្យកត់សម្គាល់នៅឡើយទេ មកដល់ពេលនេះ។

# បន្ទុកមួយសម្រាប់រដ្ឋាភិបាល និងសង្គម

អំណះអំណាង ក្នុងការកាត់បន្ថយអត្រានៃការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការមានច្រើនណាស់។ ការកាត់បន្ថយចំនួនអ្នកត្រូវជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ នឹងកាត់បន្ថយភាពចង្អៀតក្នុងពន្ធនាគារ កាត់បន្ថយការចំណាយរបស់ពន្ធនាគារ និងជួយបង្កើនសមត្ថភាពបុគ្គលិកពន្ធនាគារ។ ចំពោះជនចាប់ចោទ ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេវិញ ជម្រើសផ្សេងៗឲ្យការឃុំខ្លួនបណ្តោះអាសន្នរងចាំសវនាការ អាចទប់ស្កាត់ផលវិបាកជាច្រើន ដោយសារការឃុំខ្លួនដែលមានចំពោះសង្គម សេដ្ឋកិច្ច រាងកាយ និងផ្លូវចិត្ត ហើយនិងបង្ការការរើសអើង និង ការចាត់ទុកជាឧក្រិដ្ឋជននានាដោយសារតែការជាប់ពន្ធនាគារ។

ការឃុំខ្លួនពេលរង់ចាំសវនាការ មានផលប៉ះពាល់អវិជ្ជមានជាច្រើន ហើយចំពោះករណីខ្លះផលវិបាកនៃការឃុំខ្លួនមុនពេលសវនាការដែលប្រកបដោយស្ថានភាពអាក្រក់ ក្នុងស្ថានភាពមិនចាំបាច់អាចធ្ងន់ធ្ងរខ្លាំងណាស់។ បុគ្គលដែលជាប់ឃុំ អាចបាត់បង់គ្រួសារ ផ្ទះសម្បែង និងទ្រព្យសម្បត្តិផ្សេងៗ ការងារ និងជីវភាពរបស់ពួកគាត់។ ប្រសិនបើស្ថិតក្នុងពេលសិក្សា អនីតិជនអាចខកខានការរៀនសូត្រ និងការទទួលបានការបណ្តុះបណ្តាលផងដែរ។ ជនជាប់ឃុំខ្លួនបណ្តោះអាសន្នរងចាំសវនាការ ក៏ដូចជាជនជាប់ឃុំដទៃទៀតដែរ ប្រឈមទៅនឹងបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្ត ហើយទំនងជាមិនទទួលការព្យាបាលសមស្រប ដែលអាចនាំឲ្យមានបញ្ហាសុខភាពរយៈពេលវែង។

ដោយសារតែស្ថានភាពមិនល្អនៃសេវាសុខភាពក្នុងពន្ធនាគារនៅកម្ពុជា ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ អាចបណ្តាលឱយមានការបាត់បង់ជីវិតផងដែរ។ ទោះបីជា អង្គការលីកាដូ មិនមានព័ត៌មានពេញលេញអំពីការស្លាប់របស់ជនជាប់ឃុំក៏ដោយ ក៏ក្នុងចំណោមការស្លាប់របស់ជនជាប់ឃុំចំនួន ២៥ នាក់ ដែកត់ត្រាដោយអង្គការលីកាដូ នាកំឡុង ខែមករា និងខែតុលា ឆ្នាំ២០១៤ មាន ៥ នាក់ ជាបុរសដែលជាប់ឃុំខ្លួនបណ្តោះអាសន្នរងចាំសវនាការ ហើយ ៤ នាក់ក្នុងចំណោមពួកគាត់មានអាយុក្រោម ៣០ ឆ្នាំ។

ស្ថានភាពមិនល្អនៃការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ រួមទាំងការភ័យខ្លាចពីការជាប់ពន្ធនាគាររយៈពេលវែង ក៏បានបណ្តាលអោយជនជាប់ឃុំមួយចំនួនគិតធ្វើអត្តឃាតផងដែរ។

អង្គការ លីកាដូ បានជួបជាមួយអតីតជនជាប់ឃុំ ជាពិសេស ជនជាប់ឃុំជានារី ដែលបានរៀបរាប់អំពីផលប៉ះពាល់នៃការឃុំខ្លួន (រួមទាំងការឃុំខ្លួនបណ្តោះអាសន្នរងចាំសវនាការ) ដែលមានមកលើគ្រួសារ និងសហគមន៍។ អតីតជនជាប់ឃុំខ្លះ បានពន្យល់ថា កូនៗរបស់ពួកគាត់ត្រូវបង្ខំចិត្តបោះបង់ការសិក្សា ហើយអ្នកផ្សេងទៀតបានប្រាប់ថា សមាជិកគ្រួសាររបស់គាត់គ្មានជម្រើសអ្វីក្រៅពីបោះបង់ការងារ ដើម្បីមើលថែទាំគ្រួសារ។

ការរកឃើញរបស់ អង្គការលីកាដូ បង្ហាញថា ជនជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ រួមទាំងនារី និងកុមារ ជារឿយៗ ត្រូវបានឃុំខ្លួនក្នុងស្ថានភាពលំបាក ជាងជនដែលត្រូវបានកាត់ទោសរួចទៅទៀត។ ជាធម្មតា ឱកាសក្នុងការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំ សម្រាប់ពួកគាត់ មានកំណត់ ហើយបន្ទប់ឃុំឃាំងរបស់ពួកគាត់មានសភាពចង្អៀតណែនជាង ដោយភាគរយនៃជនជាប់ឃុំខ្លួនរង់ចាំសវនាការមានកំរិតខ្ពស់។ មួយវិញទៀត នៅតាមពន្ធនាគារខ្លះ ពុំមានការបែងចែកអោយបានច្បាស់លាស់រវាង ពិរុទ្ធជន និងទណ្ឌិត ដែលេនះមានលក្ខណៈផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ និងច្បាប់ ស្តីពីពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា។[៥០]

*អំឡុងពេលទស្សនកិច្ចថ្មីៗនេះទៅកាន់ពន្ធនាគារមួយ ដែលក្នុងនោះជនជាប់ឃុំ ៥០ ភាគរយ បានកាត់ទោសរួច ជនជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ត្រូវបានឃុំខ្លួនក្នុងអគារដែលមានការរៀបចំ និងទំហំដូចគ្នាទៅនឹងអគារទុកសម្រាប់ដាក់ទណ្ឌិតមានកម្រិតសន្តិសុខខ្ពស់ ដែលមានចំនួនតិចជាងនេះ។ ខណៈពេលដែលអាជ្ញាធរពន្ធនាគារបានប្រាប់អង្គការ លីកាដូ ថា*

## ការប៉ុនប៉ងធ្វើអត្តឃាត

រ័ត្ន បានប៉ុនប៉ងធ្វើអត្តឃាតខណៈពេលដែលគាត់ ត្រូវបានឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការ ដោយសារតែស្ថានភាពក្នុងបន្ទប់ឃុំឃាំង និងភាពមិនច្បាស់លាស់ពីអនាគតរបស់គាត់។ គាត់បានពណ៌នា ពីស្ថានភាពឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការថា វាមានលក្ខណៈយ៉ាប់យ៉ឺន និង មានភាពតានតឹងបំផុត ដែលមានមនុស្ស រហូតទៅដល់ ១០ នាក់ នៅក្នុងបន្ទប់ ដែលមានទំហំ ១២ ម៉ែត្រការ៉េ។ ក្នុងនាមជាជនជាប់ចោទដែលត្រូវបាន ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ គាត់មិនត្រូវបានអនុញ្ញាតអោយធ្វើការ ដូច្នេះហើយ ពេលវេលាសម្រាប់ចេញមកក្រៅរបស់គាត់មានដែនកំណត់។ ទណ្ឌិតផ្សេងទៀត បានជម្រឹតទារប្រាក់ពីគាត់ ហើយមេបន្ទប់ឃុំឃាំង តែងតែឃ្លាំមើលសកម្មភាពរបស់គាត់ ដើម្បីរាយការណ៍ទៅ អាជ្ញាធរពន្ធនាគារ។ ដោយសារ រ័ត្ន មិនមាន មេធាវី គាត់មិនបានដឹងថាតើគាត់នឹងត្រូវជាប់ពន្ធនាគាររយៈពេលប៉ុន្មាននោះទេ។

ជំនួសអោយការទទួលបាននូវជំនួយប្រកបដោយវិជ្ជាជីវៈ បន្ទាប់ពីការប៉ុនប៉ងធ្វើអត្តឃាត លោករ័ត្ន បានប្រាប់លីកាដូថា មន្ត្រីពន្ធនគារបានដាក់ខ្នោះដៃគាត់ ហើយ ដាក់គាត់ឱ្យនៅជាមួយជនជាប់ឃុំដទៃទៀត ដែលបានគំរាមកំហែងសម្លាប់គាត់ ប្រសិនបើគាត់ប៉ុនប៉ងធ្វើអត្តឃាតម្តងទៀត។

នៅក្នុងសវនាការ លោករ័ត្ន ដែលត្រូវបានឃុំខ្លួនដោយសារបទល្មើសតូចតាច ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ១ ឆ្នាំ។ ស្ថានភាពឃុំឃាំងរបស់គាត់ មានលក្ខណៈ ល្អប្រសើរជាបន្តបន្ទាប់ ហើយគាត់ត្រូវបានអនុញ្ញាតអោយធ្វើការងារជាជាងឈើ ដូចនេះហើយ គាត់ទទួលបានពេលចេញមកក្រៅច្រើន និងផលប្រយោជន៍ផ្សេងៗ ដូចជា អាហារបន្ថែម និងកាហ្វេ។

[៥០] ច្បាប់ស្តីពីពន្ធនាគារ មាត្រា ២៦

*ទណ្ឌិតភាគច្រើន ត្រូវបានអនុញ្ញាតអោយចេញក្រៅបន្ទប់ឃុំឃាំង ចំនួន ៣ ទៅ ៤ម៉ោង ក្នុងមួយថ្ងៃ ចំណែកជនជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ពេលខ្លះត្រូវបានអនុញ្ញាតឲ្យចេញហាត់ប្រាណតិច ជាងមួយម៉ោងក្នុងមួយថ្ងៃប៉ុណ្ណោះ។*

វិធានអប្បបរមា នៃបទដ្ឋានអង្គការសហប្រជាជាតិសម្រាប់ការប្រព្រឹត្តចំពោះជនជាប់ឃុំ (SMR) បានកំណត់ថា ជនជាប់ឃុំទាំងឡាយណាដែលមិនត្រូវបានជួលឱយទៅធ្វើការងារខាងក្រៅ គួរតែត្រូវបានអនុញ្ញាត អោយចេញហាត់ប្រាណមួយម៉ោងយ៉ាងតិច។[៥១] ប៉ុន្តែ មិនមែនជនជាប់ឃុំទាំងអស់នៅកម្ពុជា ទទួលបាននូវសិទ្ធិអប្បបរមាជាមូលដ្ឋាននេះទេ ហើយជនជាប់ឃុំភាគច្រើនត្រូវបានបង្ខំឲ្យបង់ប្រាក់ដើម្បីទទួលបានពេលចេញមកក្រៅដើម្បីហាត់ប្រាណ។ នៅក្នុងស្ថានភាពបែបនេះ ជនជាប់ឃុំខ្លះបានចេញក្រៅបន្ទប់ឃុំឃាំង ជាទៀងទាត់ទាល់តែពួកគាត់ទទួលបានឱកាសធ្វើការងារ ទៅបណ្ណាល័យ ឬ ចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និង បំណិនជីវិតផ្សេងៗ។

ការអនុវត្តន៍បែបនេះ មានគុណវិបត្តិចំពោះជនជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការបន្ថែមទៀត។ អាជ្ញាធរពន្ធនាគារ មិនត្រូវបានតម្រូវដោយច្បាប់ក្នុងការផ្តល់ឱកាសអប់រំ ឬ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ជនជាប់ឃុំបណ្តោះអាសន្នឡើយ ហើយ អង្គការមិនមែនរដ្ឋាភិបាល ដែលជាបុគ្គលសំខាន់ក្នុងការផ្តល់សេវាកម្មនេះ ហាក់បីដូចជាទុកឱកាសក្នុងការទទួលការបណ្តុះបណ្តាល និងការអប់រំនេះសម្រាប់តែទណ្ឌិតដែលជិតផុតទោស។ ទោះបីជាមានហេតុផលសមស្របក្នុងការផ្តល់ជំនាញ និងបំណិនជីវិតផ្សេងៗនៅក្នុងដំណាក់កាលជិតដោះលែង ប៉ុន្តែនៅកម្ពុជាការធ្វើបែបនេះ អាចបណ្តាលអោយជនជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ មិនទទួលបាននូវសកម្មភាពខាងក្រៅបន្ទប់ឃុំឃាំងប្រកបដោយអត្ថន័យឡើយ។ ក្នុងករណីដែលធ្ងន់ធ្ងរបំផុត ជនជាប់ឃុំខ្លួនរង់ចាំសវនាការ កម្រឃើញពន្លឺថ្ងៃណាស់។

*សុខ និង សុជាតិ ត្រូវបានឃុំខ្លួនដោយគ្មានការជម្រះក្តីអស់រយៈពេល ១៥ ខែ ក្រោមការចោទប្រកាន់ពីបទប្រើប្រាស់អំពើហិង្សា ដែលជាការចោទប្រកាន់មួយដែលពួកគាត់បានបដិសេធ។ អ្នកទាំងពីរបានទទួលទានដំណេកនៅលើអិដ្ឋ នៅក្នុងបន្ទុកឃុំឃាំងទំហំ ៤ គុណ ៥ ម៉ែត្រ ជាមួយនឹងជនជាប់ឃុំជាង ២០ នាក់ ផ្សេងទៀត។ ពួកគាត់ បានប្រាប់អង្គការលីកាដូ ថាពួកគាត់បានចេញពីបន្ទប់ឃុំឃាំងរយៈពេលតែ ៩០ នាទី ប៉ុណ្ណោះរៀងរាល់ ២ សប្តាហ៍ ម្តង។ អ្នកទាំងពីរដែលត្រូវបានឃុំឃាំងនៅក្នុងបន្ទប់ឃុំឃាំងផ្សេងគ្នា បានបញ្ជាក់ថា ជនជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការដទៃទៀត ក៏មានស្ថានភាពដូចពួកគាត់ផងដែរ ពោលគឺពេលវេលាចេញក្រៅបន្ទប់ឃុំឃាំងមានលក្ខណៈរឹតត្បិត។ ក្រោយពីកិច្ចអន្តរាគមន៍ សុខ និង សុជាតិ ទទួលបានមេធាវីការពារក្តីអោយ ហើយនៅពេលដែលករណីរបស់ពួកគាត់ត្រូវបានជំនុំជម្រះក្តី តុលាការបានលើកលែងការចោទប្រកាន់លើពួកគាត់ទាំងពីរ ហើយពួកគាត់ត្រូវបានដោះលែងភ្លាមៗ។*



អ្នកស្រីទឹម ស័ក្តមុន្នី សកម្មជនដីធ្លីសហគមន៍បុរីកីឡា ត្រូវបានដោះលែង
នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២

## ការផ្តោតលើអ្នកការពារសិទ្ធិមនុស្ស

ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ដែលគ្មានមូលហេតុសមស្រប ជាទូទៅ ត្រូវបានប្រើប្រាស់ សម្រាប់គំរាមកំហែង និង បង្ក្រាបអ្នកការពារសិទ្ធិមនុស្ស សកម្មជននយោបាយ និង សកម្មជនដីធ្លី ដែលបានបង្កការរំខានពួកគេ ក្នុងការរៀបចំការពារក្តី ប្រកបដោយ ប្រសិទ្ធិភាព និងជាការផ្ញើសារដល់អ្នកដទៃថា នឹងមិនមានការអត់អោនឡើយ។

អ្នកការពារសិទ្ធិមនុស្សអ្នកស្រី ទឹម ស័ក្តមុន្នី ត្រូវបានចាប់ខ្លួននៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ ហើយត្រូវបានដាក់ពន្ធនាគារពីបទឆបោក ទាក់ទងនឹងសកម្មភាពនិយមតវ៉ាដីធ្លីរបស់គាត់។ គាត់ត្រូវបានឃុំខ្លួនបណ្តោះអាសន្នរយៈពេល ៣ ខែ ហើយការធានាអោយនៅក្រៅឃុំ មិនត្រូវបានអនុញ្ញាតឡើយ។ អ្នកស្រី និងក្រុមគ្រួសារត្រូវបានត្រូវបានបណ្តេញចេញ ពីបុរីកីឡា[៥២] នាដើមឆ្នាំ ២០១២ ដោយក្រុមហ៊ុន ផានីមិច ដែលជាក្រុមហ៊ុនអភិវឌ្ឍន៍មានទំនាក់ទំនងល្អ និងគ្រប់គ្រងដោយអ្នកស្រី ស៊ុយ សុផាន (ជាអ្នកដាក់ពាក្យបណ្តឹង ដែលនាំអោយអ្នកស្រី ត្រូវបានឃុំខ្លួន)។

ក្រោយពីត្រូវបានគេបណ្តេញចេញ ពីផ្ទះសម្បែង អ្នកស្រីទឹម ស័ក្តមុន្នី រួមទាំងកូនប្រុស និងចៅ ២ នាក់ ទៀត បានរស់នៅជណ្តើរជាប់ជញ្ជាំង ក្នុងអគារបុរីកីឡា។ អ្នកស្រី គឺជាអ្នកថែរក្សា និងផ្គត់ផ្គង់ប្រាក់ចំណូលសម្រាប់គ្រួសារ ហើយខណៈពេល ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ គ្រួសាររបស់អ្នកស្រី បានពឹងផ្អែកលើជំនួយពីសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ ចៅរបស់គាត់ ក៏ បានជួយរកប្រាក់កម្រៃចិញ្ចឹមគ្រួសារ តាមរយៈការដើររើសអេតចាយ ដោយពួកគេត្រូវងើបនៅម៉ោង ៥ ព្រឹក ដើម្បីអាចរកបានប្រាក់ខ្លះ មុនពេលទៅសាលារៀន។ កូនប្រុសរបស់អ្នកស្រី ដែលជាអតីតទាហានមួយរូបមាន ជំងឺរបេង ប្រចាំកាយ និងស្ពឹកមួយចំហៀងខ្លួន បណ្តាលមកពីរបួសដោយសារអំបែង ត្រូវត្រង់ក្បាល កាលពីគាត់អាយុ១៨ ឆ្នាំ។

នៅពេលសវនាការ អ្នកស្រីទឹម ស័ក្តមុន្នី ត្រូវបានផ្តន្ទាទោស ពីបទបផ្តល់សេចក្តីប្រកាសដោយភូតកុហក និងត្រូវបានឃុំខ្លួនរយៈពេល ៦ ខែ ដែលត្រូវបានព្យួរទោសមួយចំនួន។ អ្នកស្រីត្រូវបានដោះលែងពីពន្ធនាគារនៅថ្ងៃដដែល។

[៥១]វិធានអប្បបរមានៃបទដ្ឋានអង្គការសហប្រជាជាតិសម្រាប់ការប្រព្រឹត្តចំពោះជាជាប់ឃុំ មាត្រា ២១ (១)
[៥២] សម្រាប់ព័ត៌មានអំពីសាវតានៃការបណ្តេញចេញពីបូរីកីឡារ និងបញ្ហាជម្លោះដីធ្លីដែលកើតមានបន្តមក សូមមើល http://www.licadho-cambodia.org/tag/borei_keila

# ការឃុំខ្លួនខុសច្បាប់

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា នីតិជនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ រហូតដល់រយៈពេល ៦ ខែ មុនពេលសវនាការ ប្រសិនបើនីតិជននោះ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ។ ការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ អាចពន្យារពេលបានពីរដង រហូតដល់រយៈពេលអតិបរមា ១៨ ខែ ប្រសិនបើមានដីការសំអាងហេតុត្រឹមត្រូវ។ ជនជាប់ចោទពីបទល្មើសមជ្ឈឹម អាចត្រូវឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ រយៈពេល អតិបរមា ៦ខែ មុនពេលសវនាការ ប៉ុន្តែថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ ខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បរមានៃទោសដែលច្បាប់បានកំណត់ឡើយ។ អនីតិជន[៥៣] អាចត្រូវឃុំខ្លួនរយៈពេលចន្លោះពី ២ខែ ដល់ ៦ខែ មុនពេលសវនាការ អាស្រ័យលើ អាយុរបស់ពួកគាត់ ឬ ចរិកលក្ខណៈនៃបទល្មើសដែលត្រូវបានចោទប្រកាន់។[៥៤]

ទោះបីជាយ៉ាងណា តាមការពិត ជនជាប់ឃុំជាច្រើន ត្រូវបានឃុំខ្លួនលើសរយៈពេលអតិបរមា ដែលអនុញ្ញាត សម្រាប់ការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ។ បញ្ហានេះ ទំនងកើតឡើងច្រើនបំផុត ចំពោះជនជាប់ឃុំ ដែលមិនមានលទ្ធភាពបង់ថ្លៃសេវាកម្មឲ្យមេធាវី ឬ ផ្ដល់ប្រាក់សូកប៉ាន់ ដល់អាជ្ញាធរពន្ធនាគារ ដើម្បីដំណើរការឯកសារឲ្យពួកគាត់។ អ្នកស្រាវជ្រាវពន្ធនាគារ អង្គការលីកាដូ តែងតែស្រាវជ្រាវរកជនជាប់ឃុំដែលជួបប្រទះបញ្ហាទាំងនេះ ហើយអន្តរាគមន៍ ដើម្បីឲ្យមានការដោះលែងជាបន្ទាន់។ បន្ទាប់ពីការអន្តរាគមន៍របស់អង្គការលីកាដូ ពីចន្លោះខែមករា ដល់ខែមិថុនា ឆ្នាំ២០១៤ ជនជាប់ឃុំ ២៩ រូប ដែលបានជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ លើសរយៈពេលដែលច្បាប់កំណត់ បានចូលរួមសវនាការលើករណី របស់ពួកគាត់ នៅសាលាដំបូងរាជធានីភ្នំពេញ។

*រស្មី អាយុ ២០ ឆ្នាំ ត្រូវបានជាប់ខ្លួននៅ ខែកញ្ញា ឆ្នាំ២០១០ ហើយត្រូវបានឃុំខ្លួននៅពន្ធនាគារតាខ្មៅ។ គាត់ត្រូវបានចោទប្រកាន់ពីបទ សមគំនិតក្នុងករណីចោរកម្ម។ តាមច្បាប់ ក្នុងនាមជានីតិជន ដែលជាប់ចោទពីបទល្មើសមជ្ឈឹម គាត់មិនគួរជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ លើសពីរយៈពេល ៦ ខែ នោះទេ ប៉ុន្តែពេលដែលអង្គការលីកាដូ បានជួប រស្មី គាត់បានជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ អស់រយៈពេលជិត ២ ឆ្នាំ ទៅហើយ ហើយក៏មិនបានទទួលព័ត៌មានអ្វីសោះឡើយ ទាក់ទងនឹងសវនាការលើករណីរបស់គាត់។ ពេលដែល អង្គការលីកាដូ បានដឹងអំពីករណីរបស់គាត់ មេធាវីមួយរូបត្រូវបានរកជូនគាត់ ហើយករណីរបស់គាត់ត្រូវបានបើកសវនាការនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២។ គាត់ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ២៥ ខែ ហើយត្រូវបានដោះលែង នៅរយៈពេលពីរសប្ដាហ៍ក្រោយមក។*

ករណីផ្សេងទៀតនៃការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការខុសច្បាប់នៅកម្ពុជា រួមមានអ្នកដែលត្រូវជាប់ឃុំមុនសវនាការ បើទោះជា ពួកគាត់ជាប់ចោទពីបទល្មើស ដែលមានការដាក់ទោសតិចជាងរយៈពេល ១ ឆ្នាំ និងអ្នកដែលមានការពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ដោយមិនអនុលោមទៅតាមនីតិវិធីត្រឹមត្រូវនោះទេ។

វាមិនមែនត្រឹមតែអ្នកដែលរង់ចាំសវនាការនោះទេ ដែលជាទូទៅត្រូវបានឃុំខ្លួនខុសច្បាប់នៅកម្ពុជា។ តាមពិត មានកត្តាជាច្រើន ដែលនាំឲ្យមានការឃុំខ្លួនខុសច្បាប់ ទាំងចំពោះជនជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ និងទណ្ឌិត។ តាមការកត់ត្រារបស់អង្គការ លីកាដូ ករណីភាគច្រើនគឺពាក់ព័ន្ធនឹងជនជាប់ឃុំ ដែលត្រូវបានឃុំខ្លួនលើសកាលបរិច្ឆេទត្រូវដោះលែង។ រឿងបែបនេះច្រើនតែកើតឡើង ដោយសារការពន្យារពេលដំណើរការឯកសារ ឬ ដោយសារសំនុំរឿងរបស់ជនជាប់ឃុំបានបាត់។

## ថ្លៃសម្រាប់សេរីភាព

យោងតាមប្រកាសស្ដីពីរបបអាហារ និង ឧបករណ៍បរិក្ខារ[៥៥] ក្នុងបន្ទប់ឃុំខ្លួនជនជាប់ឃុំទាំងអស់ ត្រូវទទួលបានប្រាក់ស្មើនឹង ១២,៥០ ដុល្លារ ពេលដែលដោះលែង សម្រាប់ថ្លៃអាហារ និងថ្លៃធ្វើដំណើរត្រលប់ទៅគេហដ្ឋានវិញ ប៉ុន្តែពួកគាត់ភាគច្រើនបានរាយការណ៍ថា ពួកគាត់មិនទទួល បានអ្វីនោះទេ។ ផ្ទុយទៅវិញ អតីតជនជាប់ឃុំខ្លះ រាយការណ៍ថា ពួកគាត់ត្រូវបង់ប្រាក់ ឬ ផ្ដល់អំណោយ ដើម្បីបានដោះលែង។

ជនជាប់ឃុំម្នាក់ បានរាយការណ៍ថា មន្ត្រីពន្ធនាគារ សុំស្រាបៀរមួយកេសពីគាត់ ខណៈ ជនជាប់ឃុំម្នាក់ទៀតមានប្រសាសន៍ថា វាជារឿងធម្មតាទៅហើយ ដែលជនជាប់ឃុំ ត្រូវបង់ប្រាក់ចន្លោះពី ៥០ ទៅ ១០០ ដុល្លារ ដើម្បីបានដោះលែង។ មន្ត្រីពន្ធនាគារ និងមន្ត្រីតុលាការ ត្រូវបានរាយការណ៍ថា បានសុំប្រាក់ពីជនជាប់ឃុំក្នុងការដំណើរការឯកសារដោះលែងទាន់ពេលវេលា។ ទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសនាពេលចាប់ខ្លួន ដូចជា ប្រាក់កាស ទូរស័ព្ទដៃ និងគ្រឿងអលង្ការ ជាទូទៅមិនត្រូវបានប្រគល់ជូនម្ចាស់ដើមវិញទេ។

អង្គការលីកាដូ ក៏បានលឺថា ជនជាប់ឃុំត្រូវបានគេតម្រូវឲ្យបង់ប្រាក់ សម្រាប់ការថតចម្លង សាលក្រមរបស់ពួកគាត់។ បើមិនដូច្នេះទេ ពួកគាត់មិនអាចដាក់ពាក្យសុំបន្ធូរបន្ថយទោស ឬ សុំការលើកលែងទោសបានឡើយ ហើយឯកសារដោះលែងរបស់គាត់ មិនអាចដំណើរការទៅបានស្រួល។ ក៏មានការរាយការណ៍ដែលថា ជនជាប់ឃុំត្រូវប្រាក់សូកប៉ាន់មន្ត្រីពន្ធនាគារ ដើម្បីបានឈ្មោះរបស់ពួកគាត់ដាក់បញ្ចូលទៅក្នុងបញ្ជីជនជាប់ឃុំ ដែលត្រូវយកទៅពិចារណា ដើម្បីទទួលការលើកលែងទោសពីព្រះមហាក្សត្រ។[៥៦]

គ្រួសាររបស់ជនជាប់ឃុំម្នាក់ ដែលបានជាប់ក្នុងពន្ធនាគារត្រឹមតែរយៈពេល ២២ ថ្ងៃ ត្រូវបានគេតម្រូវឲ្យបង់ប្រាក់ចំនួន ២០ ដុល្លារ នៅមុនថ្ងៃដោះលែង ១ ថ្ងៃ ហើយត្រូវបានប្រាប់ថា ចំនួនទឹកប្រាក់នេះ គឺសម្រាប់ថ្លៃទឹក អាហារសម្រាប់គាត់ក្នុងពេលគាត់ជាប់ឃុំឃាំងនេះ។ ភរិយារបស់គាត់បង់ប្រាក់ទាំងស្ទាក់ស្ទើរ ដោយខ្លាចថា បើគាត់មិនបង់ប្រាក់ស្វាមីរបស់គាត់នឹង មិនត្រូវដោះលែងនោះទេ។

[៥៣] អាយុអប្បបរមាសម្រាប់ការជាប់ពន្ធនាគារនៅកម្ពុជា គឺអាយុ ១៤ ឆ្នាំ។
[៥៤] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៨ ២០៩ ២១២ និង ២១៣
[៥៥] សូមលើលេខយោង ១១
[៥៦] សម្រាប់ជាឧទាហរណ៍ សូមមើល http://www.rfa.org/english/news/cambodia/release-02062013155341.html និង http://www.phnompenhpost.com/national/officials-accused-taking-bribes-royal-pardons

សំណាង ត្រូវបានចាប់ខ្លួនកាលពី ខែកក្កដា ឆ្នាំ២០០៣ ក្នុងខេត្តបន្ទាយមានជ័យ ហើយ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេលពេល ១០ ឆ្នាំ កាលពីខែមេសា ឆ្នាំ២០០៤ ពីបទ ចោរកម្ម។ ក្នុងឆ្នាំ២០១០ សំណាង ត្រូវបានផ្ទេរទៅមណ្ឌលអប់រំកែប្រែទី៤ ក្នុងខេត្តពោធិ៍សាត់។ ពេលដែលអង្គការលីកាដូទទួលដំណឹងអំពីករណីរបស់សំណាង សំណាងបានជាប់ពន្ធនាគារ អស់រយៈពេលជាង ១១ ឆ្នាំ ទៅហើយ។ គាត់ត្រូវបានដោះលែងនៅខែកក្កដា ឆ្នាំ២០១៤ បន្ទាប់ពីការអន្តរាគមន៍របស់អង្គការលីកាដូ។

# ការរង់ចាំសវនាការសាលាឧទ្ធរណ៍ដ៏យូរ

ឧបសគ្គមួយទៀត ដែលមានចំពោះអ្នកជាប់នៅក្នុងប្រព័ន្ធយុត្តិធម៌របស់កម្ពុជា គឺ ការពន្យារពេលដ៏យូរនៃសវនាការសាលាឧទ្ធរណ៍ ដែលកើតមានឡើងជាញឹកញាប់ មិនថា ការប្តឹងឧទ្ធរណ៍នោះធ្វើឡើងដោយចុងចោទ ឬ ក៏ដោយព្រះរាជអាជ្ញានោះទេ។ បញ្ហានេះមួយចំណែកអាចពន្យល់បាន ដោយសារកម្ពុជាមានសាលាឧទ្ធរណ៍តែមួយ ដែលមានទីតាំងនៅរាជធានីភ្នំពេញ។ បញ្ហានេះ រួមផ្សំជាមួយនឹងបញ្ហាកង្វះប្រព័ន្ធដឹកជញ្ជូនជនជាប់ឃុំគ្រប់គ្រាន់ នាំឲ្យមានកិច្ចការបន្ទាន់ដ៏ច្រើន ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ ដែលមិនទាន់បានដោះស្រាយឲ្យបានត្រឹមត្រូវនៅឡើយ។[៥៧]

ជនជាប់ឃុំជាច្រើន ក៏រង់ចាំសវនាការសាលាឧទ្ធរណ៍រាប់ឆ្នាំផងដែរ ហើយបន្តជាប់នៅក្នុងពន្ធនាគារធម្មតា ដោយសារ ដូចជា បញ្ហាបច្ចេកទេសរដ្ឋបាលសាមញ្ញ ដូចជា ការបាត់ ការពន្យារពេល ឬក៏ឯកសារមិនត្រឹមត្រូវ។ ជាអកុសល ជនជាប់ឃុំ ដែលរង់ចាំសវនាការសាលាឧទ្ធរណ៍មិនមានមធ្យោបាយផ្នែកច្បាប់ណាមួយ ដើម្បីប្តឹងនោះទេ ដោយសារក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា មិនបានកំណត់ថេរវេលាច្បាស់លាស់ ដែលសាលាឧទ្ធរណ៍ត្រូវបើកសវនាការទៅលើបណ្តឹងឧទ្ធរណ៍មួយ។[៥៨]

ចំនុចមួយដែលមិនធម្មតា និងជាបញ្ហាដែលគួរចាប់អារម្មណ៍ ទាក់ទងនឹងប្រព័ន្ធយុត្តិធម៌កម្ពុជា គឺពាក់ព័ន្ធនឹងការប្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញា។ ប្រសិនបើព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចណាមួយ ជនជាប់ចោទត្រូវតែបន្តជាប់ឃុំ ដើម្បីរង់ចាំសវនាការសាលាឧទ្ធរណ៍ ហើយក្នុងករណីខ្លះ រយៈពេលនៃការជាប់ឃុំ លើសពីរយៈពេលនៃកំណត់ទោសដំបូង។ ទោះជាចំពោះអ្នកដែលតុលាការដំបូងលើកលែងការចោទប្រកាន់ក៏ដោយ ក៏ត្រូវរង់ចាំមើល ថាតើ ព្រះរាជអាជ្ញាសម្រេចប្តឹងឧទ្ធរណ៍ចំពោះការសម្រេចនេះឬអត់។[៥៩]



ជនជាប់ឃុំជាបុរសនៅពេលចេញហាត់ប្រាណ នៅពន្ធនាគារ ខេត្តព្រៃវែង ឆ្នាំ២០១២

*ពិសិដ្ឋ អាយុ ៣៣ ឆ្នាំ បានជាប់ឃុំរយៈពេលជាង ៦ ឆ្នាំ ក្នុងពន្ធនាគារ ទោះបីជា គាត់ទទួលរយៈពេលកំណត់ទោសដំបូងត្រឹមតែ ១៣ ខែ ប៉ុណ្ណោះ។ ពិសិដ្ឋ ត្រូវបានចាប់ខ្លួននៅ ខែកក្កដា ឆ្នាំ២០០៧ ចំពោះការសង្ស័យទាក់ទងនឹងរឿងចោរកម្ម ហើយគាត់បានជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការអស់រយៈពេលជាង ១ ឆ្នាំ មុនពេលគាត់ត្រូវបានតុលាការកាត់ឲ្យជាប់ទោសរយៈពេល ១៣ ខែ ប៉ុន្តែសេចក្តីសម្រេចនេះ ត្រូវបានប្តឹងទាស់ដោយព្រះរាជអាជ្ញា។ ប្រសិនបើព្រះរាជអាជ្ញា មិនប្តឹងទាស់ចំពោះសេចក្តីសម្រេចនេះទេ ពិសិដ្ឋ នឹងត្រូវដោះលែង កាលពីខែសីហា ឆ្នាំ២០០៨។ ផ្ទុយទៅវិញ ពេលដែលអង្គការលីកាដូ ទទួលបានព័ត៌មានទាក់ទងករណីនេះ កាលពី ខែកញ្ញា ឆ្នាំ២០១៣ គាត់បានជាប់ឃុំអស់រយៈពេលជាង ៦ ឆ្នាំ ទៅហើយ ហើយគាត់មិនទទួលបានព័ត៌មានអ្វីសោះ ទាក់ទងនឹងការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា។ ពិសិដ្ឋ ត្រូវបានដោះលែងក្នុងរយៈពេល ១ សប្តាហ៍ បន្ទាប់ពីកិច្ចអន្តរគមន៍របស់ អង្គការលីកាដូ។*

ការសម្រេចចិត្តរបស់ព្រះរាជអាជ្ញាក្នុងការប្តឹងទាស់ ចំពោះសេចក្តីសម្រេចរបស់សាលាដំបូងជារឿយៗហាក់ដូចជាមិនសមស្រប ហើយខ្វះនូវការពិចារណា ទៅលើផលលំបាកដែលមានចំពោះជន

[៥៧] សម្រាប់ព័ត៌មានបន្ថែមស្តីពីវិបត្តិនៃការដឹកជញ្ជូនជនជាប់ឃុំ និងសិទ្ធិប្តឹងឧទ្ធរណ៍ សូមមើល http://www.licadho-cambodia.org/collection/18/in_absentia_appeal_transportation_2013
[៥៨] មាត្រា ៣៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា សាលាឧទ្ធរណ៍ត្រូវ "សម្រេចនៅក្នុងរយៈពេលសមស្រប"។
[៥៩] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៩៨

ជាប់ចោទ និងក្រុមគ្រួសាររបស់អ្នកទាំងនោះ។អត្រានៃការប្តឹងឧទ្ធរណ៍បែបនេះ ក៏ហាក់ដូចជា មានអត្រាខ្ពស់ ចំពោះខេត្តជាក់លាក់មួយចំនួនដែលបញ្ជាក់ថា ព្រះរាជអាជ្ញាមួយចំនួន មានចិត្តចង់ ក្នុងការប្តឹងទាស់ចំពោះសេចក្តីសម្រេចណា ដែលខ្លួនមិនសប្បាយចិត្ត ជាងព្រះរាជអាជ្ញាមួយចំនួនទៀត។

ករណីមួយ ក្មេងប្រុសអាយុ ១៧ ឆ្នាំ ម្នាក់ ត្រូវបានប្រាប់ថា ព្រះរាជអាជ្ញាប្តឹងទាស់ ចំពោះសេចក្តីសម្រេចលើរូបគាត់ មួយថ្ងៃមុនថ្ងៃដែលគាត់ត្រូវដោះលែង។ ឥឡូវ គាត់ជាប់ឃុំអស់រយៈពេល ៦ ខែ លើសរយៈពេលនៃកំណត់ទោសដំបូង។

*វណ្ណី ត្រូវបានជាប់ខ្លួន កាលពីខែធ្នូ ឆ្នាំ២០១១ ចំពោះការសង្ស័យទាក់ទងនឹងរឿងជួញដូរគ្រឿងញៀនហើយត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ១ ឆ្នាំ។ នាងមានផ្ទៃពោះរយៈពេល ៤ ខែ ពេលដែលនាងត្រូវបានចាប់ខ្លួន ហើយនាងសម្រាលបានកូនប្រុសក្នុងខែឧសភា ឆ្នាំ២០១២។ ក្នុងលក្ខខណ្ឌធម្មតា វណ្ណី គួរត្រូវបានដោះលែងក្នុងខែធ្នូ ឆ្នាំ២០១២ ប៉ុន្តែព្រះរាជអាជ្ញាបានប្តឹងទាស់ចំពោះសេចក្តីសម្រេចដែលដាក់ពន្ធនាគារគានាងរយៈពេល ១ ឆ្នាំ នេះ។ ពេលដែលសាលាឧទ្ធរណ៍បើកសវនាការលើបណ្តឹងឧទ្ធរណ៍នេះ វណ្ណី និងកូនប្រុសរបស់នាង បានជាប់ក្នុងពន្ធនាគារអស់រយៈពេល ២ ឆ្នាំកន្លះ រួចមកហើយ។ សាលាឧទ្ធរណ៍បានតម្កល់សេចក្តីសម្រេចរបស់សាលាដំបូង និងការដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំដដែល។*

# ឧបសគ្គក្នុងការទទួលបានយុត្តិធម៌

"ជំនួយផ្នែកមេធាវី
ជាកត្តាសំខាន់មួយ
ក្នុងការផ្តល់នូវយុត្តិធម៌ឲ្យស្មើគ្នា។
វាធ្វើឲ្យជនចាប់ចោទក្រីក្រ ឬ
ជនជាប់ចោទដែលមានប្រាក់
ស្ថិតក្នុងស្ថានភាពស្មើគ្នាជាងមុន
ដែលបង្កើនឱកាសអ្នកទាំងនោះ
ក្នុងការទទួលបានការការពារស្មើគ្នា
ឲ្យអស់លទ្ធភាពនៃច្បាប់។
បើមិនមានជំនួយផ្នែកមេធាវី នោះទេ
យុត្តិធម៌នៅកម្ពុជា
នឹងសម្រាប់តែអ្នកមានប្រាក់
អ្នកមានអំណាច និងអ្នកមានខ្សែ
រយៈតែប៉ុណ្ណោះ។"

លោកស្រី វ៉ាន់ ហ៊ីលី តំណាងការិយាល័យឧត្តមស្នងការ
អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

នៅឯសន្និសីទមួយ ស្តីពីជំនួយផ្នែកមេធាវីនៅកម្ពុជា[៦០] កាលពីខែវិច្ឆិកា ឆ្នាំ២០១៣ លោកជំទាវ កែម សន្តិភាព អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ បានក្រើនរំលឹកដល់អ្នកចូលរួមថា "ការទទួលបានយុត្តិធម៌ និងសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ត្រូវបានធានា... ដោយមិនគិតពីឋានៈសង្គមនោះ ទេ។" ប៉ុន្តែ ប្រជាជនកម្ពុជាស្ថិតនៅសែនឆ្ងាយពីការទទួលបានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ នៅឡើយ។ ផ្ទុយទៅវិញ ការទទួលបានយុត្តិធម៌ ទូទៅអាស្រ័យទៅលើឋានៈសង្គម និងស្ថានភាពហិរញ្ញវត្ថុ។

ជំនួយផ្នែកមេធាវី នៅតែមានភាពខ្វះខាតយ៉ាងខ្លាំង នៅកម្ពុជា ដោយមានតែមេធាវីជំនួយផ្នែកច្បាប់ចំនួនត្រឹមតែ ៧៤ រូប ប៉ុណ្ណោះ ដែលបម្រើការងារនៅទូទាំងប្រទេសកម្ពុជាទាំងមូល ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ (មានការថយចុះ ៤០ ភាគរយ ពី ឆ្នាំ២០១០) ដោយ ៥១ រូប មានមូលដ្ឋានការងារស្ថិតនៅទីក្រុងភ្នំពេញ។ ខេត្តចំនួន ៧ មិនមានមេធាវីជំនួយផ្នែកច្បាប់ ដែលមានមូលដ្ឋានការងារនៅទីនោះទាល់តែសោះ ហើយកម្មវិធីជំនួយផ្នែកមេធាវី នៃគណៈមេធាវីកម្ពុជា មានមេធាវី ជំនួយផ្នែកច្បាប់បម្រើការងារពេញម៉ោងត្រឹមតែចំនួន ៧ រូប ប៉ុណ្ណោះ។[៦១] បើទោះជារាជរដ្ឋាភិបាល បាន បង្កើនថវិកាសម្រាប់កម្មវិធីជំនួយផ្នែកមេធាវីនាពេលថ្មីៗនេះក៏ដោយ
ក៏សមត្ថភាពរបស់គណៈ មេធាវី នៅតែមានកម្រិតយ៉ាងខ្លាំងដដែល។

ដោយសារបញ្ហាកង្វះមេធាវីជំនួយផ្នែកច្បាប់នោះហើយ ជាពិសេសនៅតាមទីជនបទ និងថ្លៃសេវា មេធាវីឯកជនខ្ពស់ពេក ជនជាប់ចោទជាច្រើន មិនមានមេធាវីការពារឲ្យអ្នកទាំងនោះនោះទេ។ បញ្ហានេះប្រាកដជានាំឲ្យមានស្ថានភាពមួយ ដែលជនជាប់ឃុំភាគច្រើន ដែលជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការ និងជនដែលត្រូវបានទោសឲ្យជាប់ពន្ធនាគាររួច គឺជាជនក្រីក្រ។ នាយក ពន្ធនាគារក្នុងខេត្តមួយបានប្រាប់អង្គការលីកាដូ ថា ជនជាប់ឃុំក្នុងពន្ធនាគាររបស់លោក មានត្រឹមតែ ៥ ភាគរយ តែប៉ុណ្ណោះមានមេធាវីការពារក្តីឲ្យ។

ទោះបី ចំពោះអ្នកដែលមានលទ្ធភាពជួលមេធាវីឯកជនក៏ដោយ ក៏មិនមានការធានាផ្តល់ការការពារដែលប្រកបដោយគុណភាពនោះដែរ។ បញ្ហាអំពើពុករលួយដែលរីករាលដាល នៅក្នុងប្រព័ន្ធយុត្តិធម៌ទាំងមូល បានធ្វើឲ្យមានឧបសគ្គដល់កិច្ចការការពារករណីនេះ ហើយមេធាវីជាច្រើន នឹងមិនព្យាយាមផ្តល់ការការពារឲ្យត្រឹមត្រូវដល់អតិថិជនរបស់នោះខ្លួននោះទេ បែរជាផ្តល់សំណូកដល់មន្ត្រីតុលាការទៅវិញ ដើម្បីទទួលបានការដាក់ទោសធូរស្រាល។ មេធាវីខ្លះ

[៦០] សន្និសីទថ្នាក់ជាតិស្តីពីជំនួយផ្នែកមេធាវីនៅកម្ពុជា សហរៀបចំដោយ ក្រសួងយុត្តិធម៌ និងគណៈមេធាវីកម្ពុជា ក្រោមការជួយឧបត្ថម្ភពីអង្គការ យូនីសែហ្វ (UNICEF) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា សណ្ឋាគារកាំបូដឌីយ៉ាណា ភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣។
[៦១] http://cambodia.ohchr.org/WebDOCs/DocProgrammes/Number_and_location_of_legal_aid_lawyers_in_Cambodia.pdf

បាន រាយការណ៍ប្រាប់អង្គការលីកាដូ ថា ពួកគាត់មិនទាន់ត្រៀមខ្លួន ក្នុងការទទួលករណីណា ដែល មិនមានប្រាក់ទុកសម្រាប់សូកប៉ាន់នោះទេ ពីព្រោះចៅក្រមជំនុំជម្រះនឹងសម្រេចសេចក្ដីប្រឆាំងនឹងអ្នកទាំងនោះនៅពេលសវនាការខាងមុខ។

ដោយជឿថា ពួកគាត់អាចទទួលបានយុត្តិធម៌ខ្លះ អ្នកទាំងនោះជាច្រើនលក់ដី ផ្ទះ ឬទ្រព្យសម្បត្តិផ្សេងទៀត ឬ ជំពាក់បំណុលគេ ដើម្បីបង់ថ្លៃសេវាមេធាវី ហើយជារឿយៗ មិនទទួលបានអ្វីច្រើនមកវិញនោះទេ។ អង្គការលីកាដូបានទទួលការប្ដឹងពីបុគ្គល ដែលបានចំណាយថវិកាមួយចំនួនធំ ទៅដល់មេធាវី ដែលក្រោយមក មេធាវីនោះបាន បាត់ខ្លួន និងអ្នកដ៏ទៃទៀត ដែលមិនមានការព្យាយាមក្នុងការការពារក្ដីឲ្យបានត្រឹមត្រូវនៅឡើយ។ ចំពោះករណីមួយ គ្រួសាររបស់កុមារអាយុ ១៥ ឆ្នាំ ម្នាក់ បានខ្ចីថវិកាចំនួន ៣.០០០ ដុល្លារ ដើម្បីបង់ ឲ្យទៅមេធាវី ប៉ុន្តែក្រោយមក ពួកគាត់មិនដែលទទួលបានព័ត៌មានអ្វីសោះ ពីមេធាវីនោះ។

ជនជាប់ចោទដែលជាប់ឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ បានរាយការណ៍ថាមិនដែលបានជួបមេធាវីរបស់ខ្លួននោះទេ ហើយភាគច្រើនមិនបានទទួលការណែនាំផ្នែកច្បាប់ឲ្យ បានត្រឹមត្រូវ មុនពេលសវនាការនោះដែរ ឬ ក៏មិនទទួលបានការណែនាំទាក់ទងនឹងការប្ដឹងឧទ្ធរណ៍នោះឡើយ។ អតីតជនជាប់ឃុំម្នាក់បានរាយការណ៍ថា មន្ត្រីពន្ធនាគារបានប្រាប់គាត់ថា គាត់មិនចាំបាច់ត្រូវការមេធាវីនោះទេ ហើយផ្ទុយទៅវិញ គាត់គួរតែផ្ដល់ប្រាក់កាសឲ្យគាត់វិញ ដើម្បីឲ្យគាត់



កន្លែងជួបមេធាវី នៅមណ្ឌលអប់រំកែប្រែទី២ ឆ្នាំ២០០៩

## យុត្តិធម៌ត្រូវបានបដិសេធ

កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ ពេលដែលនគរបាលបាញ់ប្រហារ និងសម្លាប់អ្នក ឈរមើលដែលមិនមានកំហុសម្នាក់ និងបាញ់គ្រាប់កាំភ្លើងពិតមកលើកក្រុមមនុស្សចម្រុះ ដែលមានដូចជា អ្នករស់នៅទីនោះ អ្នកធ្វើដំណើរ និងបាតុករអហិង្សា នគរបាល ក៏បានចាប់ខ្លួនមនុស្ស ៦ រូប ទៀតផងដែរ ដោយចោទប្រកាន់អ្នកទាំងនោះ ពីបទអំពើហិង្សាដោយចេតនានិងការបង្កឲ្យខូចខាតទ្រព្យសម្បត្តិ។ សាលវនាការរបស់អ្នកទាំងនោះនាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ជាឧទាហរណ៍ដ៏ច្បាស់ក្នុងការបង្ហាញពីភាពទន់ខ្សោយ នៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ សាក្សីជានគរបាលជាច្រើនរូប ដែលបានមកបំភ្លឺនៅក្នុងតុលាការ មិនអាចកំណត់អត្តសញ្ញាណចុងចោទ សូម្បីតែម្នាក់ ហើយនគរបាលទាំងនោះ ច្រានចោលការទទួលខុសត្រូវ របស់អង្គភាពរៀងៗខ្លួន ក្នុងការចាប់ខ្លួនអ្នកទាំង ៦ រូប នោះ។ បើទោះជាមានការខ្វះខាតភស្តុតាងទាំងអស់ក៏ដោយ ក៏អ្នកទាំង ៣ រូប ក្នុងចំណោមអ្នកទាំង ៥ រូប ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ៣ ឆ្នាំដដែល។ បុគ្គលពីររូប ក្នុងចំណោមអ្នកដែលត្រូវបានកាត់ឲ្យជាប់ទោស ទោសរបស់អ្នកទាំងនោះ ត្រូវបានកាត់បន្ថយត្រឹមរយៈពេល ២៥ ថ្ងៃ។ ដោយសារតែគាត់ បានជាប់ឃុំឃាំងបណ្ដោះអាសន្នរង់ចាំសវនាការ ហេតុដូច្នេះ គាត់មិនបន្តជាប់នៅក្នុងពន្ធនាគារទៀតទេ។ ទោះបីជាយ៉ាងណា បុគ្គលទី៣ ទោសរបស់គាត់ត្រូវបានកាត់បន្ថយ មកត្រឹមតែរយៈពេល ១ ឆ្នាំ ពីព្រោះគាត់ ផ្ដិតមេដៃលើលិខិតសារភាព។ លិខិតសារភាពនោះ ដែលសរសេរជាភាសាខ្មែរ ត្រូវបានទទួល យកជាបានការ បើទោះបីជាការពិត បុរសនេះជាជនជាតិវៀតណាម ហើយមិនអាចអានភាសាខ្មែរបានផង។

ដោះស្រាយបញ្ហានេះ។

នាពេលសវនាការ ជនជាប់ចោទជារឿយៗ ត្រូវបានកាត់ឲ្យជាប់ទោស ដោយមិនមានភស្តុតាងច្បាស់លាស់ និងចម្លើយសាក្សីត្រឹមត្រូវនោះទេ។ តុលាការទទួលយកចម្លើយសារភាព នៅកន្លែងឃុំឃាំងរបស់នគរបាល ជាមូលដ្ឋានចំបង ឬ ជាមូលដ្ឋានតែមួយគត់ក្នុងការផ្តន្ទាទោសជនជាប់ចោទ។ ប្រសិនបើពិតជាមានភស្តុតាងដែលផ្ទុយគ្នាទៅនឹងចម្លើយសារភាព នៅកន្លែងឃុំឃាំងរបស់នគរបាល ជារឿយៗ តុលាការមិនអើពើនឹងភស្តុតាងនោះទេ។ បញ្ហានេះ ពិតជាគួរឲ្យព្រួយបារម្ភណ៍យ៉ាងខ្លាំង ដោយសារថា តាំងពីឆ្នាំ២០០៨ មក ៩០ ភាគរយ នៃការរំលោភបំពានទាំងអស់ ដែលបានរាយការណ៍មកអង្គការលីកាដូ ត្រូវបានគេរាយការណ៍ថា បានកើតឡើងនៅកន្លែងឃុំឃាំងរបស់នគរបាល ដែលជាធម្មតាដើម្បីបង្ខំឲ្យសារភាព។

តុលាការដែលឯករាជ្យ និងនីតិរដ្ឋរឹងមាំ គឺជាមូលដ្ឋានក្នុងការកសាងទំនុកចិត្តរបស់សាធារណៈជន ចំពោះរាជរដ្ឋាភិបាល និងដើម្បីការពារសង្គមកម្ពុជាពីការរំលោភអំណាច ពីសំណាក់មន្ត្រីរបស់រដ្ឋ និងបុគ្គលដែលមានខ្សែរយៈខ្លាំង។ ទោះបីជាយ៉ាងណា ផ្ទុយទៅវិញ ច្បាប់មូលដ្ឋានបីដែលទាក់ទងនឹងតុលាការ[៦២] ហាក់ដូចជាត្រូវបានបង្កើតឡើង ដើម្បីព្យាយាមការពារការត្រួតត្រារបស់រាជរដ្ឋាភិបាល មកលើគ្រប់ផ្នែកទាំងអស់នៃប្រព័ន្ធតុលាការ។

តាមច្បាប់ថ្មីទាំងនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវបានចាត់តាំងឲ្យត្រួតត្រាយ៉ាងខ្លាំង ទៅលើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានអំណាចសម្រេច លើថវិការបស់ឧត្តមប្រឹក្សានៃអង្គចៅក្រម និងជាអ្នកកំណត់សម្រេច ថាតើ ត្រូវចាត់វិធានការចំពោះចៅក្រម ឬ ព្រះរាជអាជ្ញា ឬ អត់។ ចៅក្រម និងព្រះរាជអាជ្ញានឹងត្រូវរួមបញ្ចូលទៅក្នុងក្របខណ្ឌរដ្ឋបាលរបស់ក្រសួងយុត្តិធម៌ ហើយមន្ត្រីជាន់ខ្ពស់របស់ក្រសួងយុត្តិធម៌នឹងធ្វើជាប្រធានគណៈកម្មាធិការ ក្នុងការសម្រេចតំឡើងឋានៈដល់ចៅក្រម។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏មានអំណាចខ្លះផងដែរ



តុលាការសាលាឧទ្ធរណ៍ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២

[៦២] ច្បាប់សំខាន់ថ្មីបី ស្តីទីប្រព័ន្ធតុលាការមានដូចជា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ។



ជនជាប់ឃុំឃាំងធ្វើការនៅក្នុងពន្ធនាគារ ខេត្តកំពង់ចាម ឆ្នាំ២០១២

# សេចក្តីបញ្ចប់

ក្នុងការគ្រងគ្រងការចាត់តាំងចៅក្រម និងករណីផ្សេងៗ ផងដែរ។

នៅពេលដែលរដ្ឋមួយ ដកហូតសេរីភាពរបស់បុគ្គលម្នាក់ រដ្ឋនោះក៏ត្រូវទទួលយកភារកិច្ច ក្នុងការគោរពសេចក្តីថ្លៃថ្នូរ និងការពារសិទ្ធិរបស់បុគ្គលនោះផងដែរ។បើទោះជាមានសិទ្ធិខ្លះអនុវត្តទៅដោយមានកម្រិត ដោយសារការជាប់ពន្ធនាគារក៏ដោយ[៦៣] ក៏នៅមានសិទ្ធិផ្សេងជាច្រើនទៀត ដែលត្រូវតែការពារ ដោយមិនមានការរើសអើងផងដែរ។ ក្នុងការបំពេញកាតព្វកិច្ចនេះ រដ្ឋមិនមែន ត្រឹមតែធានាឲ្យមាននូវកន្លែងរស់នៅសមរម្យ ស្ថានភាពរស់នៅប្រកបអនាម័យ ហើយអាហារ ទឹកនិងការហាត់ប្រាណគ្រប់គ្រាន់ប៉ុណ្ណោះទេរដ្ឋក៏ត្រូវតែការពារបុគ្គលម្នាក់ៗ ពីការរំលោភបំពានផ្នែករាងកាយ និងផ្លូវចិត្ត បញ្ហាសុខភាព ដោយសារការរស់នៅក្នុងពន្ធនាគារ និងស្ថានភាពរស់នៅបែបអមនុស្សធម៌ និងបន្ថោកបន្ទាបផ្សេងៗផងដែរ។

ជាការសោកស្តាយណាស់ ថ្វីបើការអះអាងរបស់រាជរដ្ឋាភិបាល ផ្ទុយពីនេះ ប្រព័ន្ធយុត្តិធម៌ និង ព្រហ្មទណ្ឌនៅកម្ពុជា មិនបានយកវិធីសិទ្ធិមនុស្សមកអនុវត្តតាមនោះទេ។ ផ្ទុយទៅវិញ ប្រព័ន្ធទាំងពីរជារចនាសម្ព័ន្ធមិនប្រក្រតី ដែលដឹកនាំដោយបក្សពួកនិយម។ តុលាការបន្តប្រើប្រាស់ ពន្ធនាគារជាមធ្យោបាយ ក្នុងការបំបិទសម្លេងសកម្មជននយោបាយ និងដកហូតក្រុមដែលគេមិនពេញចិត្តចេញពីសហគមន៍របស់ពួកគេ ខណៈដែលអាជ្ញាធរពន្ធនាគារមានចិត្តមិនអនុវត្តតាមការទទួលខុសត្រូវរបស់ខ្លួន ក្នុងការផ្តល់ការពារ ជំនួយដោយការទទួលបានផលប្រយោជន៍ផ្នែក សេដ្ឋកិច្ច និងនយោបាយ។

បើទោះជាអាជ្ញាធរពន្ធនាគារខ្លះបានត្អូញត្អែរថា ពួកគាត់ខ្វះធនធានហិរញ្ញវត្ថុ និងធនធានសម្ភារៈផ្សេងទៀត ក្នុងការអនុវត្តន៍កំណែទម្រង់ដែលបានសន្យាក៏ដោយ គួរតែទទួលស្គាល់ ផងដែរថាថវិកាមួយមុខមិនអាចដោះស្រាយបញ្ហាដែលចាក់យ៉ាងជ្រៅ នៅក្នុងពន្ធនាគារកម្ពុជា បាននោះទេ។ ដំបូង តុលាការត្រូវយល់អំពីផលប៉ះពាល់នៃគោលនយោបាយនៃការដាក់ទោស និងទី២ ចាំបាច់ត្រូវងាកចេញឲ្យឆ្ងាយបញ្ហាចំបង ដែលធ្វើឲ្យប៉ះពាល់ដល់ជីវិតនៅក្នុងពន្ធនាគារ ដូចជា បញ្ហាពុករលួយ ឥទ្ធិពលនៃថ្នាក់ដឹកនាំក្នុងបន្ទប់ឃុំឃាំងដ៏មានអំណាច និងការខ្វះទាំងស្រុងនូវការទទួលខុសត្រូវ។ បើមិនមានការផ្លាស់ប្តូរបញ្ហាចំបងទាំងនេះទេ អាជ្ញាធរពន្ធនាគារកម្ពុជា និងមិនអាចបំពេញ ឬ សម្រេចគោលបំណងដែលបានអះអាង ដូចជាការអប់រំ និង ស្តានីតិសម្បទា នៅកន្លែងដែលមានសុវត្ថិភាព ហើយពន្ធនាគារនៅតែជាកន្លែងដែលមានការ រំលោភបំពានសិទ្ធិ ជាជាងគោរព និងការពារសិទ្ធិដដែល។

## អនុសាសន៍

►►► អនុញ្ញាតឲ្យបង្កើនការឃ្លាំមើល ចំពោះគ្រប់កន្លែងឃុំឃាំងទាំងអស់ ដោយអ្នកឃ្លាំមើលឯករាជ្យ និងបញ្ឈប់ការរឹតត្បិតមិនមានហេតុផលសមស្រប ចំពោះការចូលក្នុងពន្ធនាគារ របស់អង្គការលីកាដូ។ អ្នកឃ្លាំមើលរបស់អង្គការលីកាដូ និងអ្នកឃ្លាំមើលផ្សេងទៀត ត្រូវតែអាចធ្វើការសម្ភាសន៍ដោយសម្ងាត់ជាមួយនឹងជនជាប់ឃុំទាំងអស់ នៅពេលដែលមានការស្នើសុំ។

►►► ផ្តល់នូវកម្មវិធីជំនួយផ្នែកមេធាវីឲ្យបានគ្រប់គ្រាន់ មានប្រសិទ្ធិភាព និងមាននិរន្តភាព ដែលផ្តល់នូវធនធានគ្រប់គ្រាន់ និងសមត្ថភាពឯករាជ្យ ដើម្បីធានានូវការទទួលបាន យុត្តិធម៌ សម្រាប់ទាំងអស់គ្នា ជាពិសេសប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ ហើយជម្រុញឲ្យបុគ្គលដែលត្រូវបានដកហូតសេរីភាព ទទួលបាននូវសិទ្ធិក្នុងការទទួលការជួយពីមេធាវី។

►►► បង្កើតនូវយន្តការបង្ការថ្នាក់ជាតិដែលឯករាជ្យពិតប្រាកដ ដោយសមាសភាពនៃការចូលរួមពីសំណាក់អ្នកជំនាញឯករាជ្យ ដែលមានសមត្ថភាពគ្រប់គ្រាន់ និងមិនស្ថិតក្រោម ឥទ្ធិពលរបស់រដ្ឋាភិបាល និងមានលទ្ធភាពធ្វើការងារដោយឯករាជ្យ និងមានស្វ័យភាពថវិកាផងដែរ។

►►► កំណែទម្រង់ច្បាប់សំខាន់ទាំងបី ស្តីអំពីស្ថាប័នតុលាការ ដើម្បីធានាថា ស្ថាប័នតុលាការអាចដំណើរការទៅប្រកបដោយឯករាជ្យ និងមានប្រសិទ្ធិភាព ក្នុងការការពារសិទ្ធិបុគ្គលគ្រប់រូប ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

►►► បង្កើតប្រព័ន្ធយុត្តិធម៌សម្រាប់អនីតិជនដាច់ដោយឡែក ដោយសម្រេច និងអនុវត្តមិនពន្យារពេល នូវសេចក្តីព្រាងច្បាប់ស្តីពីកុមារទំនាស់ជាមួយច្បាប់ ហើយធានាថា ច្បាប់នេះមានលក្ខណៈស្របគ្នាទៅនឹងវិធានអង្គការសហប្រជាជាតិ សម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព និងវិធានអប្បបរមានៃបទដ្ឋានអង្គការសហប្រជាជាតិ សម្រាប់ការគ្រប់គ្រងយុត្តិធម៌របស់អនីតិជន។

►►► ឃ្លាំមើលឲ្យបានត្រឹមត្រូវ នូវការអនុវត្តន៍នីតិវិធីថ្មីទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ហើយចាត់វិធានការណ៍ចំពោះចៅក្រមដែលប្រើប្រាស់ទម្រង់ថ្មីនេះមិនបានត្រឹមត្រូវ ក្នុងគោលបំណង ដើម្បីបង្កើនការប្រើប្រាស់វិធានការរង់ចាំសវនាការដោយមិនជាប់ឃុំឃាំង ហើយនិងកាត់បន្ថយការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ។

►►► កំណត់ ជាអាទិភាព នារីមានផ្ទៃពោះ និងនារីដែលមានកូននៅជាមួយ ជាបេក្ខជន ក្នុងការទទួលបានការដោះលែងបណ្តោះអាសន្នក្រោមការត្រួតពិនិត្យ និង/ឬ ទោសមិនជាប់ឃុំឃាំង។

[៦៣] ដូចជា សិទ្ធិទទួលបានឯកជនភាព សេរីភាពក្នុងការផ្លាស់ទី និងសេរីភាពក្នុងការប្រមូលផ្តុំ

►►► ធានាថា ការសិក្សាវាយតម្លៃពេញលេញ ត្រូវធ្វើឡើង ដើម្បីកំណត់ថា តើវាជាការប្រសើរ ក្នុងការដាក់កុមារឲ្យនៅផ្សេងពីម្ដាយដែលជាប់ពន្ធនាគារ ឬថាតើកុមារគួរតែបន្តរស់នៅ ក្នុងពន្ធនាគារ ហើយត្រូវចេញជាគោលការណ៍ណែនាំច្បាស់លាស់ ពីរបៀបអនុវត្ត និង ជម្រុញការរកកន្លែងឲ្យកុមាររស់នៅខាងក្រៅពន្ធនាគារ នៅពេលដែលកុមារមានអាយុ ៣ ឆ្នាំ។

►►► ផ្ដល់ការបណ្ដុះបណ្ដាលដល់បុគ្គលិកពន្ធនាគារ ស្ដីពីការលូតលាស់របស់កុមារ និងសេចក្ដីត្រូវការក្នុងការថែទាំសុខភាព សម្រាប់នារីមានផ្ទៃពោះ និងកុមារ ដើម្បីពួកគាត់អាចឆ្លើយតបបានសមស្របពេលដែលមានសេចក្ដីត្រូវការ និងភាពបន្ទាន់។ ចាត់អ្នកជំនាញឲ្យឃ្លាំមើលពីការលូតលាស់របស់កុមារ ដើម្បីឲ្យថា ប្រសិនបើកុមារមានបញ្ហា យើងអាចដឹងជាមុន។

►►► ធានាថា នារីវ័យក្មេងក្នុងពន្ធនាគារត្រូវបានផ្ដល់ជូននូវការថែទាំជាពិសេស ទៅតាមសេចក្ដីត្រូវការរបស់ពួកគាត់ ហើយផ្ដល់ដល់ជនជាប់ឃុំជានារីទាំងអស់ ជាពិសេស កុមារី នូវការបណ្ដុះបណ្ដាលសមស្រប ឲ្យដូចជនជាប់ឃុំជាបុរសដែរ ដើម្បីជួយឲ្យពួកគាត់ ទទួលបានការងារនាពេលអនាគត។

►►► ចាត់វិធានការធ្វើឲ្យស្ថានភាពពន្ធនាគារមានភាពប្រសើរឡើង ហើយកាត់បន្ថយភាពចង្អៀតណែន រួមទាំងធ្វើឲ្យប្រសើរឡើងនូវអនាម័យ ការផ្គត់ផ្គង់ម្ហូបអាហារ និងសម្ភារៈបរិក្ខារពេទ្យ។

►►► ធានាថា មានតែមន្ត្រីពន្ធនាគារតែប៉ុណ្ណោះដែលមានសិទ្ធិអំណាច ក្នុងការអនុវត្តវិធានការ ដាក់វិន័យ ចំពោះជនជាប់ឃុំបាន។ ករណីរំលោភបំពាន ឬ ធ្វើបាប ប្រព្រឹត្តដោយជនជាប់ឃុំដទៃទៀត ត្រូវធ្វើការស៊ើបអង្កេត និងដាក់ទោស ហើយមន្ត្រីពន្ធនាគារណា ដែលបានព្រងើយកន្តើយ ឬ បិទបាំងរឿងបែបនេះ ត្រូវទទួលខុសត្រូវ។

►►► បង្កើតនូវកម្មវិធីរបស់រដ្ឋដែលមានប្រសិទ្ធិភាព ក្នុងការការពារជនរងគ្រោះ និងសាក្សី ដើម្បីធានានូវភាពសម្ងាត់ និងការពារអ្នកដែលរាយការណ៍ និងប្ដឹងអំពីអំពើទារុណកម្ម ហើយត្រូវធានាថា ជនរងគ្រោះទទួលបានការតបស្នងសមស្រប។

►►► បង្កើតប្រព័ន្ធតាមដាន និងចាត់ការចំពោះអំពើពុករលួយក្នុងពន្ធនាគារ។ មន្ត្រីរូបណា ដែលរកឃើញថា បានពាក់ព័ន្ធនឹងអំពើពុករលួយ ត្រូវដកហូតដំណែងជាបន្ទាន់ ហើយ ដាក់វិន័យឲ្យបានសមស្រប។

►►► បញ្ឈប់ជាបន្ទាប់នូវការយកប្រាក់ចំពោះការមកសួរសុខទុក្ខជនជាប់ឃុំ ហើយធានាថា ជនជាប់ឃុំទាំងអស់ត្រូវបានផ្ដល់ឱកាសក្នុងការឆ្លើយឆ្លងលិខិតទំនាក់ទំនងជាទៀងទាត់ ការទទួល និងទាក់ទងទូរស័ព្ទ ហើយការទទួលបានព័ត៌មានពីពិភពខាងក្រៅ។

►►► ចាត់ចែងជាអាទិភាព នូវថវិកាសម្រាប់យានជំនិះ និងសាំង ក្នុងការដឹកជញ្ជូនជនជាប់ ឃុំទៅចូលរួមសវនការសាលាឧទ្ធរណ៍ និងបញ្ជូនត្រលប់មកពន្ធនាគារខេត្តវិញ។

►►► ធ្វើឲ្យប្រសើរឡើងនូវសម្ភារៈបរិក្ខារពេទ្យ ជាបញ្ហាអាទិភាព ហើយធានាថា ប៉ុស្តិ៍សុខភាព ពន្ធនាគារមានថ្នាំ និងសម្ភារៈបរិក្ខារគ្រប់គ្រាន់។ ផ្ដល់ជូនបុគ្គលិកពេទ្យពន្ធនាគារ នូវការបណ្ដុះបណ្ដាលឲ្យបានសមស្រប ដើម្បីឆ្លើយតបទៅនិងសេចក្ដីត្រូវការផ្នែកសុខភាព របស់ជនជាប់ឃុំ។

►►► ធ្វើការសិក្សាវាយតម្លៃអំពីស្ថានភាពសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនជាប់ឃុំថ្មី ឲ្យបានសមស្រប ក្នុងគោលបំណងដើម្បីធានាថា ពួកគាត់ទទួលបានការថែទាំសមស្រប និងបន្តបន្ទាប់។

►►► បង្កើតឲ្យមានការពារដើម្បីធានាថា ជនជាប់ឃុំធ្វើការឲ្យអង្គភាពឯកជនដោយស្ម័គ្រចិត្ត ហើយលក្ខខណ្ឌការងារមានភាពប្រហាក់ប្រហែលគ្នានឹងទំនាក់ទំនងការងារសេរី។ កម្មវិធីការងាររបស់ពន្ធនាគារគួរតែមិនមានការរំលោភបំពាន ហើយសុខភាព និង សុវត្ថិភាពរបស់ជនជាប់ឃុំដែលធ្វើការងារនោះ ត្រូវយកចិត្តទុកដាក់ជាអាទិភាព។